ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-Mar-2012, 15:11
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២**

**ម៉ោង ០៩:០៩ នាទី**

**សវនាការលើកទី៤០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

លោក រ៉ូជ័រ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ(*Mr. Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក ឡោ ជុនធី

លោកស្រី ទី ស្រ៊ីនណា

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

លោក ហុង គឹមសួន

កញ្ញា លី ម៉ាញៀន *(Ms.Lyma NGUYEN)*

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| កញ្ញា លី ម៉ាញ៉ឿន | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក នួន ជា | ខ្មែរ |
| លោក កាំង ហ្កេកអ៊ាវ | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច

សួរបន្តដោយលោក សេង ប៊ុនឃាង ផ្ដើមពី..........................................................ទំព័រ ០៨
សួរដោយលោក វីល្លៀម ស្មីត ផ្ដើមពី..................................................................ទំព័រ ៥២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

អញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីឲ្យលោក នួន ជា! លោកត្រូវការពេលវេលាប៉ុន្មានទៅ? និយាយពីពេលវេលាសិន។

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធានខ្ញុំសុំរយៈពេលតែប្រាំនាទីទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

[០៩:១០:០២]

**លោក ម៉ៃខល ផេសមិន៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់។ ពីម្សិលមិញខ្ញុំចង់ជម្រាបជូននៅពេលមុននឹងសម្រាក ពីកាលពីរសៀលម្សិលមិញនូវអ្វីដែលខ្ញុំចង់និយាយ។ ខ្ញុំបានផ្ញើអ៊ីម៉ែលមួយជូនទៅមន្ត្រីជាន់-- មន្ត្រីច្បាប់ជាន់ខ្ពស់អំពីឧប្បត្តិហេតុដែលកើតឡើងនៅក្នុងបន្ទប់រង់ចាំនៅខាងក្រោម។ ហើយបន្ទាប់មកអង្គជំនុំជម្រះក៏ចេញសេចក្តីសម្រេចមួយផ្សេង។ ខ្ញុំចង់លើកឡើងនូវចំណុយមួយចំនួន។ ទីមួយ ខ្ញុំបានចុះទៅជាន់ខាងក្រោមមែន ជាការពិតហើយ នៅពេលដែលតុលាការសម្រេចឲ្យគ្រូពេទ្យពិនិត្យកូនក្តីរបស់ខ្ញុំ ហើយខ្ញុំជឿជាក់យ៉ាងមុតមាំថា នេះជាសិទ្ធិរបស់ខ្ញុំក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្ញុំ ដើម្បីជួយកូនក្តីរបស់ខ្ញុំក្នុងពេលគាត់ទទួលនូវការពិនិត្យព្យាបាលនេះ។ ខ្ញុំគ្រាន់ទៅកត់សម្គាល់មើលថា តើវាមានអ្វីកើតឡើង? ខ្ញុំមិនបានជ្រៀតជ្រែកអ្វីទាំងអស់ ហើយដោយខ្ញុំចង់ពិនិត្យមើលដោយផ្ទាល់ភ្នែកទៅលើការពិនិត្យផ្នែកវេជ្ជសាស្ត្រនេះ ហើយខ្ញុំមិនបានណែនាំកូនក្តីខ្ញុំទេ។ នេះជាបទ--

[០៩:១១:២១]

ទោះបីជាខ្ញុំមិនមែនជាវេជ្ជបណ្ឌិតក៏ដោយ ក៏ខ្ញុំកត់សម្គាល់ឃើញថា ការៗពិនិត្យនេះគឺថាមានការពិនិត្យល្អិតល្អន់ គឺថាគាត់បានពិនិត្យមើលឈាម សម្ពាធឈាម ហើយគាត់មានចលនាបេះដូងញាប់ ហើយក៏មានការពិនិត្យមើលឈាមរបស់គាត់ដែរ។ ខ្ញុំបានឃើញគ្រូពេទ្យធ្វើដូច្នេះមែន។ ខ្ញុំគិតថាអ្វីដែលគ្រូពេទ្យគួរធ្វើនេះ គឺគួរធ្វើវាការពិនិត្យមើលសមត្ថភាពរបស់គាត់ ថាតើគាត់អាចចូលរួមក្នុងដំណើរការនីតិវិធីនៅពេលនោះប្រកបដោយប្រសិទ្ធភាពដែរឬក៏អត់?

ខ្ញុំមិនដឹងថា តើមានការណែនាំពិនិត្យដោយរបៀបណាទេ? ប៉ុន្តែខ្ញុំឃើញគ្រូពេទ្យ គាត់ពិនិត្យមើលថាតើកូនក្តីខ្ញុំនោះអាចអង្គុយនៅលើកៅអីនៅក្នុងបន្ទប់សវនាការដែរឬក៏អត់នោះ? ខ្ញុំថាគ្រូពេទ្យមិនគួរពិនិត្យចំណុចនេះទេ គួរតែស្វែងរកឲ្យឃើញថា តើគាត់អាចនឹងមានការផ្ចង់អារម្មណ៍ក្នុងដំណើរការនីតិវិធីដែរឬក៏យ៉ាងម៉េច? ដើម្បីឲ្យគាត់អាចជូនជាគំនិតយោបល់អីមកដល់ខ្ញុំជាមេធាវីរបស់គាត់នោះ។ គាត់គួរតែពិនិត្យមើលទៅលើសញ្ញាណបែបនេះ និងជាពិសេសគឺសមត្ថភាព ថាតើគាត់មានសមត្ថភាពផ្ចង់អារម្មណ៍ក្នុងដំណើរការនីតិវិធីក្នុងថ្ងៃនោះដែរឬក៏យ៉ាងណានោះ?

ខ្ញុំមិនដឹងថា តើត្រូវដោះស្រាយបញ្ហានេះដោយរបៀបណាទេ ក៏ប៉ុន្តែខ្ញុំគិតឃើញថា គ្រូពេទ្យគួរតែទទួលនូវការណែនាំឲ្យបានច្បាស់លាស់ក្នុងការពិនិត្យទៅលើកូនក្តីរបស់ខ្ញុំ ពីព្រោះតាមធម្មតាកូនខ្ញុំ-- កូនក្តីខ្ញុំមិនអាចអង្គុយនៅក្នុងបន្ទប់សវនាការពេញមួយថ្ងៃបានទេ។ ដូច្នេះ ខ្ញុំចង់បានចម្លើយពីខាងតុលាការ។

[០៩:១៣:១១]

ហើយពាក្យពេចន៍ចុងក្រោយនេះ គឺការសម្រេចពីម្សិលមិញរបស់អង្គជំនុំជម្រះនោះ ខ្ញុំមិនបានឃើញប្រតិចារឹកទេ មិនដឹងថាសម្រេច-- ខ្ញុំបានឮថា អង្គជំនុំជម្រះសម្រេចថាខ្ញុំនេះមានការជ្រៀតជ្រែកចូលក្នុងកិច្ចការពិនិត្យផ្នែកខាងរោគសាស្ត្រនេះ។ ហើយការសម្រេចបែបនេះ ខ្ញុំគិតឃើញថាជាការសម្រេចមួយដែលធ្វើឲ្យប៉ះពាល់ទៅដល់សិទ្ធិរបស់ខ្ញុំ។ ពីព្រោះសេចក្តីសម្រេចនេះ គឺបានសម្រេចឡើងនៅក្នុងបន្ទប់សវនាការជាសាធារណៈនេះតែម្តង។ ខ្ញុំ-- ហើយដោយមិនផ្តល់ឱកាសខ្ញុំឆ្លើយតបទេ ដោយចោទថា ខ្ញុំជ្រៀតជ្រែកចូលក្នុងកិច្ចការវិជ្ជាជីវៈគ្រូពេទ្យនេះ។ សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[០៩:១៤:១៣]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន មេធាវីការពារក្តី គឺបាននិយាយអំពីការពិនិត្យមើលផ្នែកវេជ្ជសាស្ត្រនេះ គឺមិនមានអ្វីដែលថាគ្រូពេទ្យថា គ្រូពេទ្យមិនអាចសួរនូវសំណួរជាក់លាក់មួយចំនួននោះ។ ជាពិសេសពាក់ព័ន្ធទៅនឹង ថាតើគាត់អាចផ្តល់អារម្មណ៍បាន ឬក៏យ៉ាងណានោះ? ខ្ញុំគិតថាគួរតែមានការយកចិត្តទុកដាក់ពិសេស ប៉ុន្តែអ្វីដែលមេធាវីការពារក្តីលើកឡើងនោះ គឺថាអង្គជំនុំជម្រះត្រូវធានាដល់គ្រូពេទ្យថា ត្រូវពិនិត្យទៅមើលថា តើគាត់មានសមត្ថភាពតាមដានដំណើរការនីតិវិធីដែរឬក៏អត់? ខ្ញុំយល់ឃើញថាការពិនិត្យតាមផ្នែកវេជ្ជសាស្ត្រនេះ គឺជាការសមស្របមួយហើយ។ សូមអរគុណ។

[០៩:១៥:០៩]

**កញ្ញា លី ម៉ាញៀន៖**

លោក លោកស្រីចៅក្រម គឺថាដើមបណ្តឹងរដ្ឋប្បវេណីមានការព្រួយបារម្ភ ដោយសារថាលទ្ធផលនោះ គឺថាមានការពន្យារដំណើរការនីតិវិធីយ៉ាងវែង។ ប្រសិនជាកើតឡើងបែបនេះរៀងរាល់ថ្ងៃ យើងខ្ញុំសូមឲ្យអង្គជំនុំជម្រះអនុវត្តនូវវិធាន៨១(៥) នៃវិធានផ្ទៃក្នុង ដែលថា បើជនជាប់ចោទមិនអាចអង្គុយបាន មិនអាចចូលរួមបានដោយសារសមត្ថភាពខាងផ្លូវបញ្ញារបស់គាត់នោះ ហើយនៅពេលដែលអង្គជំនុំជម្រះសម្រេចថា អវត្តមានរបស់ជនជាប់ចោទនាំឲ្យមានការពន្យារយ៉ាងវែងនេះ ហើយដែលដំណើរការស្វែងរកយុត្តិធម៌តម្រូវឲ្យធ្វើបែបនេះ។ ដូចនោះ អង្គជំនុំជម្រះត្រូវបង្គាប់ឲ្យជនជាប់ចោទតាមដានដំណើរការនីតិវិធីតាមរយៈប្រព័ន្ធសោតទស្សន៍នេះ។

[០៩:១៦:០៤]

ដូច្នេះអ្វីដែលកើតឡើង គឺថា នួន ជា គាត់ត្រូវមានការការពារតាមរយៈក្រុមមេធាវីការពារក្តីដែលមានសមត្ថភាពនេះ។ ដូច្នេះខ្ញុំសូមឲ្យអង្គជំនុំជម្រះសូមមេត្តាថ្លឹងថ្លែងរវាងសិទ្ធិរបស់ចុងចោទ និងសិទ្ធិរបស់ភាគីដទៃទៀត ដែលកំពុងតែចូលរួមក្នុងដំណើរការនីតិវិធីនេះ។ សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្តីលោក អៀង សារី!

លោកមេធាវីការពារក្តី អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់នៅក្នុងបន្ទប់

សវនាការនេះ។ តាមធម្មតាខ្ញុំមិនដែលក្រោកឡើងក្នុងពេលនេះទេ។ ប៉ុន្តែ អ្វីដែលខ្ញុំឮពីដើមបណ្ដឹងរដ្ឋប្បវេណី គឺថាវាដំណើរការនីតិវិធីត្រូវតែបន្ត នេះបើតាម (ឮមិនច្បាស់) ដោយអនុវត្តតាមវិធានផ្ទៃក្នុង។ បើអនុវត្តបែបនេះមែននោះ គឺជាការមួយដែលត្រឹមត្រូវទេ? យើងបានពិភាក្សាគ្នាលើចំណុចនេះរួចមកហើយ។ អង្គជំនុំជម្រះបានទទួលនូវសំណើសុំរបស់យើងខ្ញុំរួចមកហើយ។ ប៉ុន្តែខ្ញុំយល់ឃើញថា អ្វីដែលក្រុមដែលលោក នួន ជា បានស្នើសុំនោះ គឺដោយសារថា វា-- ដូចស្មើរតែដូចទៅនឹងអ្វីដែលដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើង។ គាត់មិនអាចតាមដានដំណើរការនីតិវិធីបាន។

[០៩:១៧:៣៨]

ជនជាប់ចោទមិនត្រូវតែចូលរួមក្នុងដំណើរការនីតិវិធីតែរូបកាយប៉ុណ្ណោះទេ ក៏ប៉ុន្តែទាំងផ្នែកបញ្ញាស្មារតី សមត្ថភាពស្មារតីផងដែរ។ បើមិនដូច្នេះទេ គឺថាមិនត្រឹមត្រូវទេ ជាការគួរឲ្យអស់សំណើចទៅវិញទេ បើមិនមានសមត្ថភាពនេះ។ នៅពេលដែលអង្គជំនុំជម្រះសម្រេច ថាតើអ្នកណាម្នាក់មិនអាចមានសមត្ថភាពទាំងផ្លូវកាយ សមត្ថភាពផ្លូវចិត្តដើម្បីចូលរួមនោះ សេចក្ដីសម្រេចបែបនេះក៏គេបានអនុវត្តក្នុងករណី មីឡូសីវិច ដោយសារថា រឿងក្ដីរបស់គាត់មិនបានដល់ដំណាក់កាលបែបនេះទេ ដោយសារ មីឡូសីវិច គឺថាស្លាប់មុនរឿងក្ដីគាត់ត្រូវបានបញ្ចប់ទាំងស្រុងនោះ។ គេបានពិចារណាទៅលើចំណុចនេះដែរ ថាតើគេឆ្លងកាត់ចំណុចផ្នែកខាងសុខភាពបានដោយរបៀបណា? ជាពិសេសនៅពេលដែលមានបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងរឿងនេះ។

[០៩:១៨:៣៥]

ខ្ញុំបានចាំរឿងក្ដីមួយដែលនៅចំពោះមុខតុលាការអន្តរជាតិ ដែលថានៅពេលអ្នកណាមិនអាចមានសមត្ថភាពផ្លូវ-- សមត្ថភាពផ្លូវបញ្ញាស្មារតីចូលរួមបាន។ នីតិវិធីអាចបន្តទៅមុខបាន មិនអាចដំណើរការទៅមុខបានទេ ខ្ញុំមិនដឹងថាតើបញ្ហាបែបនេះ គេដោះស្រាយដោយរបៀបណាទេ។ ជាពិសេសគឺជាបញ្ហាមួយដែលអង្គជំនុំជម្រះសាលាដំបូងត្រូវពិនិត្យពិចារណា និងសម្រេច មុននឹងយើងឈានទៅដល់ដំណាក់កាលបែបនេះ។ សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដី នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែសូមថា កូនក្ដីរបស់ខ្ញុំមិនមែនអសមត្ថភាពទាំងស្រុងនោះ

ទេ។ គ្រាន់តែខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់នោះទេ ប៉ុន្តែគាត់បានបញ្ជាក់ថា គាត់មានឆន្ទៈចូលរួមឆ្លើយទៅនឹងសំណួរទាំងអស់។ ជាពិសេសគាត់បានបញ្ជាក់កាលពីសប្តាហ៍មុនរួចហើយ។ ហើយតាមដែលខ្ញុំដឹងគឺថាការពន្យារពេលដ៏វែងឆ្ងាយនេះ ជាពិសេសពីម្សិលមិញនេះឯង នេះជាលើកទីមួយហើយ។ តាមការពិតកូនក្តីរបស់ខ្ញុំគាត់ចង់មានវត្តមាននៅពេលតាំងសំណួរទៅលើសាក្សី។ ដូច្នេះ យើងខ្ញុំគាំទ្រទៅដល់លោក ម៉ែខល កាណាវាស។ នៅរឿង*ស្តាទីស៊ីក ខេស* កាលពីសប្តាហ៍មុននេះ គឺពាក់ព័ន្ធទៅនឹងវត្តមានដែរ ដែលនៅ អាយ.ស៊ី.ធី.វ៉ាយ គឺអង្គជំនុំជម្រះសម្រេចៗ អង្គជំនុំជម្រះសាលាឧទ្ធរណ៍សម្រេចថា ការពន្យារពេលពីបីទៅប្រាំមួយខែនៃដំណើរការនីតិវិធីនេះ គឺថាមិនទាន់ចាត់ទុកថាជាការពន្យារមួយវែងអន្លាយ ឬជាដុំកំភួននៅឡើយទេ។ ដូច្នេះ ខ្ញុំសុំ ស្នើសុំឲ្យអង្គជំនុំជម្រះបន្តដំណើរការនីតិវិធី ទោះគាត់មិនមានវត្តមានក៏ដោយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី ខៀវ សំផន អង្គជំនុំជម្រះអនុញ្ញាតលើកនេះ ប៉ុន្តែលើកក្រោយគប្បីលោកស្រីប្រឹងប្រែងព្យាយាមនិយាយឲ្យបានមុនពេលដែលមេធាវីការពារក្តីដែលមានបញ្ហា គាត់លើកឡើងនូវសំណើ ហើយឆ្លើយតបទៅនឹងភាគីម្ខាងទៀត ចៀសវាងលោកស្រីនិយាយទៅភាគីម្ខាងទៀតនឹងនិយាយឆ្លើយតបត្រឡប់មកវិញ ហើយលោកស្រីនឹងត្រូវការឆ្លើយតបទៀត ប្រហែលជាអាចចំណាយពេលមួយព្រឹកនេះគ្រាន់តែលើកឡើងនូវបញ្ហាប៉ុណ្ណឹង។ អង្គជំនុំជម្រះសង្ឃឹមថាលោកស្រីនឹងប្រឹងប្រែងធ្វើការងារនេះ ឲ្យបានល្អនៅពេលខាងមុខ។

សូមអញ្ជើញ មួយមីនុតបានហើយ។

[០៩:២១:៤៣]

**លោកស្រី អង់តា ហ្គីសសេះ**

ជម្រាបសួរលោកប្រធាន។ អស់លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំគ្រាន់តែសុំមិនចង់និយាយអត្ថាធិប្បាយលើប្រធានបទនេះទេ ព្រោះថាខ្ញុំដឹងថា បញ្ហានេះចប់ហើយ អ៊ីចឹងហើយបានជាខ្ញុំក្រោកឈរឡើងដើម្បីនិយាយនេះ។ ខ្ញុំចង់និយាយបញ្ហាផ្សេងមួយទៀតមុននឹងសាក្សីនេះផ្តល់សក្ខីកម្ម។ ខ្ញុំពីថ្ងៃមុនហ្នឹង ខ្ញុំបានឮនិយាយអំពីបញ្ហាល្បឿននៃការផ្តល់សក្ខីកម្មនេះ ដោយសារនិយាយលឿនពេក។ ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះជម្រាបជូនទៅដល់សាក្សីសូមឲ្យនិយាយយឺតតិចជាងហ្នឹងបន្តិច ដោយសារមានបញ្ហាចម្លើយ រវាងពេលចោទសួរ ហើយនិងពេលដែលឆ្លើយ។ ខ្ញុំគិតថាជាការសំខាន់ណាស់

ដែលសាក្សីនេះដឹងថា នៅពេលដែលយើងមានការបកប្រែជាភាសាបារាំង ហើយពេល-- ការបកប្រែទៅជាភាសាបារាំងនេះវាយឺត។ ហើយអ៊ីចឹងបើយើងពុំមានរយៈពេលសម្រាកបន្តិចទេ រវាងការអន្តរាគមន៍ទាំងពីរនេះ គឺថាយើងបាត់ផ្នែកមួយចំនួននៃពាក្យពេចន៍របស់សាក្សីនេះ។

[០៩:២៣:០៥]

ឧទាហរណ៍ដូចជា ខ្ញុំអាចយោងទៅលើប្រតិចារឹកចុះថ្ងៃទី១៩ មីនា មុននេះគឺថា នៅម៉ោងដប់បួនសែសិបនាទី សាក្សីបាននិយាយអំពីសមាសភាពនៃសភា-- មហាសន្និបាតនៅឆ្នាំ៦០ ហើយគឺថាជាភាសាបារាំងមានតែប្រាំបន្ទាត់ទេ ហើយដែល-- អ៊ីចឹងវាបាត់ប្រាំបន្ទាត់ទាំងស្រុងតែម្តង។ អ៊ីចឹងយើងដឹងថាអ្នកបកប្រែជាភាសាបារាំងនេះ គាត់ខំប្រឹងប្រែងតាមដែលអាចទៅបាន ប៉ុន្តែនៅពេលដែលការបកប្រែភាសាអង់គ្លេសនេះចប់ហើយ ស្រាប់តែភាសាខ្មែរចូលមកដល់ទៀត អ៊ីចឹង បានធ្វើឲ្យអ្នកបកប្រែហ្នឹងបកមិនទាន់ អ៊ីចឹងគឺថាយើងបាត់មួយផ្នែកធំ។ អ៊ីចឹងខ្ញុំគិតថានេះជាបញ្ហាសំខាន់ណាស់ វាជាបេះដូងនៃការពិភាក្សាយើងតែម្តង។ ហើយកាលណាយើងមិនយល់បានគ្រប់ជ្រុងជ្រោយទេ យើងមិនអាចចោទសំណួរបានឲ្យសមស្របនោះទេ។ អ៊ីចឹង សូមរំឭកដល់សាក្សីនេះថាសូមឲ្យនិយាយឲ្យយឺតជាងហ្នឹង ពីព្រោះថាដោយសារអ្នកនិយាយទាំងពីរនាក់នេះគាត់និយាយជាភាសាខ្មែរទាំងពីរ។ នេះជាអ្វីដែលខ្ញុំបាន-- ខ្ញុំចង់លើកឡើងនៅពេលព្រឹកនេះ។ គឺថា ខ្ញុំមិនមែនក្រោកឡើងដើម្បីនិយាយអំពីប្រធានបទឲ្យបាននិយាយអម្បាញ់មិញនេះទេ។

[០៩:២៤:៣៧]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយបញ្ជាក់ម្តងទៀត--

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៧:២៨]

**ប្រធានអង្គជំនុំ៖**

បានស្តាប់មតិយោបល់របស់ភាគីពាក់ព័ន្ធទៅនឹងបញ្ហាដែលកើតឡើងកាលពីម្សិលមិញ ដែលមានការចូលរួមដោយឯកចិត្តរបស់មេធាវីការពារក្តី នួន ជា មេធាវីអន្តរជាតិ នៅក្នុងការពិនិត្យសុខភាពរបស់ជនជាប់ចោទ តាមបង្គាប់របស់អង្គជំនុំជម្រះ ដោយគ្រូពេទ្យទទួលបន្ទុកពិនិត្យព្យាបាលជនជាប់ចោទនៅក្នុងបន្ទប់សវនាការនេះ។ ដើម្បីឆ្លើយតបបញ្ហានេះឲ្យបានជាក់ច្បាស់ យើងខ្ញុំសូមប្រគល់ភារៈ

នេះជូនទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីធ្វើការឆ្លើយតបទៅនឹងការលើកឡើងរបស់ក្រុមមេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការដែលខ្លួនទៅចូលរួមនៅក្នុងការសង្កេត ពិនិត្យ នូវក្របខ័ណ្ឌនៃការអនុវត្តភារកិច្ចរបស់គ្រូពេទ្យ។

សូមអញ្ជើញ លោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសូមបញ្ជាក់ដូចតទៅនេះ៖

អង្គជំនុំជម្រះបានបង្គាប់ឲ្យមានការពិនិត្យសុខភាពរបស់លោក នួន ជា បន្ទាប់ពីមានការ-- មានបញ្ហាសុខភាព។ ភាគីការពារក្តីរបស់ នួន ជា បានជំទាស់បេសកកម្មដែលយើងប្រគល់ជូនទៅដល់គ្រូពេទ្យទទួលបន្ទុកក្នុងការពិនិត្យសុខភាពរបស់លោក នួន ជា គាត់អាចជំទាស់តែក្នុងលក្ខខណ្ឌតាមផ្លូវច្បាប់តែប៉ុណ្ណោះ។ ប៉ុន្តែ ក្រុមមេធាវីការពារក្តីមិនត្រូវអនុញ្ញាតឲ្យទៅចូលរួម ឬក៏ទៅអន្តរាគមន៍ដោយផ្ទាល់ចំពោះលោកគ្រូពេទ្យនោះទេ។ ពីព្រោះថាគាត់កំពុងតែពិនិត្យជនជាប់ចោទ។ ខ្ញុំគិតថាបញ្ហានេះវាច្បាស់លាស់ហើយ ហើយថាយើងទាំងអស់គ្នាក៏យល់ដែរ គឺវាមានលក្ខណៈច្បាស់លាស់ណាស់ដែលថាកាតព្វកិច្ចរបស់មេធាវីមានព្រំដែនកំណត់ ហើយអង្គជំនុំជម្រះគ្រាន់តែចង់រំឭកថា មេធាវីក៏មានដែនកំណត់របស់ខ្លួនដែរ។

បាទ ដើម្បីឲ្យយើងច្បាស់លាស់ដែល-- គឺថាគាត់ គឺថាយើងមិនបង្គាប់ឲ្យភាគីការពារក្តីទៅចូលរួមដោយផ្ទាល់ខ្លួននឹងការពិនិត្យសុខភាពលើជនជាប់ចោទនោះទេ។

[០៩:៣១:០០]

**ប្រធានអង្គជំនុំ៖**

បាទ ជាកិច្ចបន្តគឺតាមកម្មវិធីដែលបានគ្រោងទុក គឺបន្តការស្តាប់សក្ខីកម្មសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។ ហើយអម្បាញ់មិញនេះ គឺសំណើសាជាថ្មីម្តងទៀតចំពោះសាក្សី។ អ៊ីចឹងលោក កាំង ហ្កេកអ៊ាវ សូមមានការខិតខំក្នុងការបន្ថយនូវល្បឿននៅក្នុងការនិយាយរបស់លោក ដើម្បីឲ្យអ្នកបកប្រែហ្នឹងបានបកប្រែទាន់។ ហើយមួយទៀតហ្នឹង គឺឲ្យមានការឃ្លាតគ្នាផងដែរ រវាងសំណួរ និងចម្លើយ ដើម្បីឲ្យការបកប្រែហ្នឹងចប់ទៅ សឹមលោកចាប់ផ្តើមឆ្លើយ។ ហើយដូចគ្នា កាលណាឆ្លើយចប់គឺអ្នកដែលសួរក៏ត្រូវបង្អង់បន្តិចដើម្បីឲ្យការបកប្រែចប់ ហើយនឹងសឹមចាប់ផ្តើមសួរសំណួរជាថ្មីបន្ថែមទៀត។ ហើយបញ្ហាមួយទៀត ក៏សូមរំឭកដល់សាក្សីផងដែរ ថានៅក្នុងការផ្តល់សក្ខីកម្មនៅក្នុងអំឡុងពេលនៃ

ដំណើរការសវនាការក្នុងនាមលោកជាសាក្សី គប្បីចៀសវាងនូវការចម្លើយជាលក្ខណៈវាយតម្លៃ ឬការសេចក្តីសន្និដ្ឋាននូវការយល់ដឹងផ្ទាល់ខ្លួន។ សូមផ្តល់វេទិការទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរផ្សេងៗចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:៣២:២១]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណ។ លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំនឹងបន្តសំណួរមួយចំនួនទៀតដែលទាក់ទងទៅនឹងសហករណ៍ និងការដ្ឋាន ហើយបន្ទាប់មកទៀតខ្ញុំនឹងចូលទៅដល់ការសួរសំណួរដែលទាក់ទងទៅនឹងគោលនយោបាយទូទៅ ការអប់រំកែប្រែ ការកម្ទេចខ្មាំង វិធានការចំពោះក្រុមគោលដៅមួយចំនួន និងការដាក់បទបញ្ជាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក សេង ប៊ុនឃាង៖**

សួស្តីលោក កាំង ហ្កេកអ៊ាវ! ដូចដែលអង្គជំនុំជម្រះបានជម្រាបអម្បាញ់មិញហើយថា នៅពេលដែលខាងខ្ញុំសួរ សូមលោកបង្អង់បន្តិចដើម្បីឲ្យការបកប្រែហ្នឹងបានរលូន បាទ។ លោកបានជម្រាបជូនអង្គសវនាការមួយចំនួនរួចហើយអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងការបង្កើតសហករណ៍។

**ស៖** តើលោកដឹងអំពីគោលនយោបាយនេះដំបូងគេនៅពេលណាដែរ?

[០៩:៣៣:៣៦]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ឆ្នាំ១៩៧៣ ខ្ញុំនៅឃុំអមលាំង។ ការរៀបចំបង្កើតសហករណ៍គឺនៅមូលដ្ឋានបង្អែកឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង និងនៅឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ ខ្ញុំឃើញរបៀបរបបធ្វើការ ហើយនិងការបែងចែកផល ហើយនិងការទុកដាក់ផល។ ទុកដាក់នេះ និយាយអំពីសិទ្ធិគ្រប់គ្រងផល។

**ស៖** លោកដឹងទេ ថាទាក់ទងនឹងគោលនយោបាយនៃការសិទ្ធិគ្រប់គ្រងផលអីហ្នឹង តើលោកដឹងគោលនយោបាយជាក់លាក់ណាមួយដែលទាក់ទងទៅនឹងផលិតផលកសិកម្មដែរទេ?

[០៩:៣៤:៤៣]

**ឆ៖** សហករណ៍បង្កើតឡើងដើម្បីក្តាប់ផលប្រចាំឆ្នាំ។ ដូច្នេះផលដែលក្នុងសហករណ៍នីមួយៗ បង្កបង្កើនផលបាននៅលើលេខាឃុំជាអ្នកក្តាប់ ហើយកាលណោះលេខាភាគ គណៈកម្មាធិការភាគជាអ្នកចាត់ចែងផល ប៉ុន្មានទៅសមរភូមិមុខ ប៉ុន្មានសម្រាប់ឧបត្ថម្ភប្រជាជន ប៉ុន្មានធ្វើអីផ្សេងទៀត។ ព្រោះខ្ញុំមន្ទីរហ្នឹងវាអត់បង្កបង្កើនផលទេ ដើរសុំស្រូវគេហូប។ ខ្ញុំអត់ទៅសុំពីសហករណ៍ គឺទៅសុំពីខាងភាគ។

**ស៖** តើគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាមានទាក់ទងទៅនឹងការផលិតផលកសិកម្ម តើមានដាក់ចេញនូវផែនការអ្វីខ្លះទេ? លោកមានដឹងចំពោះបញ្ហានេះដែរទេ?

[០៩:៣៥:៤៩]

**ឆ៖** ឲ្យច្បាស់ឃើញជាឯកសារ អត់ទេ។ ក៏ប៉ុន្តែជាការផ្សាយតាមវិទ្យុ គឺគេថាចែកគ្នារស់។ ហើយពេលនោះរបបសម្រាប់ប្រជាជនប៉ុន្មានកំប៉ុង គឺអត់ច្បាស់។ ផ្ទាល់ខ្លួនខ្ញុំនៅមន្ទីរនោះ ឆ្នាំនោះ ឆ្នាំ៧៤ កំពុងតែអត់បាយ។ អង្ករបន្លយ ទាំងគេទាំងខ្ញុំ។ អង្កាល់នោះ ដូចជាហូបកន្លះកំប៉ុង។

**ស៖** ចុះលោកមានដឹងទេអំពីផែនការដែលថា ត្រូវធ្វើឲ្យបានប៉ុន្មានក្នុងមួយឆ្នាំអីហ្នឹង?

**ឆ៖** ផែនការហ្នឹង បើតាមខ្ញុំចាំផ្សាយក្រោយ៧៥ នោះទេ បីតោន។ មិនដឹងជាមានមុននោះឬក៏អត់ ខ្ញុំមិនចាំទេ មិនច្បាស់។ សូមជម្រាបថាមិនច្បាស់។

**ស៖** សូមៗលោកជួយបញ្ជាក់ទាំងមុន និងក្រោយហ្នឹងផងបាទ តើយ៉ាងម៉េចដែរចំពោះគោលការណ៍នយោបាយរបស់បក្សកុម្មុយនីស្តទាក់ទងទៅនឹងផលិតផលនេះ បាទ?

**ឆ៖** ផលិតផល អានេះគេហៅថា សហករណ៍កម្រិតខ្ពស់ គឺផលិតផលគឺនៅក្នុងដៃលេខាសហករណ៍ នៅក្នុងដៃបក្ស។ ហ្នឹងសហករណ៍កម្រិតខ្ពស់ នេះមួយផ្នែកទៅ។ មួយផ្នែកទៀត មធ្យោបាយផលិតកម្ម ជាស្រែ ជាគោ ក្របី។ មធ្យោបាយផលិតកម្ម បើនិយាយពីក្នុងក្របខ័ណ្ឌសហករណ៍សំខាន់វាប៉ុណ្ណឹង តែប៉ុន្តែបើនិយាយពីក្របខ័ណ្ឌទូទាំងប្រទេសវិញ វាទាំងអស់ ទាំងស្រែ ទាំងចម្ការតូចធំ ទាំងរោងចក្រឧស្សាហកម្ម ទាំងផ្លូវគមនាគមន៍ មធ្យោបាយដឹកជញ្ជូនគ្រប់បែបយ៉ាង។ ក៏ប៉ុន្តែ ខ្ញុំនិយាយក្នុងឋានៈដែលជាសហករណ៍មួយទៅចុះ។

[០៩:៣៧:៥៦]

ក្នុងឋានៈសហករណ៍មួយ មធ្យោបាយផលិតកម្មក៏នៅក្នុងកណ្តាប់ដៃលេខាសហករណ៍ គណៈៗក៏នៅក្នុងកណ្តាប់ដៃគណៈកម្មាធិការសហករណ៍។ គណៈកម្មាធិការសហករណ៍ គឺបក្ស សាខាបក្ស។ ដូច្នេះសហករណ៍ទូទាំងប្រទេស មធ្យោបាយផលិតកម្ម វានៅក្នុងកណ្តាប់ដៃបក្ស។ ឯចំណែកមធ្យោបាយ

ផ្សេងទៀតជារោងចក្រ រោងអី ស្ថិតនៅក្នុងកណ្ដាប់ដៃបក្សទាំងអស់។ នេះអំពីបញ្ហាមធ្យោបាយផលិតកម្ម។ អំពីការចាត់ចែងកម្លាំងពលកម្មក៏នៅលើបក្សចាត់ចែង។ មួយថ្ងៃធ្វើការប៉ុន្មានម៉ោង? មួយអាទិត្យសម្រាកឬអត់? ជាគោលការណ៍ឆ្នាំនោះ ពេលនោះ ដំបូង ១០ថ្ងៃសម្រាកម្ដង ប៉ុនដល់ក្រោយមក ទាំងគេទាំងខ្ញុំមានអាណាទៅធ្វើបាន១០ថ្ងៃ អត់បានសម្រាក អត់បានសម្រាកទេ ១០ថ្ងៃ។ រហូត បររហូត។ មួយថ្ងៃធ្វើការប៉ុន្មានម៉ោង? មិនមែនប្រាំបីម៉ោងទេ លើស។ បើដូចខ្ញុំអីលើស ផ្ទាល់ខ្លួនខ្ញុំ។ មួយថ្ងៃៗអត់ដែលបានធ្វើអីស្រួលបួលទេ។ ដូច្នេះ សរុបមក មធ្យោបាយផលិតកម្មនៅលើបក្ស។ កម្លាំងពលកម្មចាត់ចែង គឺបក្ស។ ផលិតផលបានមក គឺបក្សចាត់ចែង ទៅណាប៉ុន្មានៗ រួចដល់ក្រោយ នែ៎៧៥ របបអង្គរដូចខ្ញុំនិយាយអ៊ីចឹង សម្រាប់ប្រជាជន កម្លាំងលេខមួយមួយកំប៉ុងកន្លះ សម្រាប់កងទ័ពកម្លាំងលេខមួយពីរកំប៉ុង។ ចប់ នេះគឺខ្ញុំសូមសរុបប៉ុណ្ណឹង។

[០៩:៣៩:៥២]

**ស៖** មុននេះបន្តិច ខ្ញុំឮលោកនិយាយថា បីតោន តើបីតោននេះជាអ្វីទៅ? លោកអាចបញ្ជាក់បានទេ?

**ឆ៖** បីតោន គឺទិន្នផលស្រូវប្រចាំឆ្នាំក្នុងមួយហិកតា។ សំណូមពរ រើឲ្យបែកបីតោន។

**ស៖** សំណូមហ្នឹងយ៉ាងម៉េច? តើអ្នកណាជាអ្នកដាក់សំណូមពរ?

**ឆ៖** សំណូមនេះ គឺបក្សជាអ្នកដាក់សំណូមពរ។ ដល់ក្រោយៗមកបានឃើញច្បាស់ឯកសារ គឺឯកសារលេខប្រាំមួយរយ-- អ៎ ឯកសារនែ៎ ថ្ងៃ៣០ មីនា ១៩៧៦ កថាខណ្ឌទី២។

**ស៖** តើបីតោនហ្នឹងក្នុងមួយអី?

**ឆ៖** មួយរដូវៗ សូមទោស មួយរដូវ មួយរដូវមួយហិកតា ទិន្នផលស្រូវឲ្យបានបីតោន។

[០៩:៤១:១២]

**ស៖** សូមលោកពេលៗ ខ្ញុំសួរចប់ សូមលោកបង្អង់បន្តិច។ តើលោកដឹងបញ្ហានេះដោយរបៀបណាដែរ?

**ឆ៖** បីតោននេះ នៅក្នុងវគ្គសិក្សាដែល សុន សេន គាត់បង្រៀនខ្ញុំ គាត់ក៏បីតោន ផ្សាយតាមវិទ្យុកម្ពុជាប្រជាធិបតេយ្យ ក៏បីតោន។ ហើយសំណៅដែលនិយាយ អំពីវគ្គសិក្សាមាន ដូចខ្ញុំបានជម្រាបហើយនៅក្នុងកំណត់ហេតុ ក.ណ.ហ ១៦៦។

**ស៖** តើលោកដឹងទេថា ព្រៃសកើតឡើងដំបូងគេនៅពេលណាដែរ?

**ឆ៖** ម្សិលមិញខ្ញុំបានជម្រាបថា ព្រៃសនេះវាជាកេរដំណែលរបស់ ណាត កងពល៧០៣។ ដូច្នេះ ព្រៃសនេះកើតមិនឆ្ងាយអំពី១៧ មេសា ប៉ុន្មានទេ ក្រោយភ្លាមហ្នឹងឯង។

**ស៖** ចុះប្រតិបត្តិការរបស់មន្ទីរម-១៣ វិញ តើយ៉ាងណាដែរ? សូមលោករៀបរាប់បន្តិចមក។

[០៩:៤២:៥២]

**ឆ៖** ខ្ញុំមុននឹង--

**ស៖** សូមៗបញ្ជាក់មន្ទីរម-១៣(ខ)។

**ឆ៖** អរគុណ។ មុននឹងឆ្លើយសំណួរលោកព្រះរាជអាជ្ញា ខ្ញុំសូមកែតម្រូវពាក្យមួយម៉ាត់ដែលខ្ញុំរាយការណ៍ម្សិលមិញ។ មិនមែនទាហានវត្តអង្គព្រលឹងទេ ខ្ញុំច្រឡំពាក្យ ទាហានវត្តអង្គតាឡឹក។ អង្គតាឡឹកនៅក្នុងដីខ្មាំង ដី លន់ នល់។ មន្ទីរ-១៣(ខ) នេះកើតឡើងក្រោយទេ។ ខ្ញុំជាស្នើសុំ វន វ៉េត បង្កើតមន្ទីរមួយដែលមានទីតាំងនៅភូមិស្តុកស្រោត ឃុំស្តុកគោល ស្រុកអង្គស្នួល វន វ៉េត អនុញ្ញាត។ ជាគោលការណ៍កុំឲ្យចូលទៅដល់ខាងក្នុង ឃើញខ្នោះ ឃើញច្រវាក់ មិនល្អទេ។ ហើយឲ្យមិត្ត ស៊ុំ អនុប្រធានរបស់ខ្ញុំហ្នឹងត្រួតត្រាមន្ទីរ-១៣(ខ)នេះផ្ទាល់ សម្រាប់តែឃុំឃាំងមនុស្សទុក។ ហើយមួយរយៈក្រោយមក តំបន់និងភាគ ត្រូវការដោះលែងៗ។ ពួកនេះអត់មាននេះទេ អត់មានដាក់ខ្នោះ ដាក់ច្រវាក់អីទេ។ មិត្ត ស៊ុំ គាត់ធ្វើរោងមួយវែង ហើយគាត់សុំលុយបក្សទៅទិញដែកគោល ទៅទិញមេគ្របយកមកវ៉ៃធ្វើជញ្ជាំង អារឈើ ឈើជ្រុង យកមកវ៉ៃធ្វើជញ្ជាំង។ អីចឹងទៅប្រហោងចន្លោះៗប៉ុណ្ណេះ ហើយគ្របហ្នឹងក៏ទំហំប៉ុនៗនេះដែរ។ ដាក់ឲ្យនៅនុ៎ង ថ្ងៃឡើងទៅនាំគ្នាទៅធ្វើដំឡូង គាត់អត់ទាន់ធ្វើស្រូវទេ គាត់ធ្វើដំឡូងមីនៅហ្នឹងភូមិនុ៎ង ភូមិស្តុកស្រោតហ្នឹង។ មន្ទីរនេះចាប់កំណើតនៅចុងឆ្នាំ៧២ អនុម័តពី វន វ៉េត ហើយធ្វើរៀបចំទីនេះនៅចុងឆ្នាំ៧២។ ហើយក៏មកបិទដោះលែងអ្នកដែលទៅឃុំឃាំងនៅនោះអស់តាមបញ្ជារបស់ សុន សេន នៅថ្ងៃ៣០ មេសា ១៩៧៥។ អ្នកទោស-- អ្នកដែលមានបញ្ហាយកទៅទុកក្នុងនោះ ចេះតែដោះលែងបណ្តើរ អ្នកចាស់ដោះលែងទៅ អ្នកថ្មីចូលមក។ នេះគោលនយោបាយជំនាន់នុ៎ង ក្នុងបញ្ហាមនុស្សដែលមានបញ្ហា តែមិនទាន់ប៉ានចាត់ទុកជាខ្មាំង។

**ស៖** បាទ សូមអរគុណ។ តើលោកបានដឹងទេថា ទាំងមុនរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យហ្នឹង តើបើប្រៀបធៀបទៅឃើញថាមានការដ្ឋានការងារ ឬក៏សហករណ៍ហ្នឹងមានលក្ខណៈខុសគ្នាដែរទេ?

[០៩:៤៦:២១]

**ឆ៖** មុន៧៥ មិនមានប្រជាជនថ្មី មានតែប្រជាជនចាស់នៅក្នុងមូលដ្ឋានបង្អែក។ នេះដែលខុសប្លែក និងក្រោយ១៧ មេសា បក្សយកប្រជាជនដែលសល់ពីសម្រិតសម្រាំងយកទៅទុកក្នុងសហករណ៍ឲ្យលត់ដំខ្លួនក្រោមការគ្រប់គ្រងរបស់ប្រជាជនចាស់។ នេះខ្ញុំឃើញសង្កេតឃើញខុសប្លែកហ្នឹង គឺច្បាស់អ៊ីចឹង។

**ស៖** តើលោកដឹងទេ បើគិតជាមធ្យមភាគនៅ-- មានមនុស្សប៉ុន្មាននាក់នៅក្នុងសហករណ៍នីមួយៗ? លោកអាចដឹងទេ?

**ឆ៖** ខ្ញុំក្តាប់មិនបានទេ ខ្ញុំក្តាប់មិនបាន។

**ស៖** ចុះលោកធ្លាប់សង្កេតឃើញទេ ទាក់ទងទៅនឹងរបបអាហារដែលផ្តល់ឲ្យអ្នកធ្វើការទាំងនោះ តើយ៉ាងម៉េចខ្លះដែរ?

[០៩:៤៧:៣៤]

**ឆ៖** ធម្មតារបបអាហារដូចខ្ញុំបញ្ជាក់មកហើយ នៅក្នុងប្រជាជន ទាំងប្រជាជនចាស់ទាំងប្រជាជនថ្មីអត់ប្លែកគ្នាទេ។ ប្រជាជនចាស់ក៏ដោយ ថ្មីក៏ដោយ កម្លាំងលេខមួយ មួយកំប៉ុងកន្លះ។ មនុស្សចាស់ទៅផ្សេង មនុស្សកុមារតូចៗទៅផ្សេងៗទៀត អាហ្នឹងចេះតែថយហើយ។ អ្នកដែលគេប្រមូលយកទៅវ៉ៃសម្រុក ទំនប់ ប្រឡាយ ប្រព័ន្ធភ្លឺ អាហ្នឹងគេឲ្យមួយថ្ងៃពីរកំប៉ុង។ ហ្នឹងក្នុងប្រជាជនរបបក្នុងប្រជាជន។ រឿងប្រជាជនចាស់ និងប្រជាជនថ្មីដែលខុសសំខាន់ គឺប្រជាជនថ្មីមិនអាចកសាងទៅជាកងឈ្លបភូមិ ឃុំ ឬក៏ឡើងថ្នាក់ទៅរៀនទៅសូត្រអីខាងជាមួយអីនឹងគេប្រជាជនចាស់ទេ។ ប្រជាជនចាស់គេចេះតែពង្រីកខ្លួនទៅជាសមាគមកសិករ ជាជនបង្គោល យូរទៅគេឡើងចូលបក្ស ហ្នឹងដែលខុសគ្នាសំខាន់ដែលខ្ញុំចាប់អារម្មណ៍បញ្ហាហ្នឹង។ អ៊ីចឹង សូមបញ្ចប់ប៉ុណ្ណេះ។

[០៩:៤៨:៤០]

**ស៖** ចុះទាក់ទងទៅនឹងអនាម័យ តើមានកម្រិតយ៉ាងណាដែរ? លោកបានដឹងទេនៅពេលនោះ?

**ឆ៖** សរុបមកបញ្ហាអនាម័យ ដូចជា ខាងលើគិតគូរត្រឹមតែកម្រិតក្រោយមកទេ ឃើញគិតគូរត្រឹមតែកម្រិតកម្ចាត់ជំងឺគ្រុនចាញ់។ ឯចំណែករឿងអនាម័យទឹកស្អាត ទឹកដាំអីៗ ខ្ញុំមិនទាន់ប៉ានថាយ៉ាងម៉េចទេ។ មិនបានជាចាប់អារម្មណ៍ខ្លួនឯងគិតដល់នុ៎ងផង។

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងទៅនឹងសេវាពេទ្យ តើលោកដឹងទេថា មានសេវាពេទ្យសម្រាប់អ្នកធ្វើការនៅទីនោះដែរទេ?

**ឆ៖** ក្រោយ១៧ មេសា ពេទ្យសង្គមចាស់ជម្លៀសទៅទាំងអស់ ហើយខ្ញុំឃើញដុកទ័រមួយចំនួន ដូចខ្ញុំរាប់រៀបម្សិលមិញ សាស្ត្រាចារ្យមហាបរិញ្ញា ទិត ម៉ម វេជ្ជបណ្ឌិត រ័ត្ន គត់ ដែលខ្ញុំចាប់ទុកគាត់ជាបងធម៌របស់ខ្ញុំ ឃើញគេចាប់យកមកទាំងស្រស់ៗ។ ឯចំណែកពេទ្យដទៃទៀតរំសាយអស់ហើយ គ្មានសាលាពេទ្យ គ្មានមន្ទីរពេទ្យ គ្មានអីទេ អត់ទេ។ ក្រោយមក ឃើញមានចលនាមួយដាំថ្នាំខ្មែរ។ ហើយទិដ្ឋភាពអារឿងថ្នាំសម័យហ្នឹងវាឃើញ អត់តាំងពីដំបូងមកម្ល៉េះ តាំងពីសម័យសង្គ្រាម។ បើ តាម៉ុក វិញ គាត់ឃោសនាថា អាថ្នាំបារាំង វាធ្វើសម្រាប់អាកាសធាតុស្រុកវា យកមកប្រើស្រុកយើងមិនត្រូវ។ អាហ្នឹងគាត់ណែនាំអ៊ីចឹង។ នេះវាពិត។

[០៩:៥០:៥៦]

ឯចំណែក ជំនាន់នុ៎ង ឃើញមានទិញប៉េនីស៊ីលីនខ្លះ វីតាមីនសេខ្លះ យកទៅលាយ ហើយដាក់បញ្ចុកចូលទៅ-- សូមទោស វីតាមីនសេ គឺនីន មិនមែនប៉េនីស៊ីលីន-- គឺនីន យកទៅបញ្ចុកចូលដប ហើយដាក់ យកស្បោងផ្លាស្ទីករុំ យកកៅស៊ូកងហ្នឹងបិទ។ ហ្នឹងមួយបែប។ ហើយមួយបែបទៀត ជំនាន់នុ៎ងឃើញប្រឌិដ្ឋ ច្នៃប្រឌិដ្ឋប្រើទឹកដូងយកមកជំនួសសេរ៉ូម។

ដូច្នេះវាមាននិន្នាការមួយតាំងពីពេលនុ៎ងមក យកទឹកដូងទៅជំនួសសេរ៉ូម ទន្ទឹមហ្នឹងវាមាននិន្នាការមួយទៀត ធ្វើថ្នាំសម័យ តាមរបៀបអាយ។ ដល់ក្រោយមកឆ្នាំ១៩៧៦ រវាងខែ៧-- មើល៍ៗ ដូចខែ៥ មានចលនាមួយ ធ្វើថ្នាំសម័យដោយវិធីអាយ។ ឧទាហរណ៍ចង់ធ្វើម្សៅប៉េនីស៊ីលីន យកត្រឡោកទៅដុតយ៉ាងម៉េចទេ ទៅដុតនៅសៀមរាប។ រឿងនេះ ខ្ញុំជឿថាដឹងដល់ ប៉ុល ពត។ ប៉ុល ពត អនុញ្ញាត ព្រោះមន្ទីរសេនាធិការវានៅក្រោមការគ្រប់គ្រងផ្ទាល់របស់ សុន សេនទេ។ មន្ទីរសេនាធិការបញ្ជូនមនុស្សទៅរៀន ក្នុងនុ៎ងប្រពន្ធខ្ញុំទៅរៀនមួយ។ អ៊ីចឹងហើយបានខ្ញុំជឿថា ពេលហ្នឹងវាមានលក្ខណៈប្រឌិដ្ឋអ៊ីចឹង។

[០៩:៥២:២៣]

សរុបមកឃើញលុបបញ្ហាហ្នឹងទៅវិញ តាមល្បីគេថាចិនជួយមតិមិនឲ្យធ្វើអ៊ីចឹង។

ខ្ញុំនិយាយត្រឡប់ទៅខាងដើមវិញ សំណួរលោកព្រះរាជអាជ្ញា គឺសេវាកម្មសុខាភិបាលអស់ហើយ។ លុបចោលទាំងអស់ ប្រមូលពេទ្យទៅស្រែ ចុះឲ្យច្រូតស្រូវ ចុះឲ្យជាប់ការបង្កើនបង្កស្រូវ។ ខ្ញុំសូមចប់។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាជាតិ សូមលោកគិតឡើងវិញ ហើយផ្តង់នូវការសួរដេញដោល

ឲ្យស្របទៅនឹងឧបសម្ព័ន្ធ E124/2.2 ដែលអង្គជំនុំជម្រះបានកំណត់យកមកធ្វើសវនាការ សម្រាប់ដំណាក់កាលដំបូងនៃកិច្ចដំណើរការសវនាការ ដែលពាក់ព័ន្ធទីមួយ ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ពីកថាខណ្ឌ ១៨ ដល់៣២។ ពីរ រចនាសម្ព័ន្ធរដ្ឋបាល ដែលមានពាក់ព័ន្ធនឹងបក្សកុម្មុយនីស្តកម្ពុជា ក្រោយឆ្នាំ១៩៧៥ គណៈកម្មាធិការមជ្ឈិម គណៈកម្មាធិការអចិន្ត្រៃយ៍ មន្ទីរ៨៧០ រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន ហើយនិងតួនាទីមុខងាររបស់ជនជាប់ចោទ ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល ហើយនិងទំនាក់ទំនងការងារ។

[០៩:៥៣:៤៧]

នេះជាលំហូរនៃកិច្ចដំណើរការពិភាក្សាដេញដោល ឲ្យចំទៅអង្គហេតុ ដែលអង្គជំនុំជម្រះបានកំណត់ ដែលកំណត់ថា សំណុំរឿង០០២/០១ ហើយចាប់ផ្តើមពី អង្គហេតុចោទប្រកាន់វគ្គមួយ វគ្គពីរ ហើយនឹងអាចវគ្គបន្តបន្ទាប់ទៀតនៅក្នុងក្របខ័ណ្ឌនៃអង្គហេតុ ដែលអង្គជំនុំជម្រះបានកំណត់នៅក្នុងសំណុំរឿង ០០២/០១។ ប្រសិនបើធ្វើតាមលំដាប់លំដោយលំហូរនៃដំណើរការនីតិវិធី ដែលទៅតាមបរិបទនៃអង្គហេតុដែលបានចោទប្រកាន់នៅក្នុងបណ្តាកថាខណ្ឌ នៅក្នុងដីកាដំណោះស្រាយ ដូចអង្គជំនុំជម្រះបានកំណត់នោះ នឹងមិនមានភាពច្របូកច្របល់ទេ ហើយនិងមិនមានភាពច្រំដែលទេ ហើយចំនឹងគោលដៅ និងបំណងនៃកិច្ចដំណើរការសវនាការនេះ។

បញ្ហាមួយទៀត អង្គជំនុំជម្រះសូមរំឭកលោកថា នៅក្នុងអនុស្សរណៈចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E124 ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង ត្រង់កថាខណ្ឌ៧។ អង្គហេតុពាក់ព័ន្ធនឹងសហករណ៍ ការដ្ឋាន មន្ទីរសន្តិសុខ កន្លែងសម្លាប់ ឬអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទីបី នឹងមិនត្រូវបានលើកយកមកដេញដោលនៅក្នុងដំណាក់កាលជំនុំជម្រះលើកដំបូងនេះទេ។ នេះការពាក់ព័ន្ធទៅនឹងគោលបំណងនៃលោកព្រះរាជអាជ្ញាបានបង្ហាញថា នឹងសួរដេញដោលបន្តបន្ទាប់នូវអង្គហេតុសហករណ៍ ការដ្ឋាន អាពាហ៍ពិពាហ៍ដោយបង្ខំ។ នៅក្នុងដីកាទាំងអស់នេះ អង្គជំនុំជម្រះបានកំណត់យ៉ាងជាក់ច្បាស់។ ដូច្នេះ អង្គជំនុំជម្រះសង្ឃឹមថា លោកតំណាងសហព្រះរាជអាជ្ញា ហើយនិងភាគីផ្សេងទៀតដែលពាក់ព័ន្ធនៅក្នុងកិច្ចពិភាក្សានេះនឹងប្រឹងប្រែងរៀបចំ នូវការតាំងសំណួរដេញដោលចំពោះជនជាប់ចោទក្តី ចំពោះសាក្សីក្តី អ្នកជំនាញ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកម្រិតនៃអង្គហេតុដែលអង្គជំនុំជម្រះបានជម្រាបជូន។

[០៩:៥៦:១៤]

ក្នុងករណីដែលសួរ ក្រៅពីអង្គហេតុនៅក្នុងសំណុំរឿង ០០២/០១ លុះត្រាតែភាគីសួរឲ្យចប់នូវបញ្ហានៅក្នុងសំណុំរឿង ០០២/០១ សិន ហើយប្រសិនបើចង់លាតចេញក្រៅពីនេះ ភាគីដែលមានបំណងចង់សួរពីបញ្ហាផ្សេងទៀតនោះ ត្រូវសូមការអនុញ្ញាតពីអង្គជំនុំជម្រះជាមុន ដើម្បីអង្គជំនុំជម្រះសម្រេចឲ្យ ឬក៏មិនសម្រេចវាអាស្រ័យទៅលើករណីនៃគោលដៅដែលត្រូវសួរ ថាតើលទ្ធភាពរបស់គាត់ក្នុងការមកផ្ដល់សក្ខីកម្មលើកទីពីរនេះ វាជាការល្អ វាអាចប្រព្រឹត្តទៅបានដែរឬក៏អត់?

ដោយអង្គជំនុំជម្រះស្ដាប់នូវការពិភាក្សាដេញដោលនេះ ហាក់ដូចជាមានភាពច្របូកច្របល់ ហើយមិនចូលនៅក្នុងអង្គហេតុដែលបានបង្ហាញនៅក្នុងដីកាដំណោះស្រាយដូចជម្រាបនេះទេ។ សង្ឃឹមថា តំណាងសហព្រះរាជអាជ្ញានឹងគិតគូរពិចារណាអំពីបញ្ហានេះឲ្យបានល្អ។

[០៩:៥៧:១៥]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមគ្រាន់តែបញ្ជាក់អំពីបញ្ហានេះថា អ្វីដែលបានលើកឡើងអម្បាញ់មិញនេះ គឺជាអ្វីដែលពាក់ព័ន្ធទៅនឹងគោលនយោបាយតែប៉ុណ្ណោះ។ ហើយជាបន្តទៀត ខ្ញុំនឹងសួរសំណួរបន្តទៀតទៅលោក កាំង ហ្កេកអ៊ាវ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ តើលោកដឹងទេអំពីថាតើគោលនយោបាយទាំងអស់នេះ ដែលលោកបានរៀបរាប់មុនហ្នឹង វាមានភាពស៊ីសង្វាក់គ្នាជាមួយទៅនឹងមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្ដកម្ពុជា ហើយនិងគោលនយោបាយផ្សេងៗទៀតរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែរទេ?

[០៩:៥៨:០១]

**ឆ៖** គោលនយោបាយធំមួយរបស់បក្សកុម្មុយនីស្ដកម្ពុជាផ្សព្វផ្សាយយូរហើយ ជាពិសេសក្រោយ ១៩៧០ គឺគោលនយោបាយឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន។ ធ្វើសហករណ៍ក៏ក្នុងឋានៈខ្លួនទីពឹងខ្លួន។ បង្កើតថ្នាំបុរាណ ការប្រើប្រាស់ថ្នាំបុរាណក៏ខ្លួនទីពឹងខ្លួន។ កសាងកងទ័ពក៏ខ្លួនទីពឹងខ្លួន។ នេះវាគោលនយោបាយធំវា-- គោលនយោបាយហ្នឹងជាសំខាន់ មួយ។

**ស៖** បាទ សូមអរគុណ។ ហើយជាបន្តទៅទៀតនេះ ខ្ញុំនឹងលើកឡើងអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្ដកម្ពុជា ដែលទាក់ទងទៅនឹងការកំណត់មុខសញ្ញាខ្មាំងរបស់បក្ស និងគោល

នយោបាយផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងក្រុមជនជាតិភាគតិច និងអ្នកប្រតិបត្តិការសាសនាផ្សេងៗនៅក្នុងប្រទេសកម្ពុជា។ លោក កាំង ហ្គេកអ៊ាវ លោកបានជម្រាបជូនអង្គសវនាការរួចហើយអំពីតួនាទីរបស់លោកដែលជាប្រធាន ម-១៣ នៅក្នុងមុនខែ នៅមុនខែមេសា ឆ្នាំ១៩៧៥ ហើយនិងជាប្រធានមន្ទីរ ស-២១ នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។

[០៩:៥៩:៣១]

តើអំឡុងពេលដែលលោកបំពេញការងារនៅមន្ទីរសន្តិសុខទាំងនេះ តើលោកបានដឹងទេថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់ថានរណាខ្លះជាមុខសញ្ញាខ្មាំងរបស់បក្ស?

**ឆ៖** ក្នុងការប្រតិបត្តិជាក់ស្តែងដំបូងនិយាយពីគិញ គិញគឺសរុបរួមតែម្តង បក្សណែនាំឲ្យសរុបរួម បក្សអនុវត្តសរុបរួម ឲ្យតែចូលតំបន់រំដោះ គឺគិតថាជាខ្មាំង ដោយការពុះពារបែងចែក អ្នកណាមែនមិនមែននេះហើយ បានជាមានព្រឹត្តិការណ៍អ្នកជាប់ឃុំឃាំងវាយគុករត់ នេះមួយ។ ហើយនិងការបំបែកមន្ទីរ-១៣ នេះ ឲ្យទៅជា ១៣(ក) និង១៣(ខ)។ ដូច្នេះបក្សកំណត់ខ្មាំង ទីមួយ គឺអ្នកណាចូលតំបន់រំដោះ គឺចាត់ទុកជាគិញ។ ទីពីរ ខ្ញុំបានជម្រាបម្សិលមិញ ថាក្រោយទម្លាក់គ្រាប់បែកបេ-៥២ តាម៉ុកចាប់មនុស្សនៅក្នុងមូលដ្ឋានបង្អែក មិនមែនមកពីក្រៅទេ យកមកឲ្យម-១៣ សួរចម្លើយ។ អ្នកដែលគាត់គិតថា ផ្តល់ព័ត៌មានទីតាំងមន្ទីរភូមិភាគនិរតី គឺអ្នកកូនចៅចិនម្នាក់ ដែលមានការជាប់ទាក់ទងជាមួយនឹងមេប៉ូលិស លន់ នល់ សំខាន់ម្នាក់ យកមកឲ្យម-១៣ សួរចម្លើយ ហើយក៏បែកសាយជា *(ឮមិនច្បាស់)* អស់ប្រជាជនមូលដ្ឋានប្រហែលជា៥០នាក់។ នេះមុខសញ្ញាខ្មាំងទីពីរដែលកំណត់។ ហើយក្រោយមកនេះ វាមានរឿងទាហាននៅវត្តអង្គតាឡឹក បាញ់គ្នាពព្រុសប៉ប្រះ មួយចំនួនរត់ចូលមកតំបន់រំដោះ។ គាត់តាមដានមួយសន្ទុះ គាត់ប្រគល់មកឲ្យម-១៣ សួរចម្លើយ ហើយកម្ទេច។ គាត់នេះ គឺ វនវេត។ ហ្នឹងកំណត់មុខសញ្ញាខ្មាំង គឺអ៊ីចឹង។

[១០:០២:០៤]

**ស៖** បាទ ខ្ញុំសូមកាត់លោកបន្តិច ចំណុចនេះលោកបានជម្រាបជូនអង្គសវនាការរួចហើយ។

**ឆ៖** បាទ។

**ស៖** ពីករណីហ្នឹង តែចង់បានថា ការកំណត់មុខសញ្ញាខ្មាំង គោលនយោបាយរបស់បក្សក្នុងការកំណត់មុខសញ្ញាខ្មាំងជាក់លាក់ តើមានកំណត់ជាក់លាក់ថា ខ្មាំងប្រភេទនេះយ៉ាងម៉េចៗ ជាមនុស្សដែលចាត់ទុកថាជាខ្មាំងដែរទេ?

**ឆ៖** អរគុណ។ ខ្ញុំសូមរម្លឹកឡើងវិញ អំពីទស្សនាវដ្ដីទង់បដិវត្តឆ្នាំ១៩៧៣។ ពេលនោះ និយាយអំពីវណ្ណៈពិសេសៗហ្នឹងពីរ វណ្ណៈពិសេសទីមួយគឺទាហាន និងប៉ូលិស។ ក្នុងទស្សនាវដ្ដីទង់បដិវត្តណែនាំថា-- ពន្យល់ថា មិនមែនណែនាំទេ ពន្យល់ថា "ទាហាន និងប៉ូលិស ជាវណ្ណៈពិសេស ព្រោះវាកាន់កាំភ្លើងខ្លាំងមកសម្លាប់ប្រជាជនយើង"។ វណ្ណៈពិសេសទីពីរ គឺលោកសង្ឃ។ លោកសង្ឃឃោសនាសណ្ដំប្រជាជន មិនមែន មិនប្រើ-- កាលណោះដូចមិនប្រើពាក្យសណ្ដំផង មកយកលទ្ធិកម្មផល មកធ្វើឱ្យប្រជាជនយើងស្ពឹកស្រពន់ មិនងើបឡើងតស៊ូ។ ក៏ប៉ុន្តែកុំភ្លេច ពុទ្ធសាសនានៅស្រុកខ្មែរមិនជ្រៅទេ លោកសង្ឃជាកូនចៅកសិករ ក្រពះលោកសង្ឃផ្ញើនឹងឆ្នាំងបាយកសិករ។ ដូច្នេះលោកសង្ឃរណបកសិករទាំងនយោបាយ ទាំងសេដ្ឋកិច្ច។ កសិករឱ្យងាប់ ងាប់ កសិករឱ្យរស់ រស់ ហ្នឹងកំណត់អ៊ីចឹង។ នេះផ្ដល់ជាទស្សនៈប៉ុណ្ណឹង។ អ្នកអាន អ្នកសិក្សាគ្រាន់តែបានក្ដាប់ទស្សនៈវណ្ណៈបែបនេះ ដល់ក្រោយមក ១៧ មេសា បានវាឃើញច្បាស់ក្នុងការអនុវត្តមាគ៌ានេះ។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

[១០:០៤:១៥]

**ស៖** តើគោលនយោបាយរបស់បក្សមានកំណត់ថា ក្រុមជនជាតិភាគតិច ឬក៏ក្រុមណាជាសត្រូវរបស់បក្សដែរទេ?

**ឆ៖** គ្មានទេ អត់មានកំណត់អ៊ីចឹងទេ។ តែក្នុងការអនុវត្តជាក់ស្ដែងយើងខ្ញុំចេះតែឮតាមគ្នាមក បក្សជឿទុកចិត្តជនជាតិភាគតិចនៅព្រៃសាន យកមកធ្វើកងការពារ យកមកធ្វើស្អីៗហ្នឹង។ ខ្ញុំជឿអ៊ីចឹង។ ដូច្នេះឱ្យកំណត់ក្នុងឯកសារមិនឃើញមាន។

[១០:០៥:០៦]

**ស៖** ចុះក្រៅពីជនជាតិភាគតិចដែលលោកថា នៅព្រៃសាន តើមានជនជាតិភាគតិចដែលជា-- កាន់សាសនាអីនៅៗក្នុងប្រទេសកម្ពុជាហ្នឹង? តើគោលនយោបាយរបស់បក្សហ្នឹងមានកំណត់ពីបញ្ហាហ្នឹងដែរទេ?

**ឆ៖** បញ្ហានេះ វាមានការសង្កេត ហើយនិងវាមានការដឹង។ អង្កាល់ដែលខ្ញុំជាប់គុកឆ្នាំ១៩៦៩ នៅគុកធំ ខ្ញុំបានជជែកគ្នាជាមួយនឹងបក្ខជនជើងចាស់ម្នាក់-ពីរ។ បក្សទុកចាមជាជនជាតិភាគតិច បក្សមានគោលនយោបាយប្រមូលចាម។ នៅក្នុងជួរបក្សមានបុគ្គលពីរនាក់ដែលសំខាន់ គឺបង ម៉ាត់ លី ហើយនិង តាម៉ាន នេះកាលដែលដឹង។ ដល់ខ្ញុំចេញមកវិញក្នុងឆ្នាំ១៩៧១ ខ្ញុំឮថា សុះ ម៉ាត់ ទៅធ្វើទាហានឱ្យ លន់ នល់ យាមកំណាត់ផ្លូវលេខ៥ ពីឧដុង្គទៅលង្វែក។ អនុសេនាធំគាត់ឈ្មោះ អនុសេនាធំ

ស្រះស្រង់។ ខ្ញុំថា យេ! ម៉េចអ៊ីចេះបក្ស! បែបមិនប្រមូលចាមទេដឹង បានជានៅក្នុងជួរដូចមិនឃើញមានចាមណាថ្មីៗមកធ្វើបដិវត្តទៀតសោះ ហើយ សុះ ម៉ាត់ ទៅធ្វើទាហាន។ ដល់ក្រោយមក ពេលដែលខ្ញុំធ្វើ ស-២១ ខ្ញុំសួរចម្លើយ ទៅប៉ះកូនចៅចាម ដែលគេចាប់យកមក។ មេណែនាំខ្ញុំ ថាមិត្តមើលមើល៍ តើជាខ្មែរ សុខ អតីតលេខាកងពល៧០៣ហ្នឹង ឬក៏ជាខ្មែរចាម?

ដូច្នេះ ដំណើរបានប៉ុណ្ណឹង ដែលខ្ញុំសង្កេតអំពីការ-- គោលនយោបាយរបស់បក្សចំពោះចាម។

[១០:០៧:៣៧]

**ស៖** ចុះគោលនយោបាយរបស់បក្សទាក់ទងទៅនឹងមន្ត្រី ឬទាហានអី របបមុនៗ តើមានទាក់ទងនឹងបញ្ហាហ្នឹងដែរទេ?

**ឆ៖** ខ្ញុំបានជម្រាបបន្តិចម្សិលមិញ។ មាគ៌ាជាយុទ្ធវិធីប្រមូលកម្លាំងរណសិរ្សធំទូលាយ ឲ្យបែងចែកខ្មាំងជាបីប្រភេទ។ ប្រភេទល្អ អូសទាញ ប្រភេទមធ្យម អព្យាក្រឹត ហើយនិងប្រភេទឃោរឃៅរឹងរូស កម្ទេច។ នេះជាគោលនយោបាយដែលមាន។ ដូច្នេះ ខ្ញុំមិនបញ្ចាំងផ្ទុះទៅលើការអនុវត្តក្រោយ ១៧ មេសា ទេ។

**ស៖** បាទ សូមអរគុណ។ តើមនុស្សដែលបក្សចាត់ទុកថា ជាខ្មាំងហ្នឹង គេបញ្ជូនទៅណាដែរ?

**ឆ៖** ខ្ញុំរស់នៅក្នុងសន្តិសុខ ម-១៣ ហើយនិង ស-២១ រង់ចាំតែភារកិច្ច គឺត្រូវរង់ចាំមនុស្សណាដែលបក្សសម្រេចថាខ្មាំង បញ្ជូនមកឲ្យវ៉ៃសួរចម្លើយប៉ុនន៉ុង។ តែបក្សសម្រេចបញ្ជូនមកហើយ គឺខាងសន្តិសុខគ្នាត្រូវតែធ្វើហើយ ឲ្យរួចមិនបានទេ។

**ស៖** តើលោកដឹងគោលនយោបាយនេះដំបូងគេនៅពេលណាដែរ? លោកអាចបញ្ជាក់បានទេ?

**ឆ៖** គោលនយោបាយអី? គោលនយោបាយក្នុងការនគរបាលកម្ទេចខ្មាំង?

**ស៖** គោលនយោបាយរបស់បក្សក្នុងការកំណត់មុខសញ្ញាណាជាមុខសញ្ញាខ្មាំងរបស់បក្ស?

[១០:០៩:៤៧]

**ឆ៖** គោលនយោបាយកំណត់ថា គិញនេះ វាជាគោលនយោបាយចាស់ តាំងពីសម័យឥស្សរៈមកម៉្លេះ។ ដូចខ្ញុំបានឧទាហរណ៍ជូនម្សិលមិញហើយ ហើយសម័យឥស្សរៈហ្នឹងខ្ញុំសូមលើឧទាហរណ៍ភស្តុតាងមួយទៀត នៅខាងស្អាងកោះធំ ជាពិសេសនៅកោះធំ មានមេនគរបាលម្នាក់ជើងចាស់ឈ្មោះ ឡេង បាវ។ ខ្ញុំចូលទៅឆ្នាំ៧១ ឡេង បាវ នៅរស់ទេ។

**ស៖** បាទ សូមអរគុណ។ សូមលោកបញ្ជាក់សង្កត់ធ្ងន់ទៅលើ បន្ទាប់ពីឆ្នាំ១៩៧៥ មក?

**ឆ៖** បន្ទាប់ពីឆ្នាំ១៩៧៥ ខ្ញុំឃើញភស្តុតាងនៅហ្នឹងបញ្ជីកម្មេចរបស់ស-២១ ដែលសម័យ ណាត មួយជម្លៀស សុទ្ធតែខ្មែរ ឡុង បងប្អូន ឡុង បូរ៉េត។ ហើយប្អូននាក់ ម្នាក់ជាប្រពន្ធ ថាច់ ជា ហើយបីនាក់ទៀតជាកូន ថាច់ ជា ហើយក្រៅពីនោះ ដូចខ្ញុំបានជម្រាបលោកព្រះរាជអាជ្ញាអ៊ីចឹង ពួកដុកទ័រ ពួកអីសុទ្ធតែចូលមកអស់រលីង។ មុនខ្ញុំមកកាន់ការជាប្រធានស-២១ មន្ទីរនគរបាលហ្នឹងវាសម្រិតសម្រាំងសមាសភាពសង្គមចាស់របស់ លន់ នល់ នាម៉ឺនចាស់ ទាហានចាស់ ប៉ូលិសចាស់ ហើយនិងពួកមូស្លីមនៅភូមិអារ៉ាប់ ហើយនិងពួកថៃដែលមកនេសាទ។ នេះវិភាគតាមបញ្ជី។ ក្រោយមក ស-២១ នៅក្នុងកណ្ដាប់ដៃខ្ញុំទៅផ្សេង គឺសំដៅផ្ទៃក្នុងដែលមានបាតុភាព កុយ ធួន អ៊ីចឹង ឬក៏ យឹម សម្បត្តិ ហើយនិងមនុស្សដែលគេឆ្លើយដាក់ ហើយបក្សសម្រេចឲ្យទៅចាប់។

[១០:១២:១៦]

**ស៖** សួរថាតើលោកដឹងបញ្ហាទាំងអស់នេះដោយយ៉ាងណាដែរ?

**ឆ៖** ក្រោយ១៧ មេសា ខ្ញុំទៅធ្វើអនុប្រធាន ស-២១ បញ្ជីនៅនុំង ហើយការងារដែលខ្ញុំសួរចម្លើយក៏នៅនុំង ខ្ញុំធ្វើជាអ្នកសួរចម្លើយ បង្រៀនគេសួរចម្លើយ។ ណាត ចាត់តាំងឲ្យខ្ញុំទៅបង្រៀនសួរចម្លើយ ដូច្នេះឃើញជាក់ស្ដែងនៅហ្នឹង។ ហើយក្រោយមក ខ្ញុំកាន់កាប់កិច្ចការហ្នឹង ខ្ញុំនឹងមេទាក់ទងគ្នាជាប់រាល់ថ្ងៃ។ បើជាមួយ សុន សេន រាល់ថ្ងៃតាមទូរស័ព្ទ បើជាមួយពូ នួន ពីរបីថ្ងៃគាត់ហៅទៅម្ដង។

**ស៖** មុននេះបន្តិច ខ្ញុំឮលោកនិយាយពីឈ្មោះ ឡុង បូរ៉េត, ថាច់ ជា។ តើ ឡុង បូរ៉េត, ថាច់ ជា ហ្នឹងជាអ្នកណា? ជាមន្ត្រីខាងណាដែរ?

**ឆ៖** ប្រវត្តិសាស្ត្រមានច្បាស់ហើយ ឡុង បូរ៉េត គាត់នាយករដ្ឋមន្ត្រីរបស់ លន់ នល់ ហើយដូចជាប់នៅក្នុងក្រុមមហាក្បត់ប្រាំពីរនាក់ហ្នឹងផង។ ឯចំណែក ថាច់ ជា គាត់ជាសាស្ត្រាចារ្យមធ្យមសិក្សា ដល់ក្រោយមកគាត់ឡើងជារដ្ឋលេខាធិការក្រសួងសិក្សាធិការ ត្រូវពួកណាទេ បក្សពួកហ្នឹង មិនដឹងជាពួកណា ប៉ុន្តែឈ្មោះ សាល សុន ដឹកនាំបាតុកម្មសិស្សវ៉ៃ គាត់សម្លាប់។ ថាច់ ជា ក៏ស្លាប់ កែវ សាំងគីម ជារដ្ឋមន្ត្រីក្រសួងសិក្សាធិការហ្នឹងក៏ស្លាប់។ ដូច្នេះ ថាច់ ជា ហ្នឹងគាត់ជារដ្ឋលេខាធិការក្រសួងសិក្សាធិការរបស់ លន់ នល់។

[១០:១៤:៣៩]

**ស៖** បាទ អរគុណ។ តើលោកដឹងទេអំពីគោលនយោបាយនេះ នៅក្នុង ម-១៣ ហើយនិង ស-២១ តើវាមានលក្ខណៈដូចគ្នា ឬខុសគ្នាយ៉ាងម៉េចដែរ?

**ឆ៖** ដែលដូចគ្នា គឺអ្វីដែលបក្សកំណត់ថាជាខ្មាំង ត្រូវតែកម្ទេច ត្រូវតែដាច់ខាត នេះដូចគ្នា។ សម្រាប់ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាគឺអ៊ីចឹង អត់ប្រកែកទេ។ ហើយតែបក្សកំណត់ថាខ្មាំងហើយ គឺបាត់ហើយ ដោះស្រាយមិនបានទេ ត្រូវតែកម្ទេច។ ខ្ញុំបានជូនឧទាហរណ៍ហូរហែច្រើនដែរ នៅក្នុងសំណុំរឿងលេខ០០១ ដែលខ្ញុំទាមទារយ៉ាងនេះ ទាមទារយ៉ាងនោះ។ ខ្ញុំសូមមិនរំឭកលើកយកមកនិយាយវិញទេ នេះដែលដូចគ្នាសុទ្ធសាធ។ ក៏ប៉ុន្តែ ដែលប្លែកគ្នាពីមួយរយៈទៅមួយរយៈ គឺសមាសភាពដែលកំណត់ថាខ្មាំង។

ក្រោយឆ្នាំ១៩៧០ "គិញ" កំណត់គិញជាធំ។ ក្រោយឆ្នាំ១៩៧៥ កំណត់យកអតីតមន្ត្រីរាជការ និងអតីតទាហានប៉ូលិសរបស់ លន់ នល់ ជាធំ ហើយដល់ក្រោយឆ្នាំ១៩៧៦ ពីខែ-- ជាពិសេសនិយាយពីខែមួយ ឆ្នាំ១៩៧៧ ដែលបោសសម្អាត សម្រិតសម្រាំងកម្លាំងខាងឧត្តររបស់ កុយ ធួន។ ផ្ទៃក្នុងសុទ្ធសាធហើយនុ៎ង។ ដំបូង កុយ ធួន បន្ទាប់មកខាងបស្ចិម បន្ទាប់មកខាងបូព៌ា ខាងពាយ័ព្យ ចុងបញ្ចប់អស់កងទ័ពរលីង។

[១០:១៦:៥៦]

**ស៖** អរគុណ។ សូមលោកជួយបញ្ជាក់ឲ្យបានច្បាស់បន្តិចទៀត អំពីការកំណត់អត្តសញ្ញាណខ្មាំងនេះ តើធ្វើឡើងដោយរបៀបណា? ហើយថាតើអ្នកណាជាអ្នកសម្រេចធ្វើយ៉ាងនេះ?

**ឆ៖** បើនិយាយចំពោះមុខ គ្រប់ពេលវេលាខ្ញុំបានទទួលការណែនាំពី សុន សេន។ នេះនិយាយអំពីសភាពការណ៍មុនថ្ងៃ១៥ សីហា ១៩៧៧ ហើយបន្ទាប់មកគឺបងទីពីរ នួន ជា នេះ យ៉ាងម៉េចៗ សម្រេចចាប់អ្នកណា មិនចាប់អ្នកណា គាត់ជាអ្នកសម្រេចពីខាងលើ។ ហ្នឹងកំណត់អ៊ីចឹង។ តែខាងលើកំណត់ហើយ ចប់។ ស-២១ ត្រូវតែអនុវត្តរង់ចាំចាប់អ្នកនេះ រង់ចាំចាប់អ្នកនោះ ខាងលើសម្រេច។

**ស៖** តាមអ្វីដែលលោកដឹង នៅពេលនោះ តើលោកដឹងទេថា គោលនយោបាយនេះ អនុវត្តទូទាំងប្រទេស ឬក៏អនុវត្តនៅតំបន់ណាមួយជាក់លាក់តែមួយទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកសហព្រះរាជអាជ្ញា បងទីមួយ ប៉ុល ពត និងបងទីពីរ នួន ជា គ្រប់គ្រងទូទាំងប្រទេស។

**ស៖** អរគុណ។ តើលោកដឹងទេថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង ថាតើមានមន្ទីរសន្តិសុខណាដែលមានលក្ខណៈស្រដៀងជាមួយនឹងមន្ទីរសន្តិសុខ ស-២១ ដែរទេ?

[១០:១៩:២០]

**ឆ៖** ខ្ញុំបានពន្យល់នៅក្នុងសំណុំរឿងលេខ០០១ រួចមកហើយ ថាមន្ទីរសន្តិសុខទាំង ១៩៦ នេះ បក្សឲ្យសារៈសំខាន់ទៅលើសេចក្ដីសារភាព។ សេចក្ដីសារភាពណាដែលសំខាន់ចាំបាច់ មកដល់បក្សឆាប់ណាស់ គឺមកដល់បង ប៉ុល បងទីមួយឆាប់ណាស់។ ឧទាហរណ៍ ខ្ញុំបានជួបមួយ គឺសេចក្ដីសារភាពចេញពីតំបន់៣២ ភូមិភាគនិរតី ដែលមានមិត្ត ណម-- ចាប ណម ជាលេខាតំបន់-- អ៎! ជាលេខាមន្ទីរផ្ញើមក។ សុន សេន យកបញ្ហាហ្នឹងទៅណែនាំខ្ញុំភ្លាម។ ភស្តុតាងមួយទៀត ថ្ងៃ១៧ មេសា ១៩៧៨ កង ចាប សរសេរលិខិតអមមួយជូនមកមជ្ឈិមបក្ស ពីរឿងខ្មាំងវាឆ្លើយដាក់ ខាំមី។ ថ្ងៃ១៩ មេសា បងទីពីរ នេះបានអានឯកសារហ្នឹងភ្លាម។ ព្រះរាជអាជ្ញាគិតមើលពី ជាំខ្សាន្តមកដល់ភ្នំពេញ ពីរថ្ងៃ។ ហើយអានហើយ គាត់សរសេរថា តាមដាន ខាំមី ឯកសារនៅសល់។ ខ្ញុំភ្លេចហើយ ដូចឯកសារប៉ុន្មានទេ ដូច៣២/ សូមទោស ខ្ញុំមិននិយាយលេខឯកសារទេ។ ខ្ញុំវង្វេងលេខ។ ដូច្នេះសារៈសំខាន់របស់មន្ទីរនគរបាលទាំង ១៩៦ គឺសេចក្ដីសារភាពរបស់អ្នកទោស។ តែបើកាលណាអ្នកទោសឆ្លើយហើយ វាជូនទៅលេខាស្រុក ឬក៏វាជូនទៅលេខាតំបន់ ឬក៏បញ្ជូនទៅលេខាភាគខាងលើ ហ្នឹងក៏ប្រញាប់ប្រញាល់ផ្ញើមកតាមនីរសារហើយ។

[១០:២១:២២]

នីរសារពីជាំខ្សាន្តរបស់ កង ចាប មកក៏មកដល់ ក-៧។ នីរសារពីបស្ចិមមកក៏មកដល់ ក-៧។ ក-៧ នេះជាមន្ទីរនីរសាររបស់មជ្ឈិមបក្ស។ នេះរបស់ដែលដូចគ្នា ខ្ញុំបានជម្រាបហើយ ឯរបស់ដែលប្លែកគ្នាក៏ខ្ញុំបានជម្រាបហើយ។

**ស៖** បាទ អរគុណ។ លោកបានជម្រាបថាមានមន្ទីរសន្តិសុខទាំងអស់ ១៩៦ តើលោកដឹងទេ ថាមន្ទីរសន្តិសុខទាំងនោះកើតឡើងមុន ឬក៏ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥?

**ឆ៖** ខ្ញុំពិបាកនិយាយណាស់។ មន្ទីរសន្តិសុខខ្លះខ្ញុំឃើញ តាំងពីថ្នាក់ ខែ១២ ឆ្នាំ១៩៧0 ដូចមន្ទីរសន្តិសុខ ម-១៥ របស់មិត្ត តេង នៅខាងតំបន់២៥។ មន្ទីរសន្តិសុខរបស់ភូមិភាគនិរតីតំបន់៣២ របស់មិត្ត តាំង ខែក នៅភូមិត្រពាំងជោរ កើតមុនខ្ញុំទៅទៀត។

ហើយមន្ទីរសន្តិសុខបង បេះ ក៏នៅរហូតដល់ឥឡូវ។ ដូច្នេះមន្ទីរសន្តិសុខទាំងអស់វាច្រើនបន្តមកអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដី នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

អរគុណច្រើនលោកប្រធាន។ ខ្ញុំគិតថាសាក្សីត្រង់ចំណុចជាក់លាក់មួយនេះ គឺកំពុងតែដកស្រង់នូវការស្រាវជ្រាវរបស់គាត់ទេ មិន-- ដូច្នេះ ខ្ញុំស្នើឲ្យសហព្រះរាជអាជ្ញាសួរឲ្យជាក់លាក់ទៅលើព័ត៌មានទាំងអស់នេះ។ ថាតើគាត់ទទួលបានព័ត៌មាននេះពីប្រភពណាដែរ? ថាតើវាជាចំណេះដឹងផ្ទាល់ខ្លួនរបស់គាត់ បានន័យថាអ្វីដែលគាត់ដឹងនៅពេលនោះ ឬក៏អ្វីដែលគាត់បានអាន។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សហព្រះរាជអាជ្ញាអនុវត្តតាមសំណើសុំរបស់លោកមេធាវីសួរបញ្ជាក់អំពីការដឹងរបស់ជនជាប់ចោទដែលឆ្លើយអម្បាញ់មិញនេះ។

[១០:២៤:០២]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន នេះហើយជាសំណួរដែលខ្ញុំនឹងសួរបន្តទៀតដែរបាទ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** អ៊ីចឹងសូមលោកជួយបញ្ជាក់មើលថាការដឹងរបស់លោកហ្នឹង ដឹងដោយរបៀបណាដែរ?

**ឆ៖** អរគុណ។ ខ្ញុំបានជម្រាបហើយថា ប្រវត្តិខ្ញុំធ្លាប់ទៅនៅស្អាងកោះធំ គេហៅថាតំបន់២៥។ នៅពេលដែលរដ្ឋអំណាចផ្ទេរពីតំបន់១២ មកតំបន់២៥ សុខ ប៊ុតចំរើន, ហួត សេ នេះចាត់តាំងមិត្ត តេងឈ្មោះដើម ម៉ឺង សំណាង ឲ្យធ្វើលេខាតំបន់ ន៎ែ ឲ្យធ្វើលេខាមន្ទីរនគរបាលហើយ នេះច្បាស់ គ្រាន់តែខ្ញុំមិនដឹងថាមន្ទីរនគរបាលនេះឈ្មោះស្អី? ដល់ក្រោយមក ណាត យកឯកសារមួយចំនួនមកឲ្យខ្ញុំ។ នេះនៅពេលដែលខ្ញុំធ្វើអនុលេខាហើយ បានដឹងថា ឱ! មន្ទីរមិត្ត តេង ហ្នឹងឈ្មោះមន្ទីរ១៥។ ឯកមន្ទីររបស់មិត្តតាំង ខែក ហៅ ខាន់ នៅត្រពាំងជោរ ខ្ញុំទៅមិនទាន់បានទទួលការងាររបស់ជាប្រធានមន្ទីរ១៣ ផងខ្ញុំជួបនឹង តាំង ខែក នៅឃុំពាម។ តាំង ខែក ហើយនិងខ្ញុំធ្លាប់ស្គាល់គ្នា។ ដល់ទៅមិត្ត តាំង ខែក ប្រាប់ថា ខ្ញុំគេឲ្យធ្វើនគបាល។ ដូច្នេះរឿងនេះ វាជាក់ស្តែង ខ្ញុំ ហើយនិង តាំង ខែក ធ្លាប់គ្នា ហើយក៏បានជួបគ្នានិយាយគ្នាអ៊ីចឹង។ ធ្លាប់បញ្ជូនមនុស្សពី-- ធ្លាប់គេបញ្ជូនមនុស្សពីនុ៎ងមក។ ឯចំណែកមន្ទីររបស់មិត្តណម, ចាប ណម នេះតំបន់៣២ ជាមន្ទីរនគបាលមួយដែរ ប្លែកពីរបស់មិត្ត តាំង ខែក។ ខ្ញុំមិនស្គាល់ចាប ណម ទេ ក៏ប៉ុន្តែមេខ្ញុំ លោកគ្រូ សុន សេន យកសេចក្តីឆ្លើយរបស់មនុស្សម្នាក់យកមកទិតៀនខ្ញុំ ថា "ស-២១ ម៉េចក៏មិនរកមិនឃើញ សេ.អ៊ី.អា? ខាងតំបន់៣២ គេរកឃើញណ៎ា នេះ មេនគបាលគេ

ឈ្មោះ ចាប ណម"។ នេះវាជារឿងដំណើរការរួចមកហើយ។ ខ្ញុំក៏បាននិយាយបញ្ហានេះច្រើនដងដែរ នៅក្នុងសំណុំរឿងលេខ០០១។ នេះសូមបញ្ជាក់បញ្ចប់ប៉ុណ្ណឹង។

[១០:២៦:២៣]

**ស៖** ទាក់ទងនឹងមន្ទីរសន្តិសុខដែលលោកបានជម្រាបជូនអង្គសវនាការអម្បាញ់មិញថា មន្ទីរសន្តិសុខមាន១៩៦ ហ្នឹង តើលោកដឹងដោយយ៉ាងណាដែរ?

**ឆ៖** ខ្ញុំបានធ្វើសេចក្តីសរុបមួយ មន្ទីរសន្តិសុខទូទាំងប្រទេសជូនសហចៅក្រមស៊ើបអង្កេត។ ខ្ញុំគ្មានការយល់ដឹងទេ ដល់ប៉ុណ្ណឹងទេ ដល់ក្រោយមក ពេលដែលខ្ញុំមកធ្វើ ពេលដែលខ្ញុំកំពុងតែឆ្លងកាត់សវនាការអង្គជំនុំជម្រះ ទើបបានខ្ញុំឃើញ។ ឯកសារពិតប្រាកដរបស់ការិយាល័យសហចៅ-- អំព្រះរាជអាជ្ញាហ្នឹង។ មន្ទីរសន្តិសុខទាំងអស់១៩៦។

**ស៖** តើលោកដឹងទេថាអ្នកទោសដែលចាប់បញ្ជូនមកមន្ទីរសន្តិសុខហ្នឹង គេចាប់ពីណាមកលោក?

**ឆ៖** មន្ទីរសន្តិសុខផ្សេងៗ ខ្ញុំសូមនិយាយអំពីមន្ទីរ១៣។ មន្ទីរ១៣នេះ ខាងភូមិភាគនិរតីមើលទៅអ្នកណាសំខាន់ក៏គេបញ្ជូនមក ម-១៣ ឲ្យសួរដែរ។ ខាងភូមិភាគពិសេសក៏មកដែរ។ ដោយឡែកពេលដែលខ្ញុំចូលមកធ្វើជាអនុប្រធាន ស-២១ នោះ ខ្ញុំឃើញ ណាត គាត់ដើរទាក់ទងសុំគេសុំឯងដំបូង ដល់ក្រោយមកគេបញ្ជូនពីស្អាង កោះធំ ពីខាងណាៗមកឲ្យ ណាត។ ដល់ក្រោយមកទៀត ពេលដែលខ្ញុំនៅក្រោមការគ្រប់គ្រងរបស់ សុន សេន ហើយនិងចុងក្រោយបំផុតនោះជាមួយនឹងបងទីពីរនេះ បញ្ជូនមកផ្លូវការ គាត់ណែនាំ ចាំទទួល មិត្តចាំទទួលពីគ្រប់ទិស។

[១០:២៨:៣៨]

**ស៖** ចុះអ្នកទោសដែលនៅស-២១ ដែលលោកបញ្ជាក់ថាជាង១២.០០០នាក់ហ្នឹង តើពួកគេទាំងអស់ហ្នឹងមកពីខាងណាដែរលោក?

**ឆ៖** ច្រើនណាស់។ កម្មករ ពួកកម្មកររោងចក្រអគ្គិ-- នែរោងចក្រធ្វើក្រដាសចក្រអង្រែ រោងចក្រអគ្គិសនីផ្សារតូច ចូលមកមុនគេ។ ពេលដែលខ្ញុំទើបចូលទៅដល់ភ្លាមឃើញពួកនុ៎ង ពួកទាហានពួកអីៗហ្នឹងអស់មួយសាទៅ។ ហើយដល់ក្រោយមក នៅពេលដែលខ្ញុំចូលទៅហ្នឹង ឃើញចាប់ពួក២៥ ពួកខ្សែ សុខ ពួកខ្សែ ហួត សេ ពួកខ្សែ សុខ ប៊ុតចំរើន នេះមក។ ហើយដល់ខ្ញុំចូលទៅ ខ្ញុំកាន់កាប់កិច្ចការជាប្រធានស-២១ អាហ្នឹងវាមកពីខាងកងពល៣១០, ៤៥០, កងពល៥០២, កងពលគ្រប់កងពលមក។ ហើយក្រោយមក វាមកពីភូមិភាគផ្សេងៗទៀត។ ខាងលើបញ្ជូនមក។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកនៅ--

[១០:៣០:១៧]

**ប្រធានអង្គជំនុំ៖**

បាទ ហើយឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោកមេធាវី!

[១០:៣០:៣២]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន ហើយសូមអរគុណលោក លោកស្រីចៅក្រម។ ដោយសារបញ្ហាសុខភាព ជាពិសេសបញ្ហាឈឺចង្កេះ ឆ្អឹងខ្នង និងជើង ដែលធ្វើឲ្យលោក អៀង សារី ពិបាកក្នុងការអង្គុយនៅទីនេះ។ ពេលនេះលោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការផ្ទាល់ក្នុងសវនាការនេះ សម្រាប់ថ្ងៃនេះពេញតែម្តង។ ប៉ុន្តែសូមចូលរួមសវនាការដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោម។

អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាអនុញ្ញាត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក នួន ជា!

[១០:៣១:០៧]

**លោក នួន ជា៖**

ប្រធាន ថ្ងៃនេះខ្ញុំមិនស្រួលខ្លួនទេ អាស្រ័យហេតុនេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន សូមទៅសម្រាកនៅបន្ទប់ខាងក្រោម ហើយខ្ញុំនឹងព្យាយាមតានដានដំណើរការនេះ ប្រសិនបើសុខភាពអាចឲ្យតាមដានបាន។ សូមអរគុណលោកប្រធាន។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ មុនពេលលោកចៅក្រមធ្វើការសម្រេចចិត្ត កូនក្តីរបស់ខ្ញុំស្នើថា គាត់នឹងតាមដានកិច្ចដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំង ហើយគាត់ព្យាយាមចូលរួម ហើយនិងព្យាយាមយល់ឲ្យបានលម្អិត។ ហើយខ្ញុំបានពិភាក្សាជាមួយនឹងកូនក្តីរបស់ខ្ញុំ ហើយខ្ញុំសូមជម្រាបសាលាដំបូងថា

ក្នុងករណីដែលមានបញ្ហា បានន័យថា ក្នុងករណីដែលគាត់មិនអាចតាមដានបាន យើងនឹងជម្រាបទៅខាងសាលាដំបូង។

ដូច្នេះ យើងនឹងដាក់លិខិត ដើម្បីលើកលែងសិទ្ធិរបស់គាត់ចូលរួមនៅក្នុងទីសវនាការនេះ ប៉ុន្តែគាត់ទៅចូលរួមនៅខាងក្រោម។ ដូច្នេះប្រសិនបើយើងមិនលើកបញ្ហាអ្វីមកពិភាក្សាទេ បានន័យថាកូនក្តីរបស់ខ្ញុំគាត់កំពុងតែតាមដានកិច្ចដំណើរការនីតិវិធីហើយ។

[១០:៣២:៤៧]

ខ្ញុំចង់លើការជំទាស់មួយទាក់ទងទៅនឹងការចោទសំណួរ ប៉ុន្តែខ្ញុំនឹងលើកបញ្ហាទាំងអស់នេះនៅពេលដែលយើងចាប់ផ្តើមកិច្ចដំណើរការនីតិវិធីបន្ទាប់ពីការឈប់សម្រាករបស់យើង។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

តើលោកសុំទៅហ្នឹង ក្នុងអំឡុងពេលណាទៅជាក់ច្បាស់? សុំសម្រាប់ពេលណា?

**លោក នួន ជា៖**

គោរពលោកប្រធាន ពីឥឡូវនេះទៅ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីបញ្ជាក់ឲ្យបានច្បាស់លាស់!

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំគិតថា ចម្លើយគឺថា បាទ ប្រហែលជាបានឆ្លើយរួចទៅហើយលោកប្រធាន។

[១០:៣៣:៣៨]

**ប្រធានអង្គជំនុំ៖**

យើងសួរថា ការស្នើសុំហ្នឹងសម្រាប់ចិរវេលាពេលណា? សម្រាប់តែព្រឹកនេះ ពីម៉ោងនេះទៅរហូតដល់ថ្ងៃត្រង់ ដល់ពេលរសៀលចូលវិញ ឬក៏ពីនេះទៅរហូតដល់ពេញមួយថ្ងៃ? នេះវាពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ បើលោកសុំមួយពេល ហើយអង្គជំនុំជម្រះសម្រេចមួយថ្ងៃនោះវាជាការខុសឆ្គងរបស់អង្គជុំនំជម្រះ។ តែបើសុំដល់រយៈពេលមួយថ្ងៃ អង្គជំនុំជម្រះសម្រេចត្រឹមតែពេលនេះទៅត្រឹមតែរសៀលម៉ោងមួយកន្លះហើយចូលវិញនោះ វាជារឿងមួយដែលសម្រេចមិនត្រូវតាមសំណើទេ។ ពីព្រោះសំណើមិនបានបញ្ជាក់ច្បាស់លាស់ ថាពេលណាទេ ដែលសុំដកខ្លួនចាកចេញពីបន្ទប់

E1/52.1

សវនាការនេះ លះបង់សិទ្ធិមិនចូលរួមនេះ ហើយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនោះ ពីព្រោះទម្លាប់នៃការបង្ហាញនេះ មិនបានបង្ហាញពីពេលវេលាជាក់ច្បាស់នៅក្នុងសំណើរបស់ខ្លួន។

[១០:៣៤:៣៦]

**លោក ម៉ៃខល ផេសមិនៈ**

ខ្ញុំសូមនិយាយឡើងវិញនូវអ្វីដែលខ្ញុំបាននិយាយ ហើយខ្ញុំមិនដឹងថា តើកូនក្តីរបស់ខ្ញុំអាចបន្តដំណើរការ បន្តការចូលរួមរហូតដល់ពេលរសៀល ឬក៏អត់នោះទេ?

ដូច្នេះ ខ្ញុំនឹងស្នើសុំឱ្យលោកវេជ្ជបណ្ឌិតឲ្យពិនិត្យមើល ប្រសិនបើមានបញ្ហា។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៦:១០]

**ប្រធានអង្គជំនុំៈ**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី, នួន ជា ដែលបានធ្វើឡើងតាមរយៈខ្លួនគាត់ផ្ទាល់ និងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះ ដោយសារទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ ពីបន្ទប់ឃុំខ្លួននៅខាងក្រោមបន្ទប់សវនាការនេះ ពេញមួយថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាព មិនអាចអង្គុយតាមដានស្តាប់នៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់បាន ដោយក្រុមមេធាវីការពារក្តីសន្យាថានឹងប្រគល់មកឲ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិមិនចូលរួមសវនាការដោយផ្ទាល់ ដោយមានហត្ថលេខាយ៉ាងជាក់ច្បាស់ពីជនជាប់ចោទទាំងពីររូប។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទទាំងពីររូបដែលបានស្នើសុំដោយផ្ទាល់ និងតាមរយៈមេធាវីរបស់គាត់ ដោយសុំលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួននៅខាងក្រោមបន្ទប់សវនាការនេះតាមរយៈប្រព័ន្ធសោតទស្សន៍។

ក្រុមមេធាវីការពារក្តី អៀង សារី និង នួន ជា ត្រូវប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមៗនូវលិខិតលះបង់សិទ្ធិ ក្នុងការចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនា-ការនេះ ដោយចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទ អៀង សារី និង នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទទាំងពីររូបអាចតាម

ដានកិច្ចដំណើរការពីចម្ងាយ នៅក្នុងបន្ទប់ដែលបានរៀបចំទុករួចហើយសម្រាប់គាត់ម្នាក់ៗ ហើយនិងបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីរនាក់ទៅកាន់បន្ទប់ខាងក្រោម ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់ជនជាប់ចោទអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ទន្ទឹមនឹងនេះអង្គជំនុំជម្រះសូមជម្រាបផងដែរថា មេធាវីមិនមានសិទ្ធិនៅក្នុងការបង្គាប់បញ្ជាទៅគ្រូពេទ្យប្រចាំការនៅក្នុងបន្ទប់សវនាការនេះ ទៅពិនិត្យកូនក្ដីរបស់ខ្លួនទេ។ ប្រសិនបើមានព័ត៌មានណាមួយគឺ មេធាវីត្រូវស្នើសុំមកអង្គជំនុំជម្រះតាមរយៈក្រឡាបញ្ជីនៃសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីអង្គជំនុំជម្រះចាត់វិធានការសមស្របតាមផ្លូវច្បាប់។

[១០:៣៨:២៨]

ដូចគ្នានេះដែរ គឺលោកគ្រូពេទ្យមិនគប្បីទទួលការអនុវត្តនូវបទបញ្ជាឯណាដែលមិនមែនជាបទបញ្ជារបស់អង្គជំនុំជម្រះទេ នៅក្នុងការពិនិត្យសុខភាពរបស់ជនជាប់ចោទនៅក្នុងអំឡុងពេលដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនលោក កាំង ហ្កេកអ៊ាវ ទៅកាន់បន្ទប់សម្រាករបស់សម្រាប់សាក្សី ហើយនិងឲ្យនាំ អញ្ជើញគាត់ឲ្យចូលមកកាន់សវនាការវិញ ឲ្យបានមុនពេលអង្គជំនុំជម្រះចូលកាន់អាសនៈ ហើយតាមកាលវេលានេះ គឺអង្គជំនុំជម្រះពន្យារនូវការសម្រាកហ្នឹង រហូតដល់ម៉ោងដប់មួយ។

សូមអញ្ជើញមានបញ្ហាអីទៀតលោកមេធាវី! លោកមានបញ្ហាអីទៀតទេ?

**លោក ម៉ៃខល ផេសមិនៈ**

អ្វីដែលខ្ញុំស្នើ គឺថាស្នើឲ្យមានការពិនិត្យសុខភាព។ ដូច្នេះ ខ្ញុំស្នើថា ឲ្យកូនក្ដីរបស់ខ្ញុំធ្វើការ ទទួលការពិនិត្យសុខភាពនៅពេលឈប់សម្រាកអាហារថ្ងៃត្រង់នេះ។

[១០:៤០:០៣]

**ប្រធានអង្គជំនុំៈ**

គ្រូពេទ្យកុំអាលអនុវត្តបញ្ហានេះអី ពីព្រោះមិនទាន់មានឥរិយាបទណាមួយប្លែកនៅឡើយទេ។ ចាំមានពេលៗ ឥរិយាបទនៃបញ្ហាបាតុភាពដែលកើតឡើងជាសញ្ញានៃការបញ្ហាសុខភាពរបស់គាត់មានបញ្ហា ឬក៏មានព័ត៌មានណាមួយ ដែលបញ្ជាក់អំពីថាគាត់កំពុងតែមានបញ្ហាសុខភាព សូមស្នើសុំមកអង្គជំនុំជម្រះដើម្បីពិនិត្យ ឬក៏លោកគ្រូពេទ្យអាចពិនិត្យភ្លាមដោយផ្អែកខ្លួនឯងបាន ហើយរាយការណ៍មកអង្គជំនុំជម្រះ ក្នុងករណីបន្ទាន់។ លើកលែងតែករណីផ្សេង ដែលមានសំណើពីភាគី គឺត្រូវធ្វើសំណើ

តាមរយៈប្រធានអង្គជំនុំជម្រះ តាមរយៈក្រឡាបញ្ជីសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤១ នាទី ដល់ម៉ោង ១១:០៨ នាទី)*

[១១:០៨:២២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរចំពោះសាក្សី អង្គជំនុំជម្រះសូមបញ្ជាក់សាជាថ្មីម្តងទៀតអំពីការដែលអង្គជំនុំជម្រះបានសម្រេចអម្បាញ់មិញមុនពេលចូលឈប់សម្រាក។ អង្គជំនុំជម្រះសម្រេចថា មិនឲ្យ អនុញ្ញាតឲ្យមេធាវីការពារក្តីស្នើសុំដោយផ្ទាល់ទៅគ្រូពេទ្យ ដែលមានភារកិច្ចនៅក្នុងការត្រួតពិនិត្យសុខភាពរបស់ជនជាប់ចោទ ដោយផ្ទាល់នោះទេ។ ប្រសិនបើមានព័ត៌មាន ឬក៏ការកត់សម្គាល់អំពីបញ្ហាសុខភាពនូវកូនក្តីរបស់ខ្លួន ក្រុមមេធាវីការពារក្តីត្រូវស្នើមកអង្គជំនុំជម្រះតាមរយៈក្រឡាបញ្ជីសវនាការ ឬក៏ករណីផ្សេងពីនេះ ក្នុងការអនុវត្តវិជ្ជាជីវៈគ្រូពេទ្យអាចធ្វើដោយឯងៗបាន ក្នុងករណីទទួលព័ត៌មាន ឬក៏ឃើញជាក់ច្បាស់ថា ជនជាប់ចោទកំពុងស្ថិតនៅក្នុងស្ថានភាពមានបញ្ហាខាងសុខភាព រួចរាយការណ៍អំពីការពិនិត្យ វាយតម្លៃរបស់ខ្លួនមកអង្គជំនុំជម្រះតាមរយៈក្រឡាបញ្ជី។

[១១:១០:១៦]

ដោយឡែកបញ្ហាដែលអង្គជំនុំជម្រះបានសម្រេចថា មិនអនុញ្ញាតឲ្យមេធាវីការពារក្តីទៅចូលរួមដោយផ្ទាល់នៅក្នុងកិច្ចប្រតិបត្តិការរបស់គ្រូពេទ្យនៅក្នុងការពិនិត្យ ឬក៏ព្យាបាលជនជាប់ចោទ នៅក្នុងអំឡុងពេលនៃដំណើរការសវនាការ គឺលោកចៅក្រម ហ្សង់ម៉ាក ក្នុងនាមអង្គជំនុំជម្រះដែលប្រធានសវនាការបានប្រគល់ភារកិច្ចឲ្យកាលពីព្រឹកមិញបានធ្វើការបញ្ជាក់ ឆ្លើយតបយ៉ាងច្បាស់លាស់ហើយ។ ដោយអម្បាញ់មិញនេះ កត់ចំណាំ កត់សម្គាល់អំពីបញ្ហាបកប្រែភាសាទៅជាភាសាផ្សេងៗមិនដូចនឹងអ្វីដែលយើងបានសម្រេចជាភាសាខ្មែរ។ អ៊ីចឹងហើយបានជាមានការកែតម្រូវបញ្ជាក់សាជាថ្មីម្តងទៀត ឲ្យ

ច្បាស់លាស់ ហើយដើម្បីឲ្យកាន់តែច្បាស់ទៀត យើងប្រគល់ផ្តល់ភារកិច្ចទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីបញ្ជាក់បញ្ហានេះបន្ថែមឲ្យកាន់តែច្បាស់ថែមទៀត ចៀសវាងមានការភ័ន្តច្រឡំ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

[១១:១១:៥៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំគិតថា ខ្ញុំដូចជាគ្មានអ្វីធំដុំដែលត្រូវបន្ថែមទៅលើអ្វីដែលលោកប្រធានបានបញ្ជាក់នោះទេ។ ហើយខ្ញុំគិតថាមានការបកប្រែត្រឹមត្រូវហើយ ដូច្នេះអ្វីៗច្បាស់ណាស់ចំពោះភាគីទាំងអស់។ ហើយខ្ញុំគិតថា វាមិនមានប្រយោជន៍អីក្នុងការស្នើសុំ ដើម្បីទៅចូលរួមនៅក្នុងការពិនិត្យវេជ្ជសាស្ត្រនោះទេ ពីព្រោះថាសំណើសុំបែបនេះនឹងត្រូវបដិសេធហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាថ្មីម្តងទៀត សូមរំឭកដល់តំណាងសហព្រះរាជអាជ្ញា សូមពិនិត្យលទ្ធភាពក្នុងការជជែកពិភាក្សាដេញដោលនេះ នៅក្នុងក្របខ័ណ្ឌនៃអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់ឲ្យដាក់ពិភាក្សាដេញដោលទៅនៅក្នុងសំណុំរឿង ០០២/០១ ដោយចាប់ផ្តើមពីបរិបទប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជា រចនាសម្ព័ន្ធរដ្ឋបាល តួនាទីភារកិច្ចរបស់ជនជាប់ចោទ ទំនាក់ទំនងការងារនេះជាដើមដំបូងនៃកិច្ចពិភាក្សា ចោទសួរ ដេញដោលចំពោះសាក្សី ហើយជាបន្តបន្ទាប់គឺអង្គហេតុនៅក្នុងក្របខ័ណ្ឌដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធ E124/7.2 ។

[១១:១៣:២៤]

នៅក្នុងនេះក៏សូមរំឭកផងដែរថា ត្រង់ចំណុច៧ អំពីគោលនយោបាយដែលអនុវត្តគឺកម្រិតត្រឹមកថាខណ្ឌ១៦០ ដល់១៦៥ គឺកម្រិតត្រឹមការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ។

អង្គជំនុំជម្រះសង្ឃឹមថា ភាគីទាំងអស់នឹងពិនិត្យបញ្ហានេះ ដើម្បីតម្រង់ទិសនៃកិច្ចពិភាក្សាឲ្យចំនូវបណ្តាអង្គហេតុទាំងឡាយដែលជំនុំជម្រះកំណត់ឲ្យធ្វើសវនាការ ដើម្បីឲ្យកិច្ចដំណើរការប្រព្រឹត្តទៅបានឆាប់រហ័ស និងមានប្រសិទ្ធភាព។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

សូមអញ្ជើញមេធាវីការពារក្តី នួន ជា!

[១១:១៤:២៤]

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធានសូមអរគុណ។ លោកបានសន្មតទុកជាមុននូវសំណើរបស់ខ្ញុំ។ ដូច្នេះហើយទាក់ទង់ទៅនឹងអ្វីដែលខ្ញុំចង់និយាយថា ការ-- គឺប្រធានបទដែលយើងត្រូវពិភាក្សា ដូចជាការ បោសសម្អាតនៅស-២១ ការបោសសម្អាតនៅមុនឆ្នាំ៧៥ ដែលស្ថិតនៅក្នុងវិសាលភាពនៃសវនាការមួយនេះ។ ដូច្នេះហើយខ្ញុំសូមស្នើថា សហព្រះរាជអាជ្ញាមេត្តារក្សាព្រំដែននៅក្នុងអ្វីដែលយើងបានពិភាក្សានេះ។

[១១:១៥:០៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ សហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

អរុណសួស្តី លោកប្រធាន លោកចៅក្រម និងលោកមេធាវីការពារក្តី។ ខាងសហព្រះរាជអាជ្ញានឹងទទួលយកនូវអ្វីដែលអង្គជំនុំជម្រះបានស្នើ ប៉ុន្តែសំណួរដែលយើងចោទសួរនៅព្រឹកនេះ គឺថាដើម្បីបង្ហាញ ឬក៏ដើម្បីចោទដល់សាក្សី ថាតើគាត់អាចផ្តល់ជាសាក្សីទាក់ទងទៅនឹង-- អាចផ្តល់ជាសក្ខីកម្មទាក់ទងទៅនឹងគោលនយោបាយ ឬក៏អ្វីៗទាំងអស់នេះឬក៏អត់? ការពិត គឺយើងចង់ផ្តោតទៅលើការអនុវត្តគោលនយោបាយ ហើយដូចដែលលោកចៅក្រមបានដឹង គឺនៅក្នុងឯកសារ E12 គឺថាមាន-- គឺយើងបានលើកឡើងអំពីការសហឧក្រិដ្ឋកម្មរួម។ ហើយចំពោះកថាខណ្ឌ១៥៦ ដល់១៥៩ គឺយើងបាននិយាយអំពីការជម្លៀសដោយបង្ខំ គឺការជម្លៀសប្រជាជនចេញពីទីក្រុង ប៉ុន្តែលោកចៅក្រមបានសម្រេចថា នៅក្នុងសេចក្តីសម្រេចនោះ គឺថាវាសារៈសំខាន់ដែលថាគោលនយោបាយ ឬក៏ភស្តុតាងពីគោលនយោបាយមួយចំនួន ត្រូវលើកយកមកពិភាក្សា ហើយគោលនយោបាយមួយចំនួនទៀត ដែលទាក់ទងទៅនឹងការជម្លៀស ឬក៏ការបង្ខំប្រជាជនចេញ ត្រូវយកមកពិភាក្សា។

[១១:១៦:៣៤]

នេះគឺជាគោលនយោបាយដែលត្រូវធ្វើការពន្យល់ ថាតើហេតុអ្វីបានជាមានការជម្លៀសប្រជាជនចេញពីទីក្រុង។ ដូច្នេះ យើងគ្រាន់តែចំណាយពេល១៥ ទៅ២០នាទី ដើម្បីបញ្ចប់ទៅលើផ្នែកគោលនយោបាយនេះ។ ដូច្នេះ យើងបានបញ្ជាក់ច្បាស់នៅក្នុងកថាខណ្ឌ៦ នៃផ្នែកសវនាការមួយនេះ។ ដូច្នេះហើយ ខ្ញុំសូមស្នើថា ប្រសិនបើមានសវនាការលើអង្គសេចក្តីណាមួយ គឺថាយើងនឹងមិនរំឭក ឬក៏យើងមិនចោទដដែលៗទៅលើភស្តុតាងបែបនេះទេ។ ពីព្រោះថា វាគឺជាអ្វីដែលយើងបាន-- ការពិត

វាគឺជាអ្វី ដែលយើងគ្រាន់តែធ្វើយុត្តិកម្ម ទាក់ទងទៅនឹងការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង គឺទាក់ទងទៅគោលនយោបាយ។ ហេតុដូច្នេះហើយ សហព្រះរាជអាជ្ញាគ្រាន់តែចង់ស្វែងរកយុត្តិកម្ម ចំពោះការជម្លៀសប្រជាជន មិនមែនចង់សិក្សាពីអ្វីផ្សេងនោះទេ។ ដូច្នេះហើយ ប្រសិនបើយើងមាន ភស្តុតាងណាមួយ ទាក់ទងទៅនឹងគោលនយោបាយនោះ ដូច្នេះ គឺយើងអាចនឹងដឹងនូវរឿងពាក់កណ្តាល ឬក៏យើងអាចដឹងនូវភស្តុតាង យ៉ាងហោចណាស់ ក៏ពាក់កណ្តាលនៃរឿងគោលនយោបាយនោះដែរ ក៏ដូចជាការអនុវត្តគោលនយោបាយនោះដែរ។

[១១:១៧:៥២]

ដូច្នេះចំណុចទាំងអស់នេះ វាគឺទាក់ទងទៅនឹងការធ្វើបទបង្ហាញ ហើយយើងសូមស្នើថាយើងនឹង ចាប់ផ្តើមចោទសួរទៅលើសាក្សី ទៅលើគោលនយោបាយ និងទៅលើគោលការណ៍ទាក់ទងទៅនឹងបក្ស កុម្មុយនីស្តកម្ពុជា ក៏ដូចជាការអនុវត្តទៅលើគោលនយោបាយ។ ដូច្នេះហើយ គឺយើងអាចទាញយក ភស្តុតាងពីការចោទសួរទាំងអស់នេះ។ ហេតុដូច្នេះ យើងចង់ជម្រាបថា សហព្រះរាជអាជ្ញាមិនមែនចង់ ចោទសួរ ឬក៏ដើម្បីដាក់ភស្តុតាងទៅលើការអនុវត្តគោលនយោបាយនោះឡើយ។

ដូចដែលលោកចៅក្រមបានជ្រាបរួចមកហើយថា សាក្សីមួយនេះ គឺគាត់អាចបង្ហាញយ៉ាង លម្អិតទៅលើគោលនយោយបាយ នៃបក្សកុម្មុយនីស្តបានយ៉ាងល្អ។ ប្រសិនបើលោកចៅក្រមអនុញ្ញាត យើងស្នើសុំថា ខ្ញុំសូមឱ្យសហសេវិកជាតិរបស់ខ្ញុំបន្តនូវសំណួរបន្តទៅទៀត ទាក់ទងទៅនឹងគោល នយោបាយដែលផ្តោតសំខាន់ទៅលើក្រុមជាក់លាក់ ដូចជាក្រុមជនជាតិវៀតណាមជាដើម។ ហើយដូច ជាឯកសារ 12450 ទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួម ដើម្បីយើងស្វែងរកឱ្យឃើញ ថាតើឯកសារហ្នឹង ឆ្លុះបញ្ចាំងពីគោលនយោបាយ ឬក៏បង្ហាញពីគោលនយោបាយនៃកម្ទេចសត្រូវដែរ ឬក៏អត់?

[១១:១៩:១៨]

យើងត្រូវការពេលប្រហែលជាម្ភៃនាទីតែប៉ុណ្ណោះ ដើម្បីធ្វើការចោទសួរទៅលើបញ្ហានេះ ហើយ យើងលើកសំណួរនេះឡើង ដោយសារតែយើងចង់ដឹងអំពីការអនុវត្តប្រសិនបើមាន។ ហើយសំណួរ ទាក់ទងទៅនឹងគោលនយោបាយមួយនេះ យើងនឹងចោទសួរទៅលើសាក្សីជាច្រើន។ ហើយយើងមិន មែនធ្វើតែចំពោះសាក្សីមួយនេះទេ គឺថា-- ប្រសិនបើលោកចៅក្រមអនុញ្ញាត យើងសូមស្នើសុំពេលតែ ម្ភៃនាទី ដើម្បីចោទសួរទៅលើបញ្ហាមួយនេះ ហើយយើងនឹងបន្ទាប់មក យើងនឹងបន្តទៅលើប្រធានបទ តទៅទៀត ដែលនិយាយអំពីរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ក៏ដូចជាធម្មនុញ្ញ ឬក៏លក្ខន្តិកៈនានា

របស់បក្សកុម្មុយនីស្តកម្ពុជា។ សូមអរគុណលោកប្រធាន។

[១១:២០:០៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកកាំង ហ្កេកអ៊ាវ ខ្ញុំនឹងសួរបន្តទៀត ទាក់ទងទៅនឹងគោលនយោបាយនៃការបោសសម្អាតខ្មាំង។ តើលោកដឹងទេអំពីគោលនយោបាយនៃការបោសសម្អាតខ្មាំងនៅតាមបណ្តាក្រសួងនានារបស់របបកម្ពុជាប្រជាធិបតេយ្យហ្នឹងលោកដឹងដែរទេ? ហើយដឹងដោយរបៀបណាដែរ? សូមលោកជួយរៀបរាប់។

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ខ្ញុំជាអ្នកប្រតិបត្តិការម្នាក់ក្នុងរឿង អនុវត្តគោលនយោបាយបោសសម្អាតខ្មាំងផ្ទៃក្នុង ទាំងក្នុងកងទ័ព ទាំងក្នុងក្រសួង។ ទិសដៅរបស់បក្សកុម្មុយនីស្តកម្ពុជា សំដៅទៅលើមនុស្សដែលមានជាប់និន្នាការជាមួយនឹងអាមេរិក នេះម្យ៉ាង។ ក៏ប៉ុន្តែសំខាន់ក្រោយមកទៀត ឃើញសំដៅទៅលើមនុស្សដែលមានជាប់និន្នាការជាមួយនឹងវៀតណាម។ ដូច្នេះគោលនយោបាយតម្រង់ទិសពីរហ្នឹង គឺអាមេរិកនិងវៀតណាម។ ដល់ក្រោយមកគឺសំដៅទៅលើវៀតណាមតែម្តង។

**ស៖** បាទ សូមអរគុណ។ តើលោកដឹងអំពីគោលនយោបាយដែលទាក់ទងនឹងការកម្ទេចវៀតណាមនេះនៅពេលណាដែរ? ហើយដោយវិធីណាដែរ?

[១១:២២:០៥]

**ឆ៖** សូមទោស។ ខ្ញុំបញ្ជាក់មួយម៉ាត់ ដែលខ្ញុំនិយាយអំមិញហ្នឹង គឺផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជា អ្នកដែលមាននិន្នាការវៀតណាម។ ដូច្នេះខ្មែរ មិនមែនសំដៅតែវៀតណាមទេ។ សូមបញ្ជាក់ថាអាណិកជនវៀតណាម លន់ នល់ គាត់ចាប់ប្រមូលបញ្ជូនទៅស្រុកមួយសា ដល់ក្រោយមកបក្សកុម្មុយនីស្តកម្ពុជាដេញ ឆក់ឱកាសពេលដែល ឡេ យន់ ស៊ុំយកអាណិកជនវៀតណាមចេញពីកម្ពុជាទៅចូលរួមបោះឆ្នោត ប៉ុល ពត ឲ្យគេដេញ ដេញខ្ទេច គ្មានវៀតណាមណាម្នាក់នៅដីកម្ពុជាទេ។ អើនិយាយនេះ

ជារួមអ៊ីចឹង។

[១១:២២:៤៨]

ដូច្នេះ ខ្ញុំដែលនិយាយវៀតណាអំមិញ គឺសំដៅអ្នកដែលមាននិន្នាការវៀតណាម។ និយាយឲ្យដល់ឫស្សគល់ គឺអ្នកដែលជាអតីតសមាជិកបក្សប្រជាជនបដិវត្តន៍កម្ពុជា។

**ស៖** បាទ អរគុណ។ ចុះអាណិកជនវៀតណាម តើបក្សកុម្មុយនីស្តកម្ពុជាហ្នឹងមានគោលនយោបាយកម្ទេចដូចអ្នកផ្សេងទៀតដែរទេ?

**ឆ៖** មិនកម្ទេចទាំងដុលទេ។ ដូចជាមិនឃើញមានកម្ទេចជាឯកជនណាមួយផង ក្រៅពីអ្នកដែលធ្វើខុស។ លន់ នល់ គាត់ដេញចេញចាប់បញ្ជូនទៅស្រុក ឯចំណែកប៉ុល ពត គាត់ឆក់ឱកាសពេលដែល ឡេ យន់ សុំយកអាណិកជនវៀតណាមទៅចូលរួមបោះឆ្នោតសកលឆ្នាំ៧៣នេះ ប៉ុល ពត ដេញរុញទៅ ទាំងកងទ័ព ទាំងអ្នកមន្ទីរ ទាំងអាណិកជន ទៅអស់។ ដូច្នេះមុន ៧៥ អត់មានរឿងវៀតណាមណានៅលើទឹកដីខ្មែរទេ មិនមានគ្រោះអាសន្នវៀតណាមចេញពីវៀតណាមនៅលើទឹកដីកម្ពុជាទេ។ ដូច្នេះដែលខ្ញុំនិយាយអំមិញ ដែលសម្រិតសម្រាំងហ្នឹងគឺសំដៅសាច់ឈាមឯង ដែលជាសមាជិកនៃបក្សប្រជាជនបដិវត្តន៍កម្ពុជា។

[១១:២៤:២២]

**ស៖** បាទ អរគុណ។ ទាក់ទងទៅនឹងកម្មាភិបាលដែលមាននៅតាមបណ្ដាក្រសួងផ្សេងៗដែលលោកបានជម្រាបជូនអំមិញ ដែលទាក់ទងពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការបោសសម្អាតហ្នឹង តើលោកនៅចាំទេថា មានក្រសួងណាខ្លះដែរ លោកដឹងទេ?

**ប្រធានអង្គជំនុំ៖**

ខុច កុំអាល-- កុំអាលឆ្លើយ បង្អង់បន្តិច រង់ចាំស្ដាប់មើលការជំទាស់របស់លោកមេធាវីការពារក្ដី នួន ជា។ អញ្ជើញលោកមេធាវី!

[១១:២៥:០៦]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណ លោកប្រធាន។ ខ្ញុំគិតថា សហព្រះរាជអាជ្ញាហាក់ដូចជាងាកខុសបន្តិចហើយ។ ខ្ញុំបានជម្រាបហើយថា គោលនយោបាយរបស់បក្សកុម្មុយនីស្តនៅក្រោយឆ្នាំ៧៥ គឺអាចពាក់ព័ន្ធមែនគឺទាក់ទងទៅនឹងការជម្លៀសចេញពីទីក្រុងភ្នំពេញ។ ដូច្នេះយើងស្នើថា-- ដូច្នេះគឺថាមេធាវី-- សហ-

ព្រះរាជអាជ្ញាបានស្នើឲ្យមានការបោសសម្អាតនៅតាមក្រសួងមួយចំនួន នៅក្រោយ៧៥។ ដូច្នេះខ្ញុំគិតថា វាហាក់ដូចជាមិនមានអ្វីពាក់ព័ន្ធនោះទេ។ បានន័យថាមិនពាក់ព័ន្ធទៅនឹងអ្វីដែលយើងកំពុងតែពិភាក្សាក៏ដូចជាបទចោទដែលកំពុងបានអនុវត្ត។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១១:២៦:០០]

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ប្រហែលជាខាងមេធាវីការពារក្តីស្តាប់បានតែពាក់កណ្តាលនៃចម្លើយរបស់ខ្ញុំនោះទេ គឺថាខ្ញុំចង់ជម្រាបថា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា គឺពាក់ព័ន្ធទៅសវនាការមួយនេះ ហើយក៏ប្រហែលជាពាក់ព័ន្ធទៅនឹងសនវការលើកក្រោយផងដែរ។ ដូច្នេះខ្ញុំគិតថា យើងនឹងផ្តោតទៅលើបញ្ហានៃសំណុំរឿងនេះទៅលើគោលនយោបាយសហឧក្រិដ្ឋកម្មរួម ព្រោះថាសហឧក្រិដ្ឋកម្មរួមក៏អាចប្រើប្រាស់នៅក្នុងសវនាការលើកក្រោយដែរ។ ហេតុដូច្នេះហើយគឺវាពាក់ព័ន្ធ។ ដូច្នេះ វាដូចតែមាននៅក្នុងកថាខណ្ឌ១៥៦ ដល់១៥៩ នៃសេចក្តីសម្រេចរបស់សាលាដំបូងដែរ។ គឺថាគោលនយោបាយនេះទាក់ទងទៅនឹងការបោសសម្អាតនៅក្នុងបក្សកុម្ម-- នៅក្នុងបក្សកុម្មុយនីស្តក៏ដូចជាពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំនៅក្នុងករណីណាក៏ដោយ។

[១១:២៦:៥៨]

ដូច្នេះហើយ ដូចដែលលោកចៅក្រមបានមានប្រសាសន៍រួចហើយថា ខាងសហព្រះរាជអាជ្ញាគួរតែបង្កើតនូវគោលនយោបាយទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួម របស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងសំណុំរឿងនេះ។ ដូច្នេះយើងគឺមានកាតព្វកិច្ចបង្ហាញភស្តុតាងឲ្យលើសពីវិមតិសង្ស័យ ហើយខ្ញុំគិតថា លោកចៅក្រមបញ្ហានេះ គឺវាពាក់ព័ន្ធជាប្រាកដ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ជំទាស់គ្មានប្រសិទ្ធភាព។ សាក្សីឆ្លើយតបទៅនឹងសំណួរចុងក្រោយដែលសួរដោយតំណាងសហព្រះរាជអាជ្ញាជាតិអម្បាញ់មិញនេះ!

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** តើលោកនៅចាំសំណួរបានទេ ឬក៏ឲ្យខ្ញុំ--

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** សូមអញ្ជើញម្តងទៀត។

**ស៖** តើលោកនៅចាំទេថា គោលនយោបាយនៃការបោសសម្អាតខ្មាំងហ្នឹងមានកើតឡើងនៅតាមក្រសួងណាខ្លះដែរលោក នៅចាំទេ?

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំឆ្លើយអំមិញបានតែមួយចំហៀងទេ គឺប៉ះពាល់ដល់កម្លាំងរបស់អតីតបក្សប្រជាជនបដិវត្តន៍កម្ពុជា។ ក៏ប៉ុន្តែក្នុងការបោសសម្អាតនេះ វាប៉ះពាល់កម្លាំងមួយទៀត គឺកម្លាំងអនុធន ហើយនិងកសិករកណ្តាលរបស់ កែ ពក, កុយ ធួន និង កែ ពក។ កម្លាំងទាំងពីរនេះ កម្លាំងខាងបូព៌ា ប៉ះពាល់កងទ័ពជាសំខាន់ ហើយនិងកម្មាភិបាលតំបន់ ស្រុកនៅខាងបូព៌ាហ្នឹងតែម្តង។ មិនត្រឹមតែបូព៌ា វាទៅដល់ពាយ័ព្យទៀតឯណោះ។

[១១:២៨:៥២]

ដោយឡែក កម្លាំង កុយ ធួន, កែ ពក វាប៉ះពាល់តាមក្រសួង និងមន្ទីរខ្លាំងណាស់។ ពាណិជ្ជកម្មដូចប៉ះពាល់ពាណិជ្ជកម្មខ្លាំងជាងគេ។ ឧស្សាហកម្ម-- អំ ដឹកជញ្ជូនៗជើងទឹក ដឹកជញ្ជូនជើងគោក ហើយខាងឧត្តរកម្លាំង កុយ ធួន, កែ ពក នេះក៏ប៉ះពាល់កងទ័ពដែរ។ កងទ័ព៣១០ កងទ័ព៤៥០ កងទ័ព៩២០ គឺជាកម្លាំង កុយ ធួន ដែលត្រូវសម្រិតសម្រាំងស្ទើរតែបាត់ស្រមោល។ ឯចំណែកកងទ័ពខាងបូព៌ា គឺ១៧០ កងទ័ព-- កងពល១៧០ កងពល២៩០ ហើយនិងកងវរសេនាធំជ្រោយចង្វារ វរសេនាធំជើងទឹកជ្រោយចង្វារ។ ហ្នឹង ខ្ញុំសូមបញ្ចប់ប៉ុណ្ណឹង។

**ស៖** ចុះ តើមាននៅក្នុងបណ្តាក្រសួងណាផ្សេងៗទៀតដែរទេ ក្រៅពីអ្វីដែលលោកបានរៀបរាប់អម្បាញ់មិញហ្នឹង?

**ឆ៖** សូមទោស នឹកមិនទាន់ទេ។ វាយូរហើយ នឹកមិនទាន់ទេ អាចនៅមានក្រសួងផ្សេងទៀតក៏បានថាដែរ។ ស្ទើរតែគ្រប់ក្រសួង ថាមពលក៏មាននេះដែរ កម្លាំងនេះរបស់ កុយ ធួន ដែរ អេង មេងប៊ាង ហៅ ឆុន ជាកម្លាំងមួយសំខាន់នៅខាងថាមពល។ សូមឆ្លើយមួយម៉ាត់ ស្ទើរតែគ្រប់ក្រសួង។

**លោក សេង ប៊ុនឃាង៖**

បាទ ជាបន្តខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញឯកសារមួយចំនួនទៅដល់សាក្សីរូបនេះដើម្បីគាត់ពិនិត្យ និងបញ្ជាក់បាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

*(ក្រឡាបញ្ជីយកឯកសារឲ្យទៅសាក្សី)*

[១១:៣២:១៤]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន នៅក្នុងពេលដែលនេះ ខ្ញុំសូមធ្វើការកត់សម្គាល់ថា នីតិវិធីក្នុងការកំណត់អត្តសញ្ញាណឯកសារនេះ គឺត្រូវបង្ហាញទៅសាក្សី។ ក្នុងករណីដែលមានការជំទាស់ ដើម្បីជាបញ្ហានៃការកត់ប្រតិចារឹកឲ្យត្រឹមត្រូវ គឺថាឯកសារនេះគ្រាន់តែចង់រំឭកនូវការចងចាំរបស់សាក្សីរូបនេះ។ គឺថាក្នុងពេលនេះ មិនមែននៅពេលដែលសាក្សីរូបនេះពិនិត្យមើល ហើយអានហើយ ដែលធ្វើដើម្បីគោលបំណងនៃការរំឭកការចងចាំរបស់គាត់នោះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី! លោកស្រីមេធាវី!

[១១:៣៣:០៣]

**លោកស្រី អង់តា ហ្គីសសេ៖**

លោកប្រធាន សហភាតារបស់ខ្ញុំដែលគាត់បានដឹងពីចំណងជើងអត្ថបទ នៅក្នុង-- នៅលើអេក្រង់ជាភាសាខ្មែរនេះ។ ខ្ញុំៗសូមជំទាស់នៅក្នុងការបង្ហាញឯកសារនេះ ពីព្រោះថា គឺជាឯកសារដែលចេញមកពីក្រសួងពាណិជ្ជកម្ម ហើយដោយសារលោកសហព្រះរាជអាជ្ញាបានប្រើពាក្យពេចន៍ថា ទៅរំឭកការចង់ចាំហ្នឹង។ អ៊ីចឹងសូមឲ្យគាត់បង្ហាញមូលដ្ឋាន ថាសាក្សីនេះមានសមត្ថភាពក្នុងការពន្យល់លើឯកសារនេះ ពីព្រោះថា ឌុច នោះគាត់មិនបានធ្វើការនៅក្រសួងពាណិជ្ជកម្មនោះទេ។ អ៊ីចឹងដើម្បីឲ្យការពិភាក្សាគ្នានេះមានលក្ខណៈច្បាស់លាស់ អ៊ីចឹងសូមឲ្យខាងសហព្រះរាជអាជ្ញាហ្នឹងបង្ហាញនូវមូលដ្ឋាននៃការបង្ហាញឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ សហព្រះរាជអាជ្ញាមានយោបល់អីតបទៅនឹងការលើកឡើង កត់សម្គាល់របស់មេធាវីទាំងពីរក្រុមទេ។

[១១:៣៤:១៨]

**លោក វីល្លៀម ស្មីត៖**

សូមជម្រាបសង្ខេបទេ មេធាវីការពារក្តីចង់បង្ហាញនូវទូរលេខនេះ ហ្នឹងទីមួយ។ ទីពីរ ឯកសារនេះបានបង្ហាញជូនសាក្សី ទីមួយ គឺចង់ដឹងថាតើគាត់ចាំឯកសារនេះបានទេ? ធ្លាប់បានឃើញដោយផ្ទាល់ទេពីមុនមក? ហើយទោះបីជាគាត់មិនធ្លាប់បានឃើញពីមុនមកក៏ដោយ។ ឯកសារបានបង្ហាញជូនសាក្សីដើម្បីបង្ហាញបញ្ជាក់អំពីយថាភាពនៃឯកសារនេះ ថាតើខ្លឹមសារនៃឯកសារនេះ វាស៊ីសង្វាក់គ្នាទៅនឹងគោលនយោបាយ ដែលមានស្រាប់នៅក្នុងអំឡុងពេលនោះដែរឬទេ? ហើយគាត់អាចនឹងបង្ហាញអំពីយថាភាពនៃឯកសារនេះបាន។ ហើយក៏ដូចជាសាក្សីអាចមានការធ្វើការផ្តល់មតិយោបល់របស់ខ្លួនចំពោះខ្លឹមសារនៃឯកសារនេះ។ ប៉ុន្តែបើផ្ទុយពីនេះទៅវិញនោះគឺ បើសិនណាជាគាត់មិនមានជំហរអ្វីមួយដើម្បីលើកឡើងអំពីគោលនយោបាយ រចនាសម្ព័ន្ធនៅក្នុងអំឡុងពេលនោះបានទេ ក៏ដូចជាការបោសសម្អាតនៅក្នុងពេលនោះបានទេ។ យើងខ្ញុំបានស្តាប់ច្បាស់ហើយ ថាគាត់មានមូលដ្ឋានគ្រឹះយ៉ាងខ្លាំងដែលថាសាក្សីរូបនេះអាចបញ្ជាក់អំពីយថាភាព ឬក៏ផ្នែកដទៃៗទៀតនៃឯកសារនេះ។ ដូច្នេះគួរតែដាក់ឯកសារនេះបង្ហាញសាក្សី ដើម្បីឱ្យគាត់ទាក់ទងទៅនឹងបញ្ហាដែលខ្ញុំលើកឡើងទាំងអម្បាលម៉ាននេះ។

[១១:៣៦:០១]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសូមបញ្ជាក់បន្តិចទេ ខ្ញុំមិនចង់ពិភាក្សាដេញដោលគ្នាទេ។ ខ្ញុំចង់ឱ្យមានលក្ខណៈច្បាស់លាស់ក្នុងការបង្ហាញឯកសារបែបនេះ។ ទីមួយ ឯកសារគួរបង្ហាញអំពីលេខឯកសារនេះ ដើម្បីឱ្យយើងខ្ញុំបានដឹង ហើយសុំការអនុញ្ញាតពីអង្គជំនុំជម្រះបង្ហាញជូនសាក្សី។ សាក្សីបានបញ្ជាក់ហើយថាការចងចាំគាត់បាត់បង់ច្រើន ដូច្នេះការប្រើឯកសារនេះក៏ហាក់ដូចជាការដើម្បីរំឭកការចងចាំរបស់សាក្សី ដូចជា ការលើកឡើងរបស់សហព្រះរាជអាជ្ញា ថាតើគាត់ចាំឯកសារនេះទេ? ហើយថាតើឯកសារនេះត្រូវបានគេធ្វើឡើងដោយរបៀបណា?

ទាក់ទងទៅនឹងយថាភាពវិញនោះ គឺខ្ញុំសូមជំទាស់យ៉ាងខ្លាំង ថាទោះបីគាត់មិនធ្លាប់ឃើញក៏ដោយ ឬក៏ធ្លាប់ឃើញក៏ដោយ គាត់មិនអាចបញ្ជាក់អំពីយថាភាពបានទេ។ ឯកសារអាចមានព័ត៌មានដែលអាចជាប់ពាក់ព័ន្ធទៅនឹងការចងចាំរបស់គាត់ នូវព្រឹត្តិការណ៍ដែលកើតឡើងនៅពេលនោះ។ ក៏ប៉ុន្តែការពិនិត្យមើលទៅលើឯកសារដែលគាត់មិនធ្លាប់បានឃើញ គឺគាត់មិនអាចបញ្ជាក់យថាភាពបានទេ។ បញ្ហានេះ គឺមិនមែនបញ្ហាដែលត្រូវធ្វើនៅពេលនេះទេ ខ្ញុំគិតថាការធ្វើបែបនេះគឺខុសហើយ។ ខ្ញុំមិនជំទាស់ទេ បើសិនជា បើ-- គឺខ្ញុំជំទាស់តែចំពោះការដែលនិយាយថា នៅពេលសាក្សីមើលឯកសារហើយ

E1/52.1

គាត់-- គឺដើម្បីរំឭកការចងចាំនោះ ពីព្រោះខ្លឹមសារនៅក្នុងឯកសារក៏ដូចឯកសារខ្លួនវាផ្ទាល់ គឺថាមិនអាចបញ្ជាក់ពីយថាភាពដោយសារក្រោយពេលដែលឃើញឯកសារនោះទេ។ យើងខ្ញុំសូមជំទាស់បញ្ហានេះ។

[១១:៣៧:៥៧]

យើងកំពុងតែពិនិត្យមើល និងរៀនសូត្រទាំងអស់គ្នាថា តើភាពគ្រប់គ្រាន់នៅក្នុងឯក-- នៅក្នុងសវនាការនេះត្រូវធ្វើដោយរបៀបណា?

ដូច្នេះខ្ញុំសូមស្នើថា ទីមួយ ភាគីត្រូវបញ្ជាក់ពីលេខឯកសារ ដូច្នេះអង្គជំនុំជម្រះក៏អាចសម្រេចផងថាតើឯកសារនេះអាចយកមកចែករំលែក ដោយសាក្សីមើលបាន ឬក៏អត់? ហើយអង្គជំនុំជម្រះក៏អាចនឹងធ្វើការសម្រេចថា តើអនុញ្ញាត ឬក៏មិនអនុញ្ញាតឲ្យបង្ហាញ? បើមិនដូច្នេះយើងកំពុងតែពិភាក្សាគ្នាទៅលើឯកសារនេះក្នុងលក្ខណៈអរូបិយទៅវិញទេ។ ដូច្នេះខ្ញុំយល់ឃើញថា នៅពេលក្រោយ-- នៅពេលសហព្រះរាជអាជ្ញាឡើងថា អ៎! មេធាវីការពារក្តីគឺគាត់នឹងបាន-- ទទួលបានបញ្ហានេះពីការបង្ហាញឯកសារនេះក្នុងពេលណាមួយ។ សូមអរគុណ។

[១១:៣៩:០២]

**លោកស្រី អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ បើខ្ញុំគាំទ្រនូវការកត់សម្គាល់របស់សហភាតារបស់ខ្ញុំ ហើយខ្ញុំសូមបន្ថែមថានៅក្នុងក្របខ័ណ្ឌនៃការស្តាប់សាក្សីនេះគឺថា យើងមានបញ្ជីឯកសារមួយចំនួនដែលយើងដាក់ជូនទៅដល់គាត់។ ហើយខ្ញុំគិតថា យើងគិតថាជាការល្អក្នុងការចាប់ផ្តើមបង្ហាញលេខបញ្ជី ហើយនិងលេខឯកសារដែលយើងចង់បង្ហាញទៅសាក្សី ដែលមានឯកសារនៅក្នុងបញ្ជីនេះ។ អ៊ីចឹង គឺថាធ្វើយ៉ាងនេះ ដើម្បីឲ្យយើងអាចតាមសវនាការនេះបាន។ ខ្ញុំសូមកត់សម្គាល់មួយទៀត គឺថាទាក់ទងនឹងឯកសារដែលយើងបង្ហាញទៅសាក្សីនេះ នៅពេលដែលយើងធ្វើសំអាងហេតុតាមផ្លូវច្បាប់លើរបៀបធ្វើការងាររបស់យើងពាក់ព័ន្ធនឹងបញ្ហាដែលថា ការពិភាក្សាវាអាចក្រៅក្របខ័ណ្ឌ។ ខ្ញុំសោកស្តាយណាស់ដែលថាយើងពិភាក្សាអំពីឯកសារបញ្ហានេះនៅចំពោះមុខសាក្សីនេះ ដែលថាគ្រាន់តែជាអ្នកស្តាប់យើងនោះទេ។ ខ្ញុំមិនចង់វាយតម្លៃទៅលើភាពស្មោះត្រង់នៃការផ្តល់សក្ខីកម្មរបស់គាត់នោះទេ។ ខ្ញុំគ្រាន់តែចង់និយាយថា យើងអាច-- អ៊ីចឹងគឺថាយើងថា ព្រោះថាការនិយាយទៅអាចយើងឲ្យសាក្សីនោះគាត់មានទទួលឥទ្ធិពលពីភាគីនីមួយៗ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីញ្ញៀម ស្មីត៖**

លោក លោកស្រីចៅក្រម ខ្ញុំសូមឆ្លើយថា សាក្សីនេះមានជំហរមួយពិសេសជាងគេ ដែលអាចផ្តល់នូវមតិយោបល់អំពីភាពត្រឹមត្រូវ ភាពសុក្រឹត ការរចនាសម្ព័ន្ធ គោលនយោបាយដែលមាននៅក្នុងឯកសារនេះ ហើយក៏ជួយទៅដល់អង្គជំនុំជម្រះក្នុងការស្វែងរកនូវការពិត។ ដូច្នេះការបង្ហាញឯកសារដែលកើតមាននៅពេលនោះ ហើយសាក្សីក៏អាចជួយផ្តល់នូវជំនួយណាមួយដល់អង្គជំនុំជម្រះបានផងដែរ។ ដោយសារតែគាត់ជាសាក្សីដ៏សំខាន់ ដែលអាចជួយឱ្យអង្គជំនុំជម្រះយល់បានយ៉ាងច្រើនចំពោះអត្ថន័យនៃឯកសារដែលត្រូវបង្ហាញជូនចំពោះអង្គជំនុំជម្រះនេះ។ សូមអរគុណ។

[១១:៤១:៣៦]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំមិនយល់ពីបញ្ហាការពិភាក្សាលើឯកសារនោះទេ ព្រោះថាយើងទាំងអស់គ្នាត្រូវការលេខសម្គាល់ឯកសារ ហើយអង្គជំនុំជម្រះហ្នឹងផ្តល់សិទ្ធិឱ្យប្រើប្រាស់ឯកសារ។ ក៏ប៉ុន្តែរហូតដល់ពេលនេះ គឺថាយើងបានប្រើឯកសារ ហើយនិងបង្ហាញឯកសារដើម្បីពិភាក្សាគ្នាក្នុងសវនាការចំពោះមុខសាក្សី ខ្ញុំគិតថា យើងមានលទ្ធភាពក្នុងការធ្វើយ៉ាងដូច្នេះ។ ហើយអ៊ីចឹងមិនចាំបាច់ពិភាក្សាគ្នាដដែលទាក់ទងនឹងការបង្ហាញឯកសារ ឬក៏បង្ហាញតែឯកសារ ដើម្បីតែឱ្យសាក្សីរំឭក ស្មារតីចងចាំរបស់អ្នកសាក្សីនោះទេ។ ព្រោះថាយើងធ្លាប់បង្ហាញឯកសារច្រើនណាស់មកហើយ ពីមុនមកហ្នឹង អ៊ីចឹងបញ្ហានេះមិនគួរលើកយកមកនិយាយទៀតទេនៅក្នុងសវនាការនេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៣:២៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសួរទៅតំណាងសហព្រះរាជអាជ្ញាជាតិ អំពីឯកសារដែលស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនេះ ថាតើឯកសារនេះបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេលកន្លងមកហើយឬនៅ? ហើយបញ្ហាទីពីរគឺ សូមឱ្យតំណាងសហព្រះរាជអាជ្ញាជាតិដែលមានការចាប់អារម្មណ៍ ហើយយកចិត្តទុកដាក់ខ្ពស់អំពីបញ្ហាកាតព្វកិច្ចរបស់ខ្លួន ដែលជាភាគីដាក់ឯកសារចំពោះមុខអង្គជំនុំ

ជម្រះត្រូវបង្ហាញអំពីអត្តសញ្ញាណឯកសារ ដែលខ្លួនមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ព្រមទាំងលេខ ERN ផង ប្រសិនបើខ្លួនបានមានបំណងនៅក្នុងការបញ្ជាក់ ដកស្រង់នូវចំណុចដែលពាក់ព័ន្ធនៅក្នុងទំព័រនីមួយៗនៃឯកសារនោះ។ នេះគឺជារបៀបនៃការដែលយើងដាក់ឯកសារដេញដោលនៅចំពោះមុខអង្គជំនុំជម្រះកន្លងមក។ ដោយអម្បាញ់មិញនេះ គឺខាងតំណាងសហព្រះរាជអាជ្ញាមិនបានបញ្ជាក់អំពីបញ្ហាអត្តសញ្ញាណនៃឯកសារ ដែលត្រូវដាក់ស្នើសុំដាក់នោះទេ។ អ៊ីចឹងហើយបានជាមានបញ្ហា។ លោកអាចបញ្ជាក់បញ្ហានេះបានទេ ដើម្បីអង្គជំនុំជម្រះសម្រេចបញ្ហានេះ?

[១១:៤៤:៥០]

**លោក សេង ប៊ុនឃាង៖**

លោកប្រធាន ឯកសារនេះខ្ញុំបម្រុងនឹងបញ្ជាក់អត្តសញ្ញាណហើយ ប៉ុន្តែដោយសារមានការលើកឡើងបញ្ហានេះទៅ ខ្ញុំលើកមិនទាន់ ហើយឯកសារនេះគឺមានលេខ D366/7.1.330។

**ប្រធានអង្គជំនុំ៖**

ឯកសារនេះធ្លាប់បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះហើយឬនៅ?

**លោក សេង ប៊ុនឃាង៖**

លោកប្រធានឯកសារនេះ ការិយាល័យសហព្រះរាជអាជ្ញាបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយបាទ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ លោក! អញ្ជើញ បន្តតាមកិច្ចពិភាក្សាដេញដោលតាមនីតិវិធី។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ សូមលោកពិនិត្យមើលឯកសារហ្នឹង ដែលមាន ឯកសារហ្នឹងមានចំណងជើងថា "សេចក្តីរាយការណ៍របស់សន្និបាតក្រសួង" ដែលចុះថ្ងៃទី២៥ ទៅថ្ងៃ២៦ ខែកក្កដា ឆ្នាំ១៩៧៦។ សូមលោកពិនិត្យមើលតើលោកធ្លាប់ឃើញឯកសារនេះទេពីមុនមក?

**ឆ៖** ជម្រាបប្រសាសន៍ ខ្ញុំមិនដែលឃើញឯកសារនេះទេពីមុនមក។

 E1/52.1

[១១:៤៦:៣០]

**ស៖** ហើយសូមលោកពិនិត្យមើលត្រង់ចំណុចលេខមួយ ចំណុចទីមួយដែលនិយាយអំពីសកម្មភាពខ្មាំង? ដែលបានសរសេរថា សកម្មភាពនៃពួកសមាសភាពមិនល្អ តើលោកដឹងទេថា នៅពេលនោះគោលនយោបាយនេះមាននៅក្នុងក្រសួង ដែលមាននៅក្នុងឯកសារនេះទាក់ទងនឹងការ នឹងសមាសភាពមិនល្អនេះដែរទេ?

**ឆ៖** ឆ្នាំ១៩៧៦ ខែ៧ បើគិតទៅវាក្រោយថ្ងៃ១៤ ឧសភា ឆ្នាំ១៩៧៦ ដែល ប៉ុល ពត គាត់ប្រជុំអចិន្ត្រៃយ៍មួយនិយាយអំពីរឿងយួន។ ក្រោយប្រជុំនុ៎ងគាត់លើកពាក្យស្លោកថា "ចង់ឈ្នះយួនត្រូវបក្សស្អាត កងទ័ពស្អាត ប្រជាជនស្អាត" ដូច្នេះគោលគំនិតនេះវាចេញពីនុ៎ងហើយ។ ដូច្នេះបើប្រៀបធៀបទៅនឹងថ្ងៃដែលបោកគ្រាប់បែកក្រោយវាំង។ ថ្ងៃបោកគ្រាប់បែកក្រោយវាំងថ្ងៃ០២ ខែមេសា ឆ្នាំ១៩៧៦ បើប្រៀបធៀបទៅនឹងថ្ងៃដែល ប៉ុល ពត គាត់ចាប់ កុយ ធួន យកទៅដាក់ឃុំឃាំងក្នុងផ្ទះកាន់តែឃើញរយាលឆ្ងាយមកហើយ។ កុយ ធួន ត្រូវ ប៉ុល ពត ចាប់យកទៅដាក់ឃុំក្នុងផ្ទះ នៅថ្ងៃ០៨ ខែមេសា ឆ្នាំ១៩៧៦ ដូច្នេះលទ្ធភាពនេះគឺមាន។ មានជាក់ស្តែងក្នុងគោលនយោបាយកម្ចាត់ខ្មាំង។

[១១:៤៨:២៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក សុន អរុណ៖**

ខ្ញុំសូមបញ្ជាក់ថា ចម្លើយរបស់ ឌុច មុនដំបូងថា អត់ដែលបានឃើញឯកសារនេះទេ។ ប៉ុន្តែដល់ក្រោយមក ឌុច ខ្លួនឯងធ្វើសេចក្តីសន្និដ្ឋាន។ ខ្ញុំសូមជំទាស់ត្រង់សេចក្តីសន្និដ្ឋាន។ មិនមែនឆ្លើយទៅខាងព្រះរាជអាជ្ញាវិញទេ។ សូមអរគុណ។

[១១:៤៨:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវមតិយោបល់របស់លោក ប៉ុន្តែនេះគ្រាន់តែជាការកត់សម្គាល់ទេ។ ការជំទាស់គឺជំទាស់នឹងសំណួរ។

អង្គជំនុំជម្រះបានរំឭក ឌុច ច្រើនលើកច្រើនសាហើយ ទាំងព្រឹកមិញផងអំពីកម្រិតនៃការឆ្លើយតបទៅនឹងសំណួរ គឺចៀសឲ្យផុតអំពីការសន្និដ្ឋានយកចំណេះដឹងផ្ទាល់ខ្លួនទៅឆ្លើយតបវាយតម្លៃទៅនឹង

សំណួរដែលភាគីបានសួរ។ បានន័យថា ឃើញអីឆ្លើយហ្នឹង ដឹងអីឆ្លើយហ្នឹង ឮអីឆ្លើយហ្នឹង តបនឹងសំណួរប៉ុណ្ណោះ។ ពីព្រោះសាក្សីមិនមែនជាអ្នកជំនាញទេ ហើយអ្នកជំនាញក៏គេមិនឲ្យវិភាគវាយតម្លៃនៅកណ្តាលទីដែរ។ វាទាល់តែចង់បញ្ចប់នៃការធ្វើដេញដោលភាពជំនាញរបស់ខ្លួន ទើបអាចធ្វើសេចក្តីសន្និដ្ឋានបញ្ចប់នូវចំណេះដឹងអំពីជំនាញរបស់ខ្លួនជូនអង្គជំនុំជម្រះ។ ដូចគ្នា សូមភាគីផ្តង់ការគិតគូរអំពីបញ្ហាសំណួរ ចៀសវាងសំណួរណាដែលនាំឲ្យឈានដល់ការជនជាប់ចោទ-- អ៎! សាក្សីរូបនេះ ធ្វើសេចក្តី-- ឈានដល់ការឆ្លើយតបជាសេចក្តីសន្និដ្ឋាន។

[១១:៥០:៣១]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** ហើយនេះជាសំណួរដែលខ្ញុំនឹងសួរបន្តដែរ ថាការដែលដឹង លោកដឹងអំពីគោលនយោបាយដូចដែលមានចែងនៅក្នុងឯកសារនេះ លោកដឹងដោយវិធីណាដែរ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ខ្ញុំសូមអនុញ្ញាតរំឭកឡើងវិញ អំពីការឆ្លើយរបស់ខ្ញុំអំមិញ។ ផ្ទាល់ខ្លួនខ្ញុំ ឯកសារមួយសន្លឹកនេះ អត់ដែលឃើញទេ។ ហើយក៏ប៉ុន្តែទីពីរ ខ្ញុំនៅចាំថា សំណួររបស់លោកសហព្រះរាជអាជ្ញាសួរខ្ញុំថា តើមានសភាពការណ៍សម្រិតសម្រាំងនៅពាណិជ្ជកម្មមែន ឬក៏មិនមែន? បាន ខ្ញុំយោងទៅតាមសភាពការណ៍ដែលខ្ញុំចាំ។ យកមកពន្យល់ថា សភាពការណ៍សម្រិតសម្រាំងនៅក្រសួងពាណិជ្ជកម្មមាន។ នេះ ខ្ញុំសូមរំឭកប៉ុណ្ណោះ។ ហើយសូមសំណួរចុងក្រោយនេះ ខ្ញុំវង្វេងបាត់ហើយ សូមមេត្តាសួរម្តងទៀតមក។

**ស៖** លោកហាក់បីដូចជាបានឆ្លើយនឹងសំណួរនេះហើយ បាទ។ ខ្ញុំបន្តទៅឯកសារមួយទៀត គឺឯកសារ E3/153 សូមអនុញ្ញាតប្រគល់ឯកសារនេះ ជូនដល់សាក្សី បាទ។

[១១:៥២:១៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី! អញ្ជើញមេធាវីការពារក្តីអន្តរជាតិ ការពារក្តីឲ្យលោក ខៀវ សំផន!

**លោកស្រី អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ គ្រាន់តែចង់បំភ្លឺ បើសិនជាលោកសហព្រះរាជអាជ្ញាយោងទៅនឹងឯកសារដែលមាននៅក្នុងបញ្ជី ដែលគាត់បានដាក់ជូនមកយើងហើយ គឺថាទាក់ទងទៅនឹងសាក្សីនេះ តើគាត់ឲ្យលេខសម្គាល់ឯកសារដែលមាននៅក្នុងបញ្ជីនេះបានទេ? បើធ្វើអ៊ីចេះ យើងអាចស្រួលរកឯកសារនេះ ពីព្រោះថា យើងមានឯកសារដល់ទៅ ៥៧ ឯណោះ។ អ៊ីចឹង សូមឲ្យលេខសម្គាល់ឯកសារនេះ ដើម្បីសម្រួលដល់ការងារយើង។

[១១:៥៣:១៦]

**ប្រធានអង្គជំនុំ៖**

បាទ នេះគ្រាន់តែជាការបន្ថែមប៉ុណ្ណោះទេ។ ការដែលតម្រូវការ គឺចាំបាច់គឺគ្រាន់តែឲ្យលោកអត្តសញ្ញាណឯកសារប៉ុណ្ណោះ។ បាទ នេះគ្រាន់តែជាសំណើសុំបន្ថែម បើសិនអាចធ្វើបាន គ្រាន់បន្ថែមទៀតនៅលើលេខរៀងនៃឯកសារដែលបានស្នើសុំដាក់រួចហើយ ដើម្បីងាយរកតែប៉ុណ្ណោះទេ។

សូមអញ្ជើញ តំណាងសហព្រះរាជអាជ្ញា!

**លោក សេង ប៊ុនឃាង៖**

បាទ ឯកសារហ្នឹង គឺមានលេខ D300-- អ៎! E3/153 បាទ។ សូម-- ខ្ញុំគិតថា លោកស្រីមេធាវី សូមលោកស្រីមើលក្នុងបញ្ជីហ្នឹងត្រង់ឯកសារហ្នឹងទៅ ដឹងហើយបាទ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** ឯកសារហ្នឹង គឺមានចំណងថា "មតិបន្ថែមលើសេចក្ដីរាយការណ៍សន្និបាតក្រសួង" ដែលមានចុះនៅថ្ងៃទី២៥ ទៅ២៦ ខែកក្កដា។ ហើយសូមលោកពិនិត្យមើល ថាតើលោកធ្លាប់ឃើញឯកសារនេះពីមុនមកទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍ ខ្ញុំមិនដែលឃើញឯកសារនេះ ពីមុនមកទេ។ ពេលនេះហើយ ជាលើកទីមួយ ដែលខ្ញុំកាន់ឯកសារនេះ ហើយបានអាន។

[១១:៥៤:៥២]

**ស៖** តើលោកដឹងទេថា នេះជាឯកសារដែលបានលើកឡើងពីមតិយោបល់របស់កម្មាភិបាលមួយចំនួននៅក្នុងកិច្ចប្រជុំនោះ?

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសូមជំទាស់នៅត្រង់នេះ សាក្សីបានបញ្ជាក់ថា គាត់មិនដែលបានឃើញឯកសារនេះទេ ឥឡូវនេះសហព្រះរាជអាជ្ញាសួរនាំមុខសាក្សីដើម្បីចង់បានចម្លើយពីសាក្សីទៅវិញ។ បើសាក្សីមិនដែលឃើញទេ ដូច្នេះគាត់មិនអាចផ្តល់មតិយោបល់អីទៅលើឯកសារនោះទេ។ ដូច គាត់ផ្តល់តែភស្តុតាងណាដែលគាត់បានដឹងតែប៉ុណ្ណោះ។ ខ្ញុំឲ្យឧទាហរណ៍បាន ឧទាហរណ៍ថា តើមានអ្នកណាម្នាក់មកពីក្រសួងត្រូវបានគេបោសសម្អាតទេ? លោកដឹងដោយរបៀបណា? សហព្រះរាជអាជ្ញាគាត់និយាយថា សាក្សីគឺជាសាក្សីពិសេសមួយ។ ត្រឹមត្រូវហើយ ប្រហែលជាគាត់អាចធ្លាប់បានសម្លាប់ ធ្វើទារុណកម្ម ហើយសម្លាប់តាមរយៈគាត់ ឬក៏អ្នកដទៃ។ ប៉ុន្តែសួរអ៊ីចឹងវាអាចដឹងថាឥឡូវបាន ប៉ុន្តែបើសួរថា តើខ្ញុំសូមប្រាប់ថាក្នុងឯកសារនេះវាអ៊ីចេះៗៗ ហើយលោកដឹងៗអំពីឯកសារនេះទេ? ពីម្សិលមិញ គាត់ថា គាត់ដឹងតែអ្វីដែលគាត់បានដឹងនៅក្នុងរង្វង់ស-២១។ ខ្ញុំដឹងថាគាត់ដឹងពីការអានឯកសារខ្លះ។ តែការសួរលើឯកសារនេះ គឺមិនត្រឹមត្រូវទាល់តែសោះ។

[១១:៥៦:២១]

ដូច្នេះគាត់និយាយថា គាត់គឺមានជាសាក្សីមួយដែលជាសាក្សីដ៏ល្អ សាក្សីដ៏ពិសេសជាងគេ។ ប្រហែលជាយើងអាចអញ្ជើញអ្នកដទៃជំនួស ឌុច ក៏បាន។ ការដែលគ្រាន់តែលើកឡើងថាគាត់ជាមានលក្ខណៈពិសេស ជាការត្រឹមត្រូវហើយ ប៉ុន្តែនេះមិនមែនជាចម្លើយដែលឆ្លើយតបទៅនឹងការជំទាស់របស់យើងទាំងអស់នោះទេ។ ដោយសារគាត់មិនដែលឃើញឯកសារនេះទេ ត្រូវតែសួរមួយជំហានម្តងៗ តើលោកបានឃើញឯកសារនេះបានដោយរបៀបណា? បើគាត់ថាមិនបានឃើញទេ សូមសួរទៅសំណួរផ្សេង។ ដូច្នេះបើមិនអ៊ីចឹងទេ មិនអាច-- លោកដឹងពីឯកសារនេះទេ? លោកយល់ថាម៉េចដែរ? នោះជាការមិនត្រឹមត្រូវទេ។

ការប្រើប្រាស់ឯកសារដែលសាក្សីមិនដែលឃើញ ហាក់បីដូចជាការគ្រាន់តែត្រៀមរៀបចំដើម្បីចង់បានចម្លើយពី-- គឺមិនត្រឹមត្រូវទេ ទោះជាប្រព័ន្ធខំមិនឡូក្លី ស៊ីវិលឡូក្លី គឺឬក៏ជាប្រព័ន្ធចម្រុះក្តី គឺមិនត្រឹមត្រូវទេ ការតាំងសំណួរបែបនេះ។ ដូច្នេះ បើសួរជាអ្នកដែលសិក្សាស្រាវជ្រាវជាន់ខ្ពស់ប្រហែលជារឿងផ្សេង តែការសួរសាក្សីនេះ គឺមិនត្រឹមត្រូវទេ។ ដូច្នេះ ការអនុញ្ញាតឲ្យបង្ហាញនូវឯកសារ ហើយដើម្បីគ្រាន់ជាដឹងនូវភាពពាក់ព័ន្ធ គឺសាក្សីអាចមានមតិយោបល់អំពីខ្លឹមសារ ឬក៏របៀបវារៈអីទាំងអស់នេះ តែក្នុងករណីដែលសាក្សីបានដឹងតែប៉ុណ្ណោះ។

[១១:៥៧:៥០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ លោក លោកស្រីចៅក្រម។ ខ្ញុំយល់ស្របជាមួយមេធាវីការពារក្តី គឺថាសាក្សីមិនត្រូវបានអនុញ្ញាតឲ្យមើលឯកសារ ដែលគាត់មិនធ្លាប់បានឃើញពីមុននោះទេ។ សាក្សីរូបនេះ អាចផ្តល់ភស្តុតាងអំពីគោលនយោបាយ រចនាសម្ព័ន្ធៗប្រាស្រ័យទាក់ទងនៅក្នុងអំឡុងពេលនោះបាន ដោយសារគាត់មានតួនាទី និងលក្ខណៈពិសេសនៅក្នុងនេះ។ ការដែលយើងសួរនេះ គឺចង់ដឹងថាតើសាក្សីនេះអាចនៅចាំមនុស្សនៅក្នុងឯកសារនេះទេ? ដែលមានឈ្មោះនៅក្នុងឯកសារនេះទេ? ដើម្បីឲ្យគាត់ជួយទៅដល់ជំនុំជម្រះ ហើយយើងនឹងបន្តទៅទៀត។ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាគឺត្រូវបានអនុញ្ញាតឲ្យតាំងសំណួរទៅលើសាក្សីទាក់ទងទៅនឹងឯកសារមួយចំនួន ដែលវាអាចស៊ីសង្វាក់ទៅនឹងការចងចាំរបស់គាត់ ហើយនិងអាចផ្តល់ទម្ងន់នៃភស្តុតាងនេះបានទេ។ ចំណុចនេះសំខាន់ណាស់លោក លោកស្រីចៅក្រម ដែលសាក្សីរូបនេះអាចជួយឲ្យលោក លោកស្រីចៅក្រម យល់ថា តើឯកសារមួយៗវាជាប់ទាក់ទងគ្នាដោយរបៀបណា? ដោយសារតែគាត់មានវត្តមាន ឬដោយសារស្ថិតនៅក្នុងរបបនោះនៅពេលនោះ។

[១១:៥៩:១៩]

ការដែលគាត់មិនធ្លាប់បានឃើញឯកសារនេះពីមុនមក មិនគួរណាបញ្ឈប់មិនឲ្យគាត់មើលឯកសារតែត្រឹមនេះទេ។ ដោយសារតែបទពិសោធន៍គាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា គាត់អាចបង្ហាញនិងសង្កត់ទៅលើទៅចំណុចមួយចំនួន និងអាចបញ្ជាក់ទៅលើបញ្ហាដែលកើតមាននៅក្នុងឯកសារនេះបាន។ ហើយបន្ទាប់មក យើងនឹងសួរសំណួរជាបន្តទៅទៀត។ យើងយល់ស្របបើសិនណាជាចុងបញ្ចប់នៃថ្ងៃនេះ គាត់មិនអាចផ្តល់មតិយោបល់ទៅលើឯកសារនេះ នោះយើងនឹងបន្តទៅទៀត។ សូមអរគុណ។

[១១:៥៩:៥៦]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមបញ្ជាក់ចំណុចមួយទេលោក លោកស្រីចៅក្រម ខ្ញុំសូមឲ្យមានការស្ងប់ស្ងាត់ទាំងអស់គ្នា។ គោលបំណងទាំងអស់នេះ គួរតែបានធ្វើឡើងតាំងពីមុន ដើម្បីជួយដាស់ការចងចាំរបស់គាត់តែប៉ុណ្ណោះ។ នីតិវិធីត្រឹមត្រូវ គឺបង្ហាញឯកសារ សួរសាក្សី តើគាត់ធ្លាប់បានឃើញទេ? បើគាត់មិនធ្លាប់បានឃើញ

ប្រហែលជាអាចសួរសំណួរណា ការដែលគាត់ឲ្យគាត់អានឯកសារនេះ គឺហាក់បីដូច គឺដាស់ការចងចាំ រំឭកការចងចាំសាក្សីតែប៉ុណ្ណោះ។ ខ្ញុំមិនដឹងថា តើបច្ចេកទេសដែលកំពុងប្រើប្រាស់នេះយ៉ាងណានោះទេ? ប៉ុន្តែហាក់បីដូចជាគេហៅថា ជួយបញ្ចុកចំណីទៅលើសាក្សីនេះ គឺថាជួយធ្វើម៉េចឲ្យសាក្សីនេះចងចាំ ដើម្បីឆ្លើយឡើងវិញបាន។ នៅក្នុងប្រព័ន្ធដែលគេប្រើប្រាស់មកលើ មីឡូសឺវិច នោះ គឺឯកសារវាជាផ្នែកមួយនៃសំណុំរឿងទាំងមូល។

[១២:០០:៤៦]

ហើយអង្គជំនុំជម្រះអាចសម្រេចហើយ ថាតើផ្នែកណាខ្លះនៃឯកសារក្នុងសំណុំរឿងអាចប្រើប្រាស់បាន? គាត់ជាសាក្សីមួយពិសេស គឺថាគាត់អាចត្រូវផ្តល់សក្ខីកម្ម គាត់អាចឆ្លើយទៅនឹងសំណួរទាំងឡាយដទៃទៀតបានដោយមិនចាំបាច់មើលឃើញឯកសារ ហើយសួរគាត់ទៅលើចំណុចជាក់លាក់នៅក្នុងលក្ខណៈមួយនាំមុខសាក្សីបែបហ្នឹងទេ។ ហេតុនេះឯងបានជាខ្ញុំជំទាស់នោះឯង។ បើធ្វើបែបនេះវាជាការងាកចេញហើយ នេះបច្ចេកទេសបែប។ គឺដោយសារតែគាត់ពិសេស គាត់មានចំណេះដឹងពិសេស ជាសាក្សីមួយមានលក្ខណៈពិសេសជាងគេដូច្នេះនោះទេ ដោយផ្តល់ព័ត៌មានទៅឲ្យគាត់ ហើយគាត់មិនបានដឹង។ ហើយប៉ុន្តែឥឡូវនេះ ដោយសារតែការផ្តល់ព័ត៌មានតាមរយៈឯកសារនេះ គាត់អាចគាត់នឹងអាចនឹងដឹង និងឆ្លើយនៅក្នុងលក្ខណៈមួយដែលយើងមិនដឹងអាចបាន។ ប៉ុន្តែដោយសារតែគាត់គឺទើបសិក្សា ទើបដឹងតាមរយៈឯកសារនេះតែប៉ុណ្ណោះ។

[១២:០១:៤៣]

ហេតុដូច្នេះឯងទើបខ្ញុំជំទាស់។ ខ្ញុំសូមអធ្យាស្រ័យ ក្នុងការដែលខ្ញុំសង្កត់ធ្ងន់ទៅលើចំណុចទាំងអស់នេះ។ ប៉ុន្តែខ្ញុំគិតថា ខ្ញុំលើកចំណុចមួយដែលជាការជួយទៅដល់អង្គជំនុំជម្រះ។ ប្រហែលជាលោកលោកស្រីចៅក្រមអាចសម្រេចនៅពេលក្រោយ ដោយសារតែវាដល់ពេលពិសាបាយថ្ងៃត្រង់ហើយ។ សូមអរគុណច្រើន។

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០២:៤០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ដោយបញ្ហានេះក៏ជាបញ្ហាស្មុគស្មាញ ហើយក៏អាចជាគំរូនៃបញ្ហាការដាក់ឯកសារចំពោះមុខសាក្សីទៅថ្ងៃមុខទៀតដែរ។ ហេតុដូច្នេះអង្គជំនុំជម្រះមិនទាន់ពិចារណាសម្រេចលើ

បញ្ហានេះទេ។ ស្ដាប់នូវសំណើសុំ ហើយនិងការជំទាស់របស់ភាគីរួចហើយ អ៊ីចឹងបញ្ហានេះអង្គជំនុំជម្រះនឹងសម្រេចនៅបន្ទាប់ពីពេលចូលមកវិញនៅរសៀលនេះ។

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាក ដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះនៅរសៀល សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

[១២:០៣:១៩]

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់សាលសវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។ ហើយដូចគ្នា គឺអនុរក្សមន្ទីរឃុំឃាំងនាំលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី ហើយឲ្យអញ្ជើញគាត់មកកាន់សាលសវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣៤ នាទី)*

[១៣:៣៤:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គសវនាការប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្ដល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីបន្តសំណួរដេញដោលចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះសម្រេចអំពីការជំទាស់នៅក្នុងការដាក់ឯកសារចំពោះមុខសាក្សីដេញដោលដូចខាងក្រោមនេះ៖

ឯកសារទាំងឡាយដែលភាគីដាក់នៅចំពោះមុខសាក្សី ដើម្បីដេញដោលប្រសិនបើសាក្សីឆ្លើយថាខ្លួនមិនធ្លាប់បានឃើញឯកសារនោះពីមុនមកទេ នោះឯកសារនោះ ភាគីត្រូវដកចេញពីសាក្សី ត្រឡប់មកវិញ។ ហើយការតាំងសំណួរ គឺអាចសួរដេញដោលបាននូវអ្វីដែលពាក់ព័ន្ធដែលភាគីនោះមានបំណងក្នុងការតាំងសំណួរចំពោះសាក្សី។

(ចៅក្រមពិភាក្សាគ្នា)

[១៣:៣៥:៤៨]

សូមអញ្ជើញលោកស្រីចៅក្រម ដើម្បីបញ្ជាក់បន្ថែមទៀត ដោយសារមានការបកប្រែថា មិនច្បាស់លើបញ្ហាសម្រេចអម្បាញ់មិញនេះ។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ នេះគឺពាក់ព័ន្ធទៅនឹងបញ្ហាបកប្រែ។ ខ្ញុំសូមបញ្ជាក់នូវអ្វីដែលលោកប្រធានទើបតែជម្រាបជូនអម្បាញ់មិញ។ ផ្នែកទីមួយ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនោះគឺច្បាស់ហើយ សាក្សីទាំងឡាយណាដែលត្រូវបានគេបង្ហាញឯកសារ ហើយមិនអាចថា ហើយថាមិនដែលឃើញឯកសារនោះទេ នោះត្រូវដកឯកសារនោះចេញពីអេក្រង់កុំព្យូទ័រ ឬឯកសារចេញពីមុខជន-- ពីសាក្សី។

[១៣:៣៦:៤៥]

ដូច្នេះ តាមរយៈនេះគឺថា ភាគីអាចតាំងសំណួរទៅសាក្សីរូបនោះ ទៅលើឯកសារនោះបាន។ ខ្ញុំយល់ថា ប៉ុណ្ណេះប្រហែលជាច្បាស់ហើយ សម្រាប់ភាគីទាំងអស់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវសាក្សីមានឯកសារនៅចំពោះមុខខ្លួនទេ? មន្ត្រីរដ្ឋបាលតុលាការដកហូតយកឯកសារនោះត្រឡប់មកវិញ!

សូមប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការសួរដេញដោល។

[១៣:៣៧:៣៥]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ នៅក្នុងឯកសារនេះ គឺបាននិយាយអំពីមាគ៌ាបដិវត្តន៍សង្គមនិយម គឺមានដកស្រង់និយាយថា បក្សសំដៅកម្ទេចសំណល់លើវណ្ណៈជិះជាន់។ បើប្រៀបធៀបទៅនឹងចំណេះដឹងនិងបទពិសោធន៍--

**ប្រធានអង្គជំនុំ៖**

អស់ថ្មហើយ ផ្តល់ថ្មទៅឲ្យសាក្សីថ្ម!

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ដោយសារតែពេលនេះកំពុងតែដូរថ្ម អ៊ីចឹងខ្ញុំសូមប្រើឱកាសនេះ គឺបញ្ហាដែលនៃការតាំងសំណួរ ខ្ញុំសូមត្រឡប់ទៅពីមុនបន្តិច។ តាមដែលខ្ញុំយល់គឺថា លោកស្រីចៅក្រម ខាតវ៉ាយថ៍ ដែលបញ្ជាក់នោះ គឺថា យើងអាចប្រើប្រាស់អ្វីដែលមាននៅក្នុងឯកសារ។ ប៉ុន្តែមិនត្រូវយោងថា អ្វីដែលមាននៅក្នុងឯកសារទេ។ មិនត្រូវនិយាយថា ឯកសារនេះនិយាយថា ដូច្នេះ និយាយថាអ៊ីចេះ។ ខ្លឹមសារនៅក្នុងឯកសារមិនត្រូវយកមកប្រើ ហើយដោយយោងទៅលើនៅក្នុងឯកសារនេះ ឬក៏ខ្ញុំយល់ច្រឡំ ក៏មិនដឹង។ ប៉ុន្តែហាក់បីដូចជាយើងប្រើប្រាស់នូវវេទិកាដដែល ដូចពីព្រឹកមិញ ក្នុងរសៀលនេះ។

[១៣:៣៩:២៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីញ្ចៀម ស្មីត៖**

សូមអរគុណលោក លោកស្រីចៅក្រម។ ខ្ញុំយល់ថាមេធាវីការពារក្តីគឺថា វាពាក់ព័ន្ធទៅនឹងសំណួរ ដែលចោទសួរទៅលើបញ្ហាទាំងនេះ។ ដូច្នេះ មេធាវីការពារក្តីហាក់បីដូចជាញាប់ពេក។ បើវាពាក់ព័ន្ធទៅនឹងបញ្ហានាំមុខ ឧទាហរណ៍ថា នៅក្នុងឯកសារនេះ មានបញ្ហានេះ តើត្រឹមត្រូវទេ?

[១៣:៤០:០២]

ប្រហែលជាបើធ្វើដូច្នេះ ទើបមានបញ្ហា។ ក៏ប៉ុន្តែបើសំណួរសួរថានៅក្នុងឯកសារនេះ មានបញ្ហា តើលោកអាចផ្តល់យោបល់បានទេ ទៅលើបញ្ហានេះ? នេះវាជាទម្រង់នៃការតាំងសំណួរអាចទៅបាន។ ខ្ញុំគិតថាមេធាវីការពារក្តីដូចមិនបានបញ្ជាក់នេះ លុះណាតែវាជាសំណួរនាំមុខ ហើយទើបយើងខ្ញុំយល់ស្រប។ ប៉ុន្តែការដែលចង្អុលបង្ហាញបញ្ហាថា លោកជ្រាបទេ ខ្ញុំអាចសូមឲ្យលោកបញ្ជាក់ ឬផ្តល់យោបល់បានទេ នេះវាជាទម្រង់មួយនៃការតាំងសំណួរដែលអាចសួរលើសាក្សីរូបនេះបានតាមដែលខ្ញុំយល់។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ការជំទាស់របស់ខ្ញុំម៉េចចាំបាច់យោងទៅក្នុងឯកសារនេះ។ តើលោកដឹងអំពីប្រធានបទនេះ ឬក៏អី? នៅតែជាសំណួរនាំមុខដដែលហ្នឹង។ ជាពិសេសនៅពេលដែលសាក្សីមើល

ឯកសារថា ខ្ញុំអត់ធ្លាប់បានដឹង មិនធ្លាប់បានឃើញទេ។ ម៉េចក៏នៅតែសួរថាដដែល ថាដឹងឬក៏អត់? គាត់អាចឆ្លើយថា ដឹង ឬក៏អត់ក៏មិនត្រូវនិយាយថា មាននៅក្នុងឯកសារទេ។ បើថាមាននៅក្នុងឯកសារនោះមានន័យថា ជាការផ្ដល់ព័ត៌មានទៅឲ្យសាក្សីដដែលហ្នឹង។ ដូច្នេះយើងខ្ញុំសូមស្នើដោយសេចក្ដីគោរពថាមិនត្រូវមានសំណួរនាំមុខ។ សំណួរនាំមុខមិនជាការចាំបាច់នោះទេ។

[១៣:៤១:៤១]

**លោក វីណ្សៀម ស្មីត៖**

លោក លោកស្រីចៅក្រម ខ្ញុំមិនចង់ជជែកតវ៉ាម្ដងហើយម្ដងទៀតពេញមួយថ្ងៃនេះទេ ប៉ុន្តែជំហររបស់យើងខ្ញុំនោះ គឺថាបើសិនណាយើងសួរសំណួរបើកទៅលើសាក្សីនេះ នៅគ្រប់បញ្ហាទាំងអស់ទាក់ទងទៅនឹងអំឡុងនៃកម្ពុជាប្រជាធិប-- បក្សកុម្មុយនីស្ដកម្ពុជានោះនឹងត្រូវការរយៈពេលច្រើនថ្ងៃ ច្រើនសប្ដាហ៍ណាស់ ហើយយើងដឹងថាសាក្សីនេះ គឺថាគាត់បានពិនិត្យមើលឯកសាររាប់រយរាប់ពាន់ឯកសារឯណោះ។ ដូច្នេះអ្វីដែលមាននៅក្នុងឯកសារនេះ គឺជាបញ្ហាដែលបានលើកឡើងជាក់លាក់។ បើគាត់-- បើយើងមិនអាចចង្អុលបង្ហាញបញ្ហាជាក់លាក់ហ្នឹង ដើម្បីឲ្យគាត់ផ្ដល់ជាគំនិតយោបល់អីនោះទេ នោះយើងនឹងមិនអាចឈានទៅដល់ភាពច្បាស់លាស់ដែលអង្គជំនុំជម្រះចង់ដឹងនោះទេ។ យើងមិនអាចដឹងអំពីតម្លៃនៃភស្តុតាងបានទេ ឬក៏មិនដឹងអំពីប្រភេទនៃភស្តុតាងដែលសាក្សីរូបនេះអាចផ្ដល់បានទេ។

ដូច្នេះវាត្រូវតែមានធាតុណាមួយដែលអាចនាំសាក្សីនេះឆ្ពោះទៅកាន់ចំណុចណាមួយ ដើម្បីឲ្យសាក្សីរូបនេះឆ្លើយសំណួរទៅនឹងបញ្ហាជាក់លាក់នោះតាមដែលគាត់អាចឆ្លើយបាន។ បើមិនដូច្នោះទេយើងនិងបាត់តម្លៃសាក្សីនេះហើយ ពីព្រោះការដែលយើងនាំគាត់ឆ្ពោះទៅកាន់ចំណុចជាក់លាក់ណាមួយហើយចោទសួរគាត់ ហើយបើគាត់មិនដឹងទាល់តែសោះនោះយើងខ្ញុំនឹងបន្តទៅមុខទៀត។ ការធ្វើបែបនេះ គឺដើម្បីឲ្យអង្គជំនុំជម្រះបានយល់ជ្រាបបានច្បាស់។ ការសួរសំណួរនាំមុខជាការត្រឹមត្រូវហើយ-- វាមិនត្រឹមត្រូវទេ។ សូមអរគុណ។

[១៣:៤៣:៣៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៥:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ ដើម្បីដោះស្រាយបញ្ហានេះ ឲ្យបានជ្រះស្រឡះម្ដងហើយម្ដងទៀត ហើយបញ្ហាឯកសារនៅ

ក្នុងសំណុំរឿងក្តីនេះ យើងមានបញ្ហាច្រើនលើកច្រើសាហើយ។ ហើយដើម្បីដោះស្រាយបញ្ហាប្រឈម នៅពេលនេះ អង្គជំនុំជម្រះសូមប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបញ្ជាក់បន្ថែមដល់ភាគីដែលពាក់ព័ន្ធ ដើម្បីឲ្យបានយល់ជ្រួតជ្រាបអំពីកិច្ចដំណើរការនៃនីតិវិធីដែលដេញដោលនៅក្នុងលក្ខខណ្ឌនៃឯកសារ ដែលបានលើដាក់នៅចំពោះមុខសាក្សី ហើយសាក្សីបានបញ្ជាក់ថា មិន-- ខ្លួនមិនដែលបានដឹង បានឃើញនូវខ្លឹមសារ-- នូវឯកសារទាំងនោះពីមុនមក។

សូមអញ្ជើញ លោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ក្នុងគោលបំណងដើម្បីផ្តល់ការណែនាំទៅដល់មេធាវីសម្រាប់ភាគីទាំងអស់នេះ។ វិធានទីមួយ គឺបានលើកឡើងហើយ សេចក្តីសម្រេចទីមួយ គឺបើសាក្សីមិនធ្លាប់ដឹង បានឃើញឯកសារទេ នោះត្រូវដកឯកសារនោះ ចេញពីសាក្សីវិញ។ សេចក្តីសម្រេចទីពីរ គឺថាភាគីដែលតាំងសំណួរមិនមានសិទ្ធិពិនិត្យមើលឯកសារ ហើយថា កថាខណ្ឌមួយនៃឯកសារនេះ និយាយថាដូច្នេះ សូមផ្តល់មតិយោបល់មើល៍ យ៉ាងម៉េចដែរ? ប៉ុន្តែភាគីដាក់ឯកសារ-- ភាគីតាំងសំណួរអាចតាំងសំណួរដោយយោងទៅលើ តើវគ្គគន្លឹះដែលមាននៅក្នុងឯកសារនេះ។ ឧទាហរណ៍ ថាតើសាក្សីដឹងអំពីប្រធានបទនេះទេ? តើកាលដែលខ្ញុំលើកប៉ុណ្ណោះច្បាស់ទេ?

[១៣:៤៧:៥៥]

**លោក ម៉ៃខល កាណាវាស៖**

ច្បាស់ហើយ លោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។

សូមអញ្ជើញ តំណាងសហព្រះរាជអាជ្ញា!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ យោងតាមចំណេះដឹង និងបទពិសោធន៍របស់លោក ដែលលោកមានកន្លងមកនៅពេលនោះ។ តើលោកបានដឹងអំពីគោលនយោបាយដែលនិយាយអំពីមាគ៌ាបដិវត្តន៍

សង្គមនិយមដែរទេ? សូមលោកជួយរៀបរាប់អំពីបញ្ហានេះ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** មាគ៌ាសង្គមនិយម កសាងសង្គមនិយម និងការពារសង្គមនិយមនេះ។ វាជាគោលនយោបាយគ្រឹះ ក្រោយថ្ងៃ១៧ មេសា ១៩៧៥។ ការរៀនសូត្រវគ្គខាងសេនាធិការ ក៏មាននិយាយបញ្ហានេះ។ នៅក្នុងលក្ខន្តិកៈបក្សក៏និយាយបញ្ហានេះ។ សន្និបាត ស-២១ លើកដំបូង ក៏មាននិយាយពីបញ្ហានេះ។ ដូច្នេះ វាទូទៅ ទូទាំងប្រទេស។

[១៣:៤៩:២៦]

**ស៖** បាទ អរគុណ។ តើលោកមានការយល់ដឹងអ្វីបន្ថែមពីលើនេះទៀតដែរទេ?

**ឆ៖** ខ្ញុំសូមមិននិយាយលម្អិតថា អាម៉េចមាគ៌ាសង្គមនិយម អាម៉េចកសាងសង្គមនិយមទេ។ ក៏ប៉ុន្តែជាការតម្រូវដែលបក្សទាមទារឲ្យបក្ខជនគ្រប់រូបយល់នៅក្នុងរយៈកាលថ្មី គឺធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម ឲ្យបានឆាប់រហ័ស ឲ្យបានល្អ។ ដូច្នេះ ខ្លឹមសារផ្សេង។ នេះ ខ្ញុំនិយាយពីកិច្ចតម្រូវដែលបក្ស តម្រូវឲ្យបក្ខជនគ្រប់រូបធ្វើ។ បក្ខជននៅ ស-២១ ក៏ធ្វើ នៅកងពល ៧០៣ ក៏ធ្វើនៅឯណាក៏ធ្វើដែរ។

**ស៖** បាទ អរគុណ។

[១៣:៥០:២០]

**លោក សេង ប៊ុនឃាង៖**

លោកប្រធាន ខ្ញុំអស់ហើយ ៗសហការីខ្ញុំនឹងបន្តសំណួរតទៅទៀត។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរអស់លោក លោកស្រីទាំងអស់។

**សួរដោយលោក វីល្លៀម ស្មីត៖**

លោក កាំង ហ្កេកអ៊ាវ សម្រាប់មួយថ្ងៃកន្លះនេះ គឺថាយើងបានសួរលោកពាក់ព័ន្ធទៅនឹងបញ្ហាបក្សកុម្មុយនីស្តកម្ពុជា ក៏ដូចជាមនោគមន៍វិជ្ជា និងគោលនយោបាយរបស់បក្ស។ ជាពិសេសនៅក្នុងអំឡុងមុនឆ្នាំ៧៥ និងអំឡុងពី១៩៧៥ ទៅដល់១៩៧៩។ សូមអរគុណ លោក លោកស្រីចៅក្រមដែល

បានផ្តល់ឱកាសនេះ។

ឥឡូវខ្ញុំសូមចូលទៅដល់ប្រធានផ្នែកមួយទៀត ទាក់ទងទៅនឹងរចនាសម្ព័ន្ធរបស់បក្ស គឺរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយយើងភ្ជាប់ទៅដល់រចនាសម្ព័ន្ធនៃបញ្ហាទំនាក់ទំនង និងតួនាទីរបស់ជនជាប់ចោទ។

[១៣:៥១:៥៤]

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរលោកទៅលើបក្សកុម្មុយនីស្តកម្ពុជា ដែលជាអង្គការមួយ គឺនិយាយត្រឡប់ និយាយចន្លោះពី៧៥-៧៩។ ហើយក៏ដូចជាពីឆ្នាំមុនៗផងដែរ។ ដូច្នេះលោកដឹងហើយ គឺយើងត្រឡប់ចូលទៅនឹងសំណួរនិយាយអំពីលក្ខន្តិកៈបក្ស ហើយព្យាយាមជួយដល់លោក លោកស្រីចៅក្រមថាតើបក្សកុម្មុយនីស្តកម្ពុជាហ្នឹងដំណើរការទៅដោយរបៀបណា។ ដូច្នេះសំណួរទីមួយគឺ លោកនិយាយពីមុននេះបន្តិចថាបក្សកុម្មុយនីស្ត ជាពិសេសនៅក្នុងលក្ខន្តិកៈរបស់បក្សតែម្តង ដែលថាសមាជិកបក្សទាំងអស់មានកាតព្វកិច្ចកសាងបដិវត្តន៍។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើលោកធ្លាប់ដែលបានឃើញលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាដែរទេ?

[១៣:៥៣:៣២]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាមានបីជំនាន់។ ជំនាន់ទីមួយ លក្ខន្តិកៈបក្សឆ្នាំ១៩៦០ ខ្ញុំបានរៀននៅឆ្នាំ១៩៦៧។ ជំនាន់ទីពីរ ខ្ញុំបានរៀននៅឆ្នាំ១៩៧២។ ហើយលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាជំនាន់ទីបី ខ្ញុំបានរៀន ហើយមានវគ្គបង្រៀនទៅទៀត ហូរហែ។ នៅ-- ខ្ញុំបានរៀននៅឆ្នាំ១៩៦៦, ៦៦។

**ស៖** ទាក់ទងទៅនឹងលក្ខន្តិកៈនៅក្នុងឆ្នាំ១៩៦០នោះ គឺជាលើក-- ឱកាសលើកទីមួយហើយដែលលោកបានឃើញលក្ខន្តិកៈហ្នឹង?

**ឆ៖** បាទ ខ្ញុំបានឃើញនៅពេលនុ៎ង ហើយបានរៀនច្បាស់លាស់។

[១៣:៥៥:០០]

**ស៖** តើលោកបានសិក្សាលក្ខន្តិកៈឆ្នាំ១៩៧១ ដែរទេ?

**ឆ៖** លក្ខន្តិកៈបក្សឆ្នាំ១៩៧១ ខ្ញុំរៀនផ្ទាល់ខ្លួន ជាប់ជាហូរហែ។

**ស៖** ហើយទាក់ទងទៅនឹងលក្ខន្តិកៈ ១៩៧៦ តើលោកបានសិក្សាដែរទេ?

**ឆ៖** លក្ខន្តិកៈបក្សឆ្នាំ១៩៧៦ ខ្ញុំរៀន តាមវគ្គដែលមេបង្រៀនផង លោកគ្រូ សុន សេន បង្រៀន

នៅក្នុងវគ្គសិក្សាផង។ ភស្តុតាង គឺនៅក្នុងកំណត់ហេតុ ក.ណ.ហ ១៦៦។

**ស៖** តើលោកឃើញថា នៅក្នុងលក្ខន្តិកៈ ១៩៦០ នោះ អ៊ំ! ១៩៧៦ តើលោកគ្រាន់តែបានឃើញ ឬក៏ លោកបានសិក្សាវាតែម្តង?

**ឆ៖** ខ្ញុំវង្វេងហើយ សូមលោកបញ្ជាក់ម្តងទៀត លក្ខន្តិកៈឆ្នាំណា? ដែលលោកសួរខ្ញុំអំមិញ អាចុងក្រោយនេះ លក្ខន្តិកៈឆ្នាំណា?

**ស៖** តើនៅពេលណាដែលលោកឃើញលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឆ្នាំ១៩៧៦? តើលោកចាំទេឆ្នាំណា ពេលណាដែលលោកបានឃើញជាលើកដំបូងនោះ?

**ឆ៖** គឺក្នុងឆ្នាំ១៩៧៦ នេះឯង។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ តើគោលបំណងរបស់លក្ខន្តិកៈនេះមានគោលបំណងអីដែរ? តើវាមានជាប្រភេទនៃច្បាប់មានគោលបំណងអីដែរ?

[១៣:៥៧:២៦]

**ឆ៖** លក្ខន្តិកៈវាជាមូលដ្ឋានគ្រឹះរបស់បក្ស។

**ស៖** លោកយល់ស្របជាមួយខ្ញុំទេថា លក្ខន្តិកៈកំណត់ និងរៀបរាប់ កត់លក្ខខណ្ឌសម្រាប់ចូលជាសមាជិកបក្ស ក៏ដូចជាលក្ខខណ្ឌនៃកាតព្វកិច្ចរបស់សមាជិកបក្សនៅក្នុងពេលនោះ? សំដៅថា គឺការទទួលខុសត្រូវរបស់សមាជិកបក្ស។

**ឆ៖** បញ្ហានេះខ្ញុំសូមវិភាគបញ្ហាលក្ខន្តិកៈរបស់ខ្ញុំ របស់បក្សខ្ញុំ។ លក្ខន្តិកៈឆ្នាំ១៩៦០ ខ្ញុំភ្លេចខ្លះហើយ ដូច្នេះខ្ញុំសូមប្រៀបធៀបថា លក្ខន្តិកៈបក្សឆ្នាំ១៩៧០ និងលក្ខន្តិកៈបក្សឆ្នាំ១៩៧៦ ប្លែកគ្នា អត់ប្លែកគ្នា អ៊ំនែ! អត់ប្លែកគ្នាទេ ចែកជាពីរផ្នែក។ ផ្នែកទីមួយ ចំណងជើងវា គេហៅថា “មាគ៌ានយោបាយ និងលាក់ការណ៍នយោបាយជាមូលដ្ឋានរបស់បក្ស”។ នោះគឺជាមាគ៌ានយោបាយសតិអារម្មណ៍ និងចាត់តាំង ដែលបក្សទាមទារឲ្យបក្ខជនគ្រប់រូបពុះពារ អនុវត្ត បំពាក់បំប៉នឲ្យខ្លួនឯងឲ្យបាន។ ផ្នែកទីពីរ វាជាមាគ៌ាចាត់តាំង។ លោកព្រះរាជអាជ្ញាសួរខ្ញុំអំមិញ ចូលក្នុងមាគ៌ាចាត់តាំងហ្នឹងហើយ បក្ខជនគ្រប់រូបត្រូវបំពេញភារកិច្ចបែបនេះ ទទួលវិន័យបែបនេះ ស្អីៗទាំងអស់។ ហ្នឹងចូលមាគ៌ាចាត់តាំងរបស់បក្ស។

[១៣:៥៩:៤៨]

**ស៖** លោក លោកស្រីចៅក្រម គឺថាខ្ញុំអាចបង្ហាញលក្ខន្តិកៈ គឺឯកសារ E3/130 ERN ជាភាសាខ្មែរ 00530007 អង់គ្លេស 005338 ហើយជាភាសាអង់គ្លេស 0018422 ដល់ 00184047

ហើយជាភាសាបារាំង 00292914 ដល់ 00292934។ យើងមានឯកសារជាក្រដាសសម្រាប់ដាក់បង្ហាញជូនសាក្សីផងដែរ ហើយក៏ស្នើសុំឲ្យបង្ហាញជូនឯកសារនេះលើអេក្រង់ៗកុំព្យូទ័រនេះ បើសិនជាមានការអនុញ្ញាតពីអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយមន្ត្រីរដ្ឋបាលតុលាការយកឯកសារពីសហព្រះរាជអាជ្ញាជូនទៅសាក្សីពិនិត្យ។

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សីពិនិត្យ)*

[១៤:០១:១១]

**លោក វីណ្ឌៀម ស្មីត៖**

ថាតើយើងខ្ញុំអាចស្នើសុំបង្ហាញក្នុងពេលដែលមិនទាន់ភ្លើងអ៊ីចេះបានទេ?

**សួរដោយ លោក វីណ្ឌៀម ស្មីត៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ ប្រសិនណាលោកមើលទៅលើឯកសារ E3/130 នេះ តើលោកបានជ្រាបទេ? លោកអាចបញ្ជាក់ជូនយើងខ្ញុំបានទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** បញ្ជាក់ថាម៉េច?

**ស៖** តើលោកអាចប្រាប់តុលាការបានទេថា តើវាជាលក្ខន្តិកៈ៦១ ឬក៏៧១ ឬក៏លក្ខន្តិកៈ៧៦?

**ឆ៖** លក្ខន្តិកៈបក្សនេះ លក្ខន្តិកៈ៧៦។

**ស៖** តើនេះជាលក្ខន្តិកៈដែលលោកបានបង្រៀននៅពេលដែលលោកមានតួនាទីនៅស-២១ នោះមែនទេ?

**ឆ៖** លក្ខន្តិកៈបក្សនេះ មេយកទៅបង្រៀន។ ឯចំណែកខ្ញុំបានលក្ខន្តិកៈនេះមក ខ្ញុំរៀនផ្ទាល់។ បក្ខជនគ្រប់រូប គឺរៀនផ្ទាល់ ខ្ញុំអត់បានបង្រៀនលក្ខន្តិកៈនេះទេ។

**ស៖** លោកបានរៀនសូត្រពីលក្ខន្តិកៈនេះ តើលក្ខន្តិកៈនេះឆ្លុះបញ្ចាំងត្រឹមត្រូវអំពីការយល់ដឹងរបស់លោកក្នុងលក្ខណៈវិនិច្ឆ័យជាសមាជិកបក្ស ក៏ដូចជាកាតព្វកិច្ចរបស់បក្ខជនចន្លោះពី៧៥ ទៅ ៧៩ ឬក៏ចន្លោះពី ៧៦-៧៩ នេះ។

[១៤:០៣:២៧]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា បក្ខជនគ្រប់រូបដែលភ័យព្រួយនឹងការងាររបស់ខ្លួន និងអាយុជីវិតរបស់ខ្លួន ត្រូវគិតគូរភាគទីមួយ ផ្នែកទីមួយនៃក្នុងលក្ខន្តិកៈនេះជាសំខាន់។ ឯចំណែកផ្នែកទីពីរ វាដោះស្រាយបានតាមការប្រជុំជីវភាពបក្សរាល់ខែ។ ដូច្នេះ បើមិនរៀនផ្នែកទីមួយពីទំព័រ១០០៧ ដល់ទំព័រ១២--០១២ ទេ លំបាកក្នុងការកសាងខ្លួនខ្លាំងណាស់។ ដូច្នេះបក្ខជនគ្រប់រូបត្រូវពិនិត្យពិច័យបញ្ហានេះឲ្យមែនទែន។

**លោក វីល្លៀម ស្មីត៖**

លោក លោកស្រីចៅក្រមថា តើខ្ញុំអាចស្នើសុំឲ្យមន្ត្រីសំណុំរឿងគាត់បង្ហាញនូវឯកសារនេះលើអេក្រង់ ដើម្បីយើងបង្ហាញនូវផ្នែកផ្សេងទៀត ដើម្បីអាចឲ្យមើលឃើញទាំងអស់គ្នា។

**ស៖** លោក កាំង ហ្កេកអ៊ាវ ជំពូកទីពីរ នៃលក្ខន្តិកៈនេះទាក់ទងទៅនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសបក្ខជន។ អំពីលក្ខណៈសម្បត្តិ ដើម្បីជ្រើសរើសចូលក្នុងអង្គការដឹកនាំផ្សេងៗរបស់បក្ស តើលក្ខណៈសម្បត្តិទាំងនេះ គេយកមកអនុវត្តផ្ទាល់តែម្តង ឬយ៉ាងម៉េច?

**ឆ៖** ខ្ញុំសូម មុននឹងឆ្លើយចង់បញ្ជាក់បញ្ហាមួយ តើព្រះរាជអាជ្ញាអនុញ្ញាតឲ្យខ្ញុំបញ្ជាក់បញ្ហានេះទេ ទាក់ទងនឹងជំពូកទីពីរនេះ? ជំពូកទីពីរនេះៗ បើប្រៀបធៀបលក្ខន្តិកៈបក្សឆ្នាំ៧០ និងលក្ខន្តិកៈបក្សឆ្នាំ៧៥ដូចគ្នា មានលក្ខណៈសម្បត្តិ១០យ៉ាងនេះ។ ប៉ុន្តែលោកយកតែពីរនេះ ទៅផ្ទុំគ្នាទៅប្រៀបធៀបលក្ខន្តិកៈបក្សឆ្នាំ៦០ ខុសគ្នា។

[១៤:០៦:៣៣]

លក្ខន្តិកៈបក្សឆ្នាំ៦០ ចែងថា “បក្ខជនរូបណាដែលមានអាយុបក្ស១០ឆ្នាំឡើងទៅ បក្សនឹងពិនិត្យបេក្ខភាពមជ្ឈិមបក្សជូន” មកដល់លក្ខន្តិកៈបក្សឆ្នាំ៧០ ហើយនិង៧៦ យកលក្ខខណ្ឌ ១០(ខ) ជារបាំងបោះបង់ចោល លក្ខខណ្ឌអតីតភាពចោលហើយ។ ដូច្នេះក្នុងការអនុវត្តជាក់ស្តែងអ្នកណាអ្នកវិនិច្ឆ័យសម្រេចបញ្ហានេះ ១០(ខ) ជ្រើសរើសឲ្យឡើងថ្នាក់ គឺបក្សខាងលើ។ និយាយឲ្យចំ គឺបងទីមួយ និងបងទីពីរ ជាអ្នកជ្រើសរើសមនុស្សឲ្យឡើង។ តាមចិត្តគាត់ លុបចោលអតីតភាព។ នេះការយល់ដឹងរបស់ខ្ញុំក្នុងការអនុវត្តលក្ខណៈសម្បត្តិ១០យ៉ាងនេះ។

[១៤:០៧:៤១]

**ស៖** ដូច្នេះ បើសិនយើងខ្ញុំមិនយល់ច្រឡំទេ លក្ខណៈសម្បត្តិ១០យ៉ាងដើម្បីជ្រើសរើសចូលក្នុងអង្គការដឹកនាំផ្សេងៗរបស់បក្ស គឺត្រូវ-- បានដាក់ជំនួសចូលមកលក្ខន្តិកៈឆ្នាំ១៩៧១ ដើម្បីឲ្យក្លាយ ទៅ

ជា១លក្ខន្តិកៈសម្រាប់ឆ្នាំ៧៦ តើអ៊ីចឹងទេ?

**ឆៈ** លក្ខណៈសម្បត្តិ១០យ៉ាងនេះ ជារបស់ដែលលេខាបក្ស ប៉ុល ពត បង្កើតថ្មី ចាប់តាំងពីលក្ខន្តិកៈបក្សឆ្នាំ៧០ រហូតមក។ លក្ខន្តិកៈបក្សឆ្នាំ៦០ វាទៅផ្សេង។ លក្ខន្តិកៈបក្សឆ្នាំ១៩៧០ និង ៧៦ វាទៅផ្សេង។ ៧០ និង ៧៦ មានជំពូកហ្នឹងដូចគ្នា ១០(ខ)។

**សៈ** តាមដែលលោកដឹងអំពីលក្ខន្តិកៈបក្សរបស់ពេលនោះ ហេតុអ្វីបានជាលក្ខណៈសម្បត្តិទាំង ១០យ៉ាង ដើម្បីជ្រើសរើសចូលជាបក្ខជន ក្នុងអង្គការដឹកនាំផ្សេងៗរបស់បក្ស ម៉េចបានដាក់បញ្ចូលមកក្នុងលក្ខន្តិកៈ១៩៧១ នេះ?

[១៤:០៩:២៦]

**ឆៈ** យ៉ាងម៉េចបានជាគេបញ្ចូល។ ខ្ញុំសូមមិនឆ្លើយទេ ពិបាកណាស់។ ជារឿងគេដែលគេបញ្ចូល ក៏ប៉ុន្តែ ប្រសិនបើនិយាយពីប្រៀបធៀប ខ្ញុំអាចប្រៀបធៀបជូនបាន។

**សៈ** បើសិនជាលោកអាចមានមតិយោបល់អីថា ហេតុអ្វីបានជាលក្ខណៈសម្បត្តិទាំង១០យ៉ាងយកមកដាក់បញ្ចូលយ៉ាងដូច្នេះ ដោយសារតែលោកជាបក្ខជននៅក្នុងពេលនោះ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ?

**ឆៈ** ដំឡើងថ្នាក់បក្ខជនឲ្យចូលមកមជ្ឈិមបក្ស។ បើសិនជាគិតពីអាយុបក្ស វាជាលក្ខណៈវិនិច្ឆ័យមួយក្រៅខ្លួន ក្រៅអត្តនោម័តិរបស់មជ្ឈិមបក្ស របស់លេខា ហើយនិងអនុលេខា។ បើនិយាយអំពីលក្ខណៈសម្បត្តិ ១០(ខ) វិញ។ ឥឡូវ លោកមើល (ខ) ទីមួយ សាមគ្គីភាព រឹងប៉ឹង។ (ខ) ទីពីរ អនុវត្តមាគ៌ានយោបាយ។ ស្រេចនឹងគេថា អ្នកនេះអនុវត្តបានល្អ អ្នកនោះអនុវត្តមិនបានល្អ អាហ្នឹងស្រេចនឹងគេថាតើ។ ដូច្នេះ លក្ខណៈវិនិច្ឆ័យនៅលើអត្តនោម័តិរបស់លេខា និងអនុលេខាបក្ស។ នេះ វាខុសគ្នា។

**សៈ** មុននេះបន្តិច លោកនិយាយថា ដោយសារតែលក្ខន្តិកៈ ១៩៧១ គឺអតីតភាពនៅក្នុងបក្ស គឺមិនត្រូវបានយកមកពិចារណា ឬគិតគូរនោះទេ។ ហេតុអ្វីបានជាគេផ្លាស់ប្តូរយ៉ាងដូច្នេះ ឲ្យកើតមកជាលក្ខន្តិកៈ១៩៧១? ម៉េចក៏មិនយកអតីតភាពដែលមានពីមុនៗនេះមក រាប់បញ្ចូល?

**ឆៈ** បើកាលណាខ្ញុំឆ្លើយ វាទៅជាខ្ញុំពន្យល់ ទៅជាខ្ញុំអត្ថាធិប្បាយ ខ្ញុំសន្និដ្ឋាន។ ដូច្នេះ ខ្ញុំសុំគ្រាន់តែសូមប្រៀបធៀបប៉ុណ្ណឹង។

[១៤:១១:៥៦]

**សៈ** បើសិនខ្ញុំអាចស្នើសុំឲ្យលោកធ្វើសន្និដ្ឋាន ដោយសារតែលោកស្ថិតនៅក្នុងបក្ស។ លោក

មានតួនាទីដែលអាចធ្វើសេចក្តីសន្និដ្ឋានបែបនេះបាន។ តើខ្ញុំអាចសួរបានទេ?

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន មុននឹងសាក្សីឆ្លើយ ខ្ញុំសូមជំទាស់។ គឺគាត់មិនបានសួរឲ្យទៅសេចក្តីសន្និដ្ឋានទេ។ សួរឲ្យសាក្សីរូបនេះ ស្មានៗ បើសុំឲ្យសួរបាទ ឬទេ។ បើបាទ សួរទៅទៀត។ បើអត់ដឹងទេ គឺមិនត្រូវសួរទៀតទេ។ បើសួរទៅទៀត មានន័យថា វាជាការស្មានៗតែប៉ុណ្ណោះ ជាមតិយោបល់ស្មានៗ។ ដូច្នេះ មិនត្រឹមត្រូវទេ។ ត្រូវសួរថា បាទ ឬក៏ទេ។

**លោក វីណ្សៀម ស្មីត៖**

លោក លោកស្រីចៅក្រម សាក្សីមិនបានប្រើពាក្យថា ស្មាននោះទេ ឬក៏ដូចជាអ៊ីចឹងដូច្នេះទេ។ ដោយសារតែគាត់ជាសមាជិក ឬក៏ជាបក្ខជន ខ្ញុំអាចឲ្យគាត់ធ្វើសេចក្តីសន្និដ្ឋាន។ ប្រសិនជាខ្ញុំសួរសាក្សីថាតើគាត់និយាយដោយស្មានៗ ព្រាវៗ ឬក៏អត់នោះ គឺថានោះ ខ្ញុំនឹងបន្តទៅទៀត។

[១៤:១៣:០៩]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន លោក លោកស្រីចៅក្រម។ នេះគឺខ្ញុំសូមជំទាស់ទៀតហើយ បើសិនណា សាក្សីនិយាយថា គាត់ធ្លាប់អង្គុយជាមួយ ប៉ុល ពត ឬជាមួយអ្នកណា នៅពេលគេព្រាងលក្ខន្តិកៈបក្សនេះ ក៏ជាផ្នែកមួយគណៈកម្មាការដែលធ្វើសេចក្តីព្រាងនេះ។ ដូច្នេះ គាត់អាចមានចំណេះដឹងដោយផ្ទាល់ខ្លួន នៅពេលនោះ ខ្ញុំយល់ហើយ។ ប៉ុន្តែការសុំមតិយោបល់ ក៏ការដូចជាកាសុំឲ្យធ្វើសេចក្តីសន្និដ្ឋាន តែគាត់ធ្វើជាការស្មានៗទៅវិញ ដោយមិនប្រើពាក្យថា ដឹង ឬក៏មិនដឹងនោះ។ បើគាត់ថា ដឹង គឺថាគាត់អាចអះអាងមក។ ដោយសារថានៅក្នុង-- តាំងពីក្នុងសំណុំរឿង០០១ ក៏ដូចនៅក្នុងសំណុំរឿងនេះ គឺគាត់ជាកម្មាភិបាលថ្នាក់ទាបទេ។ គាត់គ្រាន់តែជាប្រធានស-២១។ បើគាត់ថា ដឹង នឹងសួរតទៅទៀត តែគាត់ថាមិនដឹងទេ។ ហើយសួរលើសពីនេះ គឺថាគាត់ប្រាកដជាស្មានៗទេ។ គំនិតយោបល់របស់ខ្ញុំនោះ គឺថាគំនិតយោបល់បែបនេះ ឬសេចក្តីសន្និដ្ឋានបែបនេះ គឺជាការជួយទៅដល់ខាងសហព្រះរាជអាជ្ញាដើម្បីផ្តល់នូវការដាក់បន្ទុកតែប៉ុណ្ណោះ។ ពេលនេះចម្លើយ វាជាចម្លើយមួយដែលមានវិមតិសង្ស័យហើយ។

ដូច្នេះ វាជាបញ្ហាមួយដែលមិនអាចដោះស្រាយទៅលើសំណុំរឿងនេះបានទេ។ ដោយសាតែចម្លើយបែបជាការស្មានៗបែបនេះ។

[១៤:១៤:៤៥]

**លោក វីល្មៀម ស្មីត៖**

លោកប្រធាន ខ្ញុំគិត-- នៅក្នុងឆ្នាំ១៩៧១ នៅពេលដែលលក្ខណៈសម្បត្តិនៃបក្ខជនត្រូវបានផ្លាស់ប្តូរនៅក្នុងលក្ខន្តិកៈហ្នឹង តើការផ្លាស់ប្តូរហ្នឹង វាកើតឡើងយ៉ាងដូចម្តេចដែរ? តើវាមានផលប៉ះពាល់អ្វីទៅដល់ប្រតិបត្តិការរបស់បក្ស? បាននន័យថាទាក់ទងទៅនឹងការដំឡើងឋានៈបក្ស ដំឡើងឋានៈ--

**ឆ៖** បច្ច័យដែលលេចចេញពីការដាក់លក្ខណៈសម្បត្តិ ១០(ខ) ឲ្យចូលមកជាធរមាននៅក្នុងលក្ខន្តិកៈបក្សចាប់តាំងពីឆ្នាំ១៩៧១ វាមានបច្ច័យយ៉ាងម៉េច? ខ្ញុំឃើញបក្ខជនមួយចំនួន គ្នាមានអាយុបក្សច្រើនហើយ ក៏ប៉ុន្តែបក្សអត់គិតគូរបញ្ចូលមជ្ឈិមទេ។ ឯចំណែកផ្ទុយទៅវិញ អ្នកខ្លះអាយុបក្សមិនច្រើនទេ តែគេបានឡើងឋានៈ។ នេះជាការពិនិត្យឃើញជាក់ស្តែង។ ដូច្នេះខ្ញុំជឿថា នេះជាបច្ច័យនៃការអនុវត្តលក្ខណៈសម្បត្តិ១០(ខ)។

**ស៖** សូមអរគុណ។ លោក កាំង ហ្កេកអ៊ាវ លក្ខន្តិកៈមួយនេះ គឺមានផ្នែកជាច្រើន ហើយយើងនឹងពិភាក្សានៅពេលក្រោយ។ ឥឡូវនេះយើងពិភាក្សាផ្នែកមួយចំនួន។ អ្វីដែលខ្ញុំចង់ពិភាក្សាជាមួយលោក គឺយើងពិនិត្យមើលទៅលើផ្នែកទៅតាមលំដាប់លំដោយ ដែលយើងចាប់ផ្តើមទីមួយ គឺដោះ--ទាក់ទងទៅនឹងផ្នែកដែលមានចំណងជើងថា គោលការណ៍ជាមូលដ្ឋាន ហើយនិងស្ថានភាពនយោបាយរបស់បក្សនៅក្នុងសម័យបដិវត្តន៍ថ្មី នៅក្នុងសង្គមកម្ពុជា។ ហេតុផលដែលខ្ញុំចង់ចាប់ផ្តើមទៅលើចំណុចនេះគឺថា ដើម្បីស្នើសុំឲ្យលោកជួយដល់តុលាការក្នុងការផ្តល់លើការពន្យល់មួយចំនួនទាក់ទងទៅនឹងពាក្យបក្សនីមួយៗ បាននន័យថា ពាក្យបច្ចេកទេសបក្សនីមួយៗ ដែលប្រើប្រាស់នៅក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា។

[១៤:១៧:១៩]

ពាក្យបច្ចេកទេសមួយចំនួននោះ អាចថាមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬក៏វាស្របទៅនឹងអ្វីដែលលោកបាននិយាយកាលពីពេលមុនទាក់ទងទៅនឹងមនោគមន៍វិជ្ជា ក៏ដូចជាគោលនយោបាយ។ ប៉ុន្តែដើម្បីធ្វើឲ្យវាច្បាស់លាស់ទៅលើអ្វីដែលបក្ស ដែលលក្ខន្តិកៈហ្នឹងចង់មានន័យហ្នឹង គឺខ្ញុំស្នើសុំឲ្យលោកបញ្ចេញមតិទាក់ទងទៅនឹងពាក្យបច្ចេកទេសនីមួយៗនៅក្នុងលក្ខន្តិកៈបក្សនោះ។ ដូច្នេះហើយគឺយើងអាចបកស្រាយ ហើយនិងយល់អំពីរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជាបាន។

ដូច្នេះ ខ្ញុំសូមចាប់ផ្តើមដោយពិនិត្យទៅលើគោលការណ៍ជាមូលដ្ឋានទីពីរ ហើយខ្ញុំសូមបង្ហាញនៅលើស្គ្រីន ដែលលោកឃើញនៅចំពោះមុខនេះ គឺវានិយាយថា បន្ទាប់ពី ក្រោយពីបក្សដឹកនាំ-- បក្ស

បន្តដឹកនាំ បក្សបន្តដឹកនាំបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម ដោយផ្តាច់មុខដាច់ខាត និងគ្រប់ផ្នែក។ ដូច្នេះ សំណួររបស់ខ្ញុំ គឺថាតើពាក្យកសាងសង្គមនិយម និងផ្តាច់មុខដាច់ខាត និងគ្រប់ផ្នែកហ្នឹងមានន័យយ៉ាងម៉េចដែរ?

[១៤:១៩:០២]

**ឆៈ** បក្សដឹកនាំបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម។ ហ្នឹងជាគ្រឹះមូលដ្ឋាននៃមាគ៌ានយោបាយក្រោយ១៧ មេសា។ មុន១៧ មេសា គេធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ។ ក្រោយ១៧ មេសា គេធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម។ អាម៉េចបដិវត្តន៍សង្គមនិយម? កម្មសិទ្ធិលើមធ្យោបាយផលិតកម្មទាំងអស់ជារបស់បក្ស។ ចាត់ចែងកម្លាំងពលកម្មសព្វបែបយ៉ាងបក្ស។ ផែនការសេដ្ឋកិច្ច ជាសេដ្ឋកិច្ចផែនការ។ ផែនការសេដ្ឋកិច្ចចេញពីបក្ស។ នេះបដិវត្តន៍សង្គមនិយម។ ចុះកសាងសង្គមនិយមយ៉ាងម៉េច? ធ្វើម៉េចឲ្យសតិអារម្មណ៍យើងម្នាក់ៗនេះ វាផុតគ្រួសារនិយម ស្វ័នតួនិយម បក្សពួកនិយម បុណ្យសក្តិនិយម អាណាធិបតេយ្យ ស្អីៗហ្នឹងគេបំបាត់ចោលហើយ គេខំពុះពារបំបាត់។ ហើយអ្នកណាអ្នកដឹកនាំ? បក្សកុម្មុយនីស្តកម្ពុជាដឹកនាំផ្តាច់មុខ។ ផ្តាច់មុខបានន័យថា "ម្នាក់ឯង"ៗ អត់មានបក្សណាមកលាយឡំទេ។ ពីព្រោះនៅក្នុងសង្គមកម្ពុជាវាមានគេឆ្លៀតបង្កើតបក្សច្រើនដែរ នេះបើតាមឯកសារដែលយើងខ្ញុំបានរៀន។ ដូច្នេះ គ្មានបក្សណាទេ គឺបក្សកុម្មុយនីស្តកម្ពុជាដែលដឹកនាំដោយ ប៉ុល ពត, នួន ជា ជាអ្នកដឹកនាំផ្តាច់មុខ។ ដាច់ខាត គឺពីរនាក់ហ្នឹងដឹកនាំដាច់ខាតតែម្តង មិនរាថយ ទៅមុខជានិច្ច។ គ្រប់ផ្នែក នគរបាលក៏បក្ស ប៉ុល ពត, នួន ជា យោធាក៏ ប៉ុល ពត, នួន ជា ដែរ សេដ្ឋកិច្ចក៏ ប៉ុល ពត, នួន ជា ពាណិជ្ជកម្មក៏ ប៉ុល ពត, នួន ជា។ នេះគ្រប់ផ្នែក។

[១៤:២១:២២]

**សៈ** សូមអរគុណចំពោះចម្លើយដ៏ក្បោះក្បាយ។ ដូច្នេះតើលោកចង់និយាយថា នៅពេលដែលពាក្យនិយាយថា "ផ្តាច់មុខ ដាច់ខាត" គឺមិនមានកន្លែងណាមួយសម្រាប់បក្សដទៃទៀតទេ មែនទេ?

**ឆៈ** ត្រឹមត្រូវ! ហើយក៏មិនមានសតិអារម្មណ៍ និងគោលនយោបាយរបស់វណ្ណៈណាផ្សេងទៀតដែរ គឺសតិអារម្មណ៍របស់វណ្ណៈកម្មករ។ បក្សកុម្មុយនីស្តកម្ពុជា ជាបក្សរបស់វណ្ណៈកម្មករ។

**សៈ** នៅក្នុងគោលការណ៍នៃរដ្ឋមួយនេះ គឺថាបក្សដឹកនាំដើម្បីសម្រេចឲ្យបាននូវការកសាង ហើយបន្តរហូតទៅដល់បដិវត្តន៍សង្គមនិយម។ តើលោកអាចជម្រាបបានទេ ថាតើវាមានភាពខុសគ្នាយ៉ាងម៉េចដែររវាងបដិវត្តន៍សង្គមនិយម និង-- រវាងបដិវត្តន៍សង្គមនិយម និង អ៊ំ--

**អ្នកបកប្រែ៖**

លោកចៅក្រម អ៎! លោកប្រធានប្រធាន អ្នកបកប្រែមានបញ្ហាជាមួយនឹងពាក្យបច្ចេកទេស។ សូមឲ្យសហព្រះរាជអាជ្ញានិយាយសាជាថ្មីម្តងទៀត។

[១៤:២២:៤៨]

**ប្រធានអង្គជំនុំ៖**

សូមតំណាងសហព្រះរាជអាជ្ញាសួរជាថ្មីម្តងទៀត ព្រោះអ្នកបកប្រែមិនអាចបកប្រែបានដោយសារពាក្យបច្ចេកទេស។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោក កាំង ហ្គេកអ៊ាវ នៅក្នុងគោលការណ៍ទីពីរ គឺបានបញ្ជាក់ថា បក្សដឹកនាំ សម្រេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ហើយបន្តដឹកនាំបដិវត្តន៍សង្គមនិយម។ បញ្ហា-- សំណួរដែលខ្ញុំចោទសួរ គឺថាតើមានភាពខុសគ្នាយ៉ាងម៉េច រវាងបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ និងបដិវត្តន៍សង្គមនិយម?

[១៤:២៣:៤៥]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យវាមានពីរផ្នែក។ មួយផ្នែក គឺប្រជាជាតិ មួយផ្នែកទៀត គឺប្រជាធិបតេយ្យ។ ប្រជាជាតិ គឺដេញចក្រពត្តិ និងបរិវារ។ ប្រជាធិបតេយ្យ គឺដោះស្រាយឲ្យកសិករមានដីភ្ជួរ មានស្រែធ្វើ។ នេះជាសំខាន់។ ឥឡូវនេះ ១៧ មេសា វាសម្រេចៗ បានទាំងបដិវត្តន៍ប្រជាជាតិដេញចក្រពត្តិ និងបរិវារទៅហើយ សម្រេចបានទាំងបដិវត្តន៍ប្រជាធិបតេយ្យទៅទៀតផង។ ព្រោះដីស្រែទាំងអស់ មធ្យោបាយផលិតកម្មទាំងអស់ វាធ្លាក់មកក្នុងកណ្តាប់ដៃបក្ស ដែលជាបក្សរបស់វណ្ណៈកម្មករ។ ដូច្នេះ វាឈានទៅដល់សង្គមនិយមមួយកម្រិតធំទៅទៀត។

សរុបមកបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ខ្ញុំនិយាយឡើងវិញ បដិវត្តន៍ផ្នែកជាប្រជាជាតិ គឺដេញចក្រពត្តិ និងបរិវារ។ ប្រជាធិបតេយ្យ គឺធ្វើម៉េចឲ្យកសិករមានស្រែធ្វើ។ ហើយឥឡូវយើងចូលហួសទៅហើយ ចូលដល់សង្គមនិយមមួយកម្រិតយ៉ាងជ្រៅទៅហើយ។

[១៤:២៥:១៧]

**ស៖** សូមអរគុណ។ នេះជាចម្លើយដ៏ច្បាស់លាស់ ឥឡូវនេះ តើលោកអាចជម្រាបយើងបានទេថា តើពាក្យ "បដិវត្តន៍សង្គមនិយម" ហ្នឹងមានន័យយ៉ាងម៉េចដែរ?

**ឆ៖** "បដិវត្តន៍សង្គមនិយម" តាមពិត "បដិវត្តន៍សង្គមនិយម" និយាយអំពីការបង្កបង្កើនផលហើយនិងការបែងចែកផល។ គេថា "ពីម្នាក់ៗតាមសមត្ថភាព ត្រឡប់ទៅម្នាក់ៗវិញតាមសាច់ការ"។ នេះបដិវត្តន៍សង្គមនិយម គឺអ៊ីចឹង។ នេះគោលការណ៍នៃការបង្កបង្កើនផល និងបែងចែកផល។ ក៏ប៉ុន្តែ "បដិវត្តន៍សង្គមនិយម" វាន័យម៉្យាងទៀត "មធ្យោបាយផលិតកម្ម"។ "មធ្យោបាយផលិតកម្ម" វាស្ថិតនៅលើកណ្តាប់ដៃឯកជន ឬនៅលើកណ្តាប់ដៃបក្ស។ "បដិវត្តន៍សង្គមនិយម" នៅស្រុកខ្មែរសម្រេចដល់នៅក្នុងកណ្តាប់ដៃបក្សទាំងមូល។ ចម្ការកៅស៊ូ ក៏មកជារបស់បក្ស កូនស្រែមួយអំពករបស់កសិករ ក៏មកជារបស់បក្ស។

[១៤:២៦:៤០]

**ស៖** សំណួរចុងក្រោយទាក់ទងទៅនឹងប្រធានបទមួយនេះគឺថា តើបដិវត្តន៍សង្គមនិយមនៅពេលនោះត្រូវប្រើប្រាស់ដោយរបៀបណា ដើម្បីឲ្យ-- ដើម្បីធ្វើឲ្យប្រជាជន-- ថាតើប្រជាជនមានសិទ្ធិក្នុងការជ្រើសរើសជាផ្នែកនៃបក្សហ្នឹង ឬក៏អត់ទេ? បានន័យថាទាក់ទងទៅនឹងការផលិត។

**ឆ៖** យើងអាចនិយាយបានថា អត់ ក៏ថាបាន យើងអាចនិយាយថា តាមផ្នែក ក៏ថាបាន។ ជាក់ស្តែងកម្មករឧស្សាហកម្មដែលជម្លៀសទៅ គេដឹកបញ្ចូលមកវិញដាក់ក្នុងរោងចក្រដដែល។ ដូច្នេះគេចាត់ចែង ក៏ប៉ុន្តែតាមជំនាញរបស់យើង។ ដោយឡែក សហករណ៍ជាឡលត់ដំ គេហៅថា "ឡក្តៅ"។ យកវណ្ណៈផ្សេងៗទៀត ដែលសល់ពីកម្ទេចយកទៅដាក់ក្នុងហ្នឹង ឲ្យទៅជាកសិករ។ នេះគ្មានផ្នែកជ្រើសរើសទេ មិនមែនថាអ្នកឯងពីដើមធ្វើពេទ្យ ឥឡូវទៅធ្វើពេទ្យវិញទៅ។ នេះឯងពីដើមធ្វើគ្រូទៅធ្វើគ្រូវិញទៅ គ្មានទេ។ គឺត្រូវតែទៅស្រែ។

**ស៖** តើពួកគាត់មានជម្រើសដែរ ឬទេនៅពេលនោះ នៅពេលដែលគាត់ធ្វើការងារ?

**ឆ៖** គ្មានទេ។

[១៤:២៨:២៤]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅគោលការណ៍បន្ទាប់ ការពិតវានៅក្នុងគោលការណ៍ទីពីរទេ។ ដូច្នេះខ្ញុំសូមអានថា ហេតុដូច្នេះសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាគឺជាវណ្ណៈ-- គឺជាកសិករកម្មករ ដែលធ្វើការនៅជួរមុខ គឺជាអ្នកដែលមានការតាំងចិត្ត ហើយជាគំរូដ៏ល្អ។ ដូច-- តើវាមានភាព

ខុសគ្នាដែរឬទេ រវាងសមាជិកបក្សកុម្មុយនីស្តកម្ពុជាជាមួយនឹងប្រជាជនដែលមិនមែនជាសមាជិក? ទាក់ទងទៅនឹងការរំពឹងចង់បាន-- ដែលទាក់ទងទៅនឹងការរំពឹងដែលបក្សចង់បាន បានន័យថា តើទាក់ទងទៅនឹងការដែលបក្សចង់បាននៅក្នុងតួនាទីនៃបក្ស-- នៃបដិវត្តន៍កម្ពុជា?

[១៤:២៩:៤៨]

**ឆ៖** ធាតុពិតនេះ ឬក៏តួនាទីនេះ គេហៅថា ធាតុពិតជាកងឈានមុខរបស់បក្ខជន។ ជាកងឈានមុខរបស់បក្ខជន សមាជិកបក្សគ្រប់រូបត្រូវតែជាកងឈានមុខ គំរូជាងគេបំផុតអ៊ីចឹងឯង។ នេះជាការទាមទាររបស់បក្សទៅលើបក្ខជន។ ឯចំណែកមហាជនផ្សេងៗវាទៅតាមកម្រិតទៀត យុវកក ជាថ្នាលសម្រាប់បណ្តុះបណ្តាលមនុស្សឲ្យទៅជាបក្ខជន។ សហជីពកម្មករ ជួនអីវាជាថ្នាលបណ្តុះបណ្តាលមនុស្សទៅជាយុវកក ឬក៏បក្ខជន អាហ្នឹងបើគេបណ្តុះបណ្តាលទៅតាមថ្នាលវាបន្តិចៗ។ ដូច្នេះ ដំបូងគេលត់ដំមនុស្សនៅក្នុងកសិដ្ឋាន ជ្រើសរើសចាត់តាំងជាមេពួក មេក្រុមបណ្តើរៗទៅ។ នេះ គឺអ៊ីចឹង។

**ស៖** តើខ្ញុំអាចនិយាយបានទេថា តើមានសមាជិកបក្សកុម្មុយនីស្តប៉ុន្មានដែលមាននៅពេលនោះ? បានន័យថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំចង់និយាយពីចំនួនជាមធ្យមប៉ុណ្ណោះ។

[១៤:៣១:១៧]

**ឆ៖** អត់ដឹងទេៗ។

**ស៖** តើលោកអាចនិយាយបានទេថា ភាគច្រើននៃប្រជាជន (សូមទោស) គឺភាគច្រើននៃប្រជាជនហ្នឹងគឺជាសមាជិក ឬក៏មិនមែនជាសមាជិកបក្ស ឬមួយក៏លោកមិនអាចនិយាយ ឬមិនអាចប្រាប់យើងបានទេ?

**ឆ៖** ខ្ញុំគិតថាសមាជិកបក្សមានមិនដល់ប្រាំភាគរយនៃប្រជាជនកម្ពុជាទេ។ តិចជាងប្រាំភាគរយតិចជាង។

**ស៖** តើសមាជិកភាពនៃបក្សហ្នឹង តើសមាជិកបក្សហ្នឹងជាការស្ម័គ្រចិត្ត ឬក៏អត់ទេ?

**ឆ៖** ធម្មតាទេ មនុស្សយើងតែចូលធ្វើបដិវត្តន៍ វាចេះតែចង់បានឡើងនឹងគេហើយ។ ដូច្នេះចេះតែខំដើម្បីបានទៅជាសមាជិកបក្ស វាមានតួនាទីដឹកនាំ នេះជាបញ្ហាមួយ។ បញ្ហាពីរ គេឲ្យចូល ឬមិនចូលស្រេចលើគេ អ្នកឯងចង់យ៉ាងម៉េចក៏ដោយបើគេមិនឲ្យចូលចង់ឲ្យងាប់ មិនមែនដាក់ពាក្យសុំបានទេ។

[១៤:៣២:៥៩]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅគោលការណ៍ទីបួន គឺមានឃ្លាមួយនៅក្នុងគោលការណ៍នេះ ដែលខ្ញុំស្នើសុំឲ្យលោកជួយពន្យល់ ហើយឃ្លានេះបាននិយាយថា "បក្សយកលទ្ធិម៉ាក្ស-លេនីនមកអនុវត្តធ្វើជាមូលដ្ឋាននៃទស្សនៈរបស់ខ្លួន ដោយអនុវត្តៗសកម្មភាពម៉ាក្ស-លេនីន មកអនុវត្តឲ្យរស់រវើកតាមស្ថានភាពជាក់ស្តែងនៃប្រទេសកម្ពុជា តាមគោលការណ៍ភ្ជាប់ទ្រឹស្តីនិងការជាក់ស្តែងដាច់ខាត"។ ដូច្នេះសំណួររបស់ខ្ញុំគឺថា តើគោលការណ៍នេះចង់និយាយអំពីអ្វី? បានន័យថាគោលការណ៍ភ្ជាប់ទ្រឹស្តីនឹងការជាក់ស្តែងដាច់ខាត តើពាក្យនេះមានន័យយ៉ាងម៉េចដែរនៅក្នុងលក្ខន្តិកៈនេះ?

[១៤:៣៤:១៩]

**ឆ៖** លទ្ធិម៉ាក្ស-លេនីន ដែលយកមកអនុវត្តភ្ជាប់នឹងទ្រឹស្ត្រី គឺមាគ៌ាទាំងអស់ណាដែលបក្សកុម្មុយនីស្តកម្ពុជាសរសេរចេញ ជាឯកសារផ្សេងៗ ឯកសារសំខាន់ដំបូងបំផុត គឺមាគ៌ានយោបាយជាយុទ្ធសាស្ត្រឆ្នាំ១៩៦០ និងមាគ៌ាជាយុទ្ធវិធីប្រមូលកម្លាំងរណសិរ្សធំទូលាយឆ្នាំ១៩៦០ ហើយបានវាចេញជាលក្ខន្តិកៈ។ ដូច្នេះ ទាំងអស់នេះវាសុទ្ធតែយកលទ្ធិម៉ាក្ស-លេនីន មកអនុវត្តស្របទៅតាមសង្គមកម្ពុជា។ អ្នកដែលមានសិទ្ធិយកទ្រឹស្តីម៉ាក្ស-លេនីនមកអនុវត្តមានតែម្នាក់គត់គឺ លេខាបក្ស ប៉ុល ពត។ គ្មានអ្នកណាមានសិទ្ធិដឹងទេ។ ទៅដល់មានសិទ្ធិអ្នកផ្សេងទៀតដែរ ក្បាលម៉ាស៊ីនពីរ ទ្រឹស្តីពីរ មាគ៌ាពីរខុសគ្នា ដូច្នេះ មានតែម្នាក់គត់ គឺប៉ុល ពត។

**ស៖** សូមអរគុណ។ ដូច្នេះ នៅពេលដែលលោកនិយាយ គឺវាដើម្បីបង្កើតកម្លាំង តើយើងនិយាយអំពីកម្លាំងយោធា ឬក៏កម្លាំងពលកម្ម តើប្រភេទកម្លាំងមួយណា ដែលយើងកំពុងតែនិយាយ បានន័យថា តើយើងកសាងកម្លាំងបែបណា?

[១៤:៣៥:៥៧]

**ឆ៖** ទេ សូមទោស ខ្ញុំស្តាប់សំណួរអត់ទាន់បានទេ។ ស្រាប់តែចេញពីកម្លាំងអ្នកណា កំពុងនិយាយអំពីរឿងការភ្ជាប់ទ្រឹស្តី ទៅនឹងជាក់ស្តែង។

**ស៖** នៅក្នុងចម្លើយរបស់លោក លោកពិភាក្សាអំពីការកសាងកម្លាំង។ ដូច្នេះ ខ្ញុំសូមលើកសំណួរ គោលការណ៍ភ្ជាប់ទ្រឹស្តីនឹងការជាក់ស្តែងដាច់ខាត តើជាភ្ជាប់គោលការណ៍ជាមួយនឹងប្រជាជនដោយដាច់ខាត ឬមួយក៏អ្វីដែលផ្សេងពីនេះ?

**ឆ៖** អត់ទេ បកប្រែៗសេចក្តីដែលខ្ញុំអត្ថាធិប្បាយ ចម្លើយរបស់ខ្ញុំជាៗខ្មែរទៅអង់គ្លេសមានល្អៀង។ មានល្អៀងហើយ បានជាយើងស្តាប់គ្នាអត់បាន។ មានល្អៀងហើយ ដូច្នេះ ខ្ញុំសូមបញ្ជាក់ឡើង

វិញ ការដែលខ្ញុំនិយាយសូមបញ្ជាក់ឲ្យខ្លី ការយកលទ្ធិម៉ាក្ស-លេនីន មកអនុវត្ត ទៅតាមជាក់ស្តែងក្នុងសង្គមខ្មែរ គឺប៉ុល ពត អ្នកយកលទ្ធិម៉ាក្ស-លេនីននេះ មកច្នៃប្រឌិត ចេញជាមាគ៌ា ចេញជាឯកសារផ្សេងៗសម្រាប់អនុវត្ត។ ខ្ញុំបានលើកឧទាហរណ៍ ឯកសារសំខាន់ជាមូលដ្ឋានដំបូងមានពីរ គឺឯកសារមាគ៌ាជាយុទ្ធសាស្ត្រ និងមាគ៌ាជាយុទ្ធវិធីប្រមូលកម្លាំងរណសិរ្ស។ ប្រមូលកម្លាំងរណសិរ្ស នេះជាឈ្មោះឯកសារដែល ប៉ុល ពត គាត់ធ្វើ។

[១៤:៣៧:៤២]

ដូច្នេះ អ្នកដែលទៅទទួលម៉ៅផ្ទាល់មុខតែម្នាក់ឯងក្នុងការកសាងមាគ៌ា គឺ ប៉ុល ពត ។ កសាងយ៉ាងម៉េច? គឺយកលទ្ធិម៉ាក្ស-លេនីន មកអនុវត្តជាក់ស្តែងទៅតាមសង្គមខ្មែរ។ នេះ គឺខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹងឡើងវិញ។

**ស៖** ខ្ញុំនឹងបន្ត ប៉ុន្តែឥឡូវ ខ្ញុំសូមសួរលោកបន្តិច ថាតើចំណុចនេះ មានន័យថា វាជាគោលការណ៍ភ្ជាប់ទ្រឹស្តី ទៅនឹងការអនុវត្តជាក់ស្តែង បានន័យថា លទ្ធិម៉ាក្ស-លេនីន ទៅនឹងគោលនយោបាយដែលត្រូវអនុវត្ត។ តើគោលការណ៍នេះ ចង់មានន័យបែបនេះមែនដែរឬទេ?

**ឆ៖** ឧបមា ខ្ញុំលើកសភាពការណ៍ជាក់ស្តែងចុះ។ សង្គមខ្មែរមានវណ្ណៈប៉ុន្មាន? សង្គមខ្មែរមានវណ្ណៈប្រាំ ប៉ុល ពត អ្នកយកម៉ាក្ស-លេនីនមកភ្ជាប់ ថាតើត្រូវវាយវណ្ណៈណា មិនវាយវណ្ណៈណាទុកវណ្ណៈណា ប្រមូលវណ្ណៈណា។ នេះ ទាល់តែ ប៉ុល ពត បានសម្រេចបាន។ ច្នៃប្រឌិតបាន រៀបចំបាន។ ឧបមា នៅពេលដែលឈ្មោះ លន់ នល់ ហើយ ដេញ លន់ នល់ ចេញបាត់ហើយ។ លោតផ្លោះទៅដល់បដិវត្តន៍សង្គមនិយមជាងពាក់កណ្តាលហើយ។ នេះក៏ ប៉ុល ពត ច្នៃប្រឌិតមាគ៌ាទៅអ៊ីចឹង។ នេះជាមាគ៌ាបក្សដែលភ្ជាប់នឹងជាក់ស្តែង។ ជាក់ស្តែងនៅក្នុងសង្គមខ្មែរ វាឈ្មោះ លន់ នល់ គឺកម្ទេចបានស្ទើរៗទាំងអស់។ អាហ្នឹងហើយ ប៉ុល ពត គាត់លោតតែម្តង។ នេះ ដែលហៅថា ភ្ជាប់ទ្រឹស្តីទៅនឹងជាក់ស្តែង។ នេះ ខ្ញុំសូមជម្រាបប៉ុណ្ណឹង។

[១៤:៣៩:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សមលម្មនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការរបស់យើង។ អនុរក្សមន្ទីរឃុំឃាំងអញ្ជើញសាក្សីទៅកាន់បន្ទប់សម្រាប់សាក្សីរង់ចាំ ហើយនិងបង្គាប់ឲ្យនាំគាត់មក

កាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ ឲ្យបានមុនអង្គជំនុំជម្រះចូលកាន់អាសនៈ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៤:៥៩:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីណ្សៀម ស្មីត៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ មុនពេលយើងឈប់សម្រាក គឺលោកប្រាប់យើងចុងក្រោយថា តើបក្សកុម្មុយនីស្ដកម្ពុជាមានគោលការណ៍នៃការភ្ជាប់ទ្រឹស្ដីនិងការអនុវត្តជាក់ស្ដែង។ ឥឡូវនេះ ខ្ញុំសូមបន្តចូលទៅផ្នែកមួយទៀត គឺគោលការណ៍ទីបី ខ្ញុំសូមអានសង្ខេបៗទេ គឺនិយាយថា បក្សបានប្រកាន់ខ្លួនរបស់ខ្លួនដោយប្រកាន់យកជំហរស្មារតីតស៊ូដាច់ខាតមោះមុត ហើយគឺពាក់ព័ន្ធទៅនឹងវណ្ណៈអធន កម្លាត់វណ្ណៈអធន មូលធន សក្ដិភូមិ ចក្រពត្តិ និងពួកប្រតិកិរិយាទាំងអស់។

[១៥:០១:០៨]

ខ្ញុំដឹងថាលោកបានពិភាក្សាកាលពីព្រឹកមិញនេះ អំពីវណ្ណៈ ឬក៏ខ្លាំងរបស់បក្សកុម្មុយនីស្ដកម្ពុជា។ ប៉ុន្តែពេលនេះខ្ញុំគ្រាន់តែចង់សួរលោកថា សួរសំណួរមួយចំនួនទៅលើពាក្យពេចន៍ទាំងនេះ ដោយសារពាក្យពេចន៍ទាំងនេះបានប្រើប្រាស់នៅក្នុងលក្ខន្តិកៈនេះ គឺលក្ខន្តិកៈដែលជាច្បាប់គ្រប់គ្រងរបស់បក្សកុម្មុយនីស្ដកម្ពុជា។ នៅពេលដែលលក្ខន្តិកៈនិយាយថា គោលនយោបាយក្នុងការកម្ចាត់ពួកៗវណ្ណៈអធនពួកនេះ តើគេសំដៅទៅលើអ្នកណាដែរ?

សូមអង្គជំនុំជម្រះបង្ហាញឯកសារ។ នេះសូមបន្តបង្ហាញជាហូរហែនៅលើអេក្រង់ដើម្បីឲ្យសាក្សីគាត់អាចមើលឃើញ ក៏ដូចជាឯកសារក្រដាសដែលមាននៅចំពោះមុខគាត់។ អ៊ីចឹងគាត់មានជម្រើសពីរ។

[១៥:០២:២៨]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** លក្ខណៈដែលលោកចៅក្រមសួរខ្ញុំទេ អ៎!នែ៎ លោកព្រះរាជអាជ្ញាសួរខ្ញុំទេ។ ការបង្ហាញនៅលើអេក្រង់ទៅឯណាណោះនៅឡើយទេ។ សូមបង្ហាញឲ្យចំ។ សូមលោកឲ្យគេបង្ហាញឲ្យចំ។

កថាខណ្ឌទីប៉ុន្មាន?

**ស៖** ខ្ញុំគិតថា កំពុងតែបង្ហាញលោកនៅលើអេក្រង់នោះហើយ វាទាក់ទងទៅនឹងគោលការណ៍ទីបួននៃលក្ខន្តិកៈ ដោយចាប់ផ្ដើមប្រើពាក្យថា បក្សបំពាក់ និងប្រកាន់យក គឺទំព័រ 0053010។ ឃើញទេដែលលក្ខន្តិកៈចែងត្រង់នេះថា បក្ស គឺថាបំពាក់ និងប្រកាន់យកទស្សនៈអធន និងជីវទស្សនៈអធន។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ នៅក្នុងបរិបទត្រង់នេះនៃលក្ខខន្តិកៈថាតើពាក្យថា "អនុធន" នេះ "វណ្ណៈអនុធន" នេះមានន័យថាយ៉ាងម៉េចដែរ?

**ឆ៖** ដោយការប្រែភាសារអាក់រអួល ខ្ញុំសូមអនុញ្ញាតបញ្ជាក់លោកព្រះរាជអាជ្ញាបន្តិច។ សួរខ្ញុំអំពីអនុធន ឬអធន? អនុធន ឬអធន។ អធន បារាំងគេហៅថា "*ប្រូឌុយតារីយ៉ា*"។ ឯចំណែក អនុធន បារាំងគេហៅថា "*ពើទីត ប៊ូហ្សួរ*" ។ ឥឡូវអាណាមួយ?

**ស៖** គឺចង់សួរពាក្យថា "អនុធន" តែម្ដង ថាតើពាក្យ "អនុធន" នេះមានន័យថាម៉េច?

[១៥:០៥:០០]

**ឆ៖** អនុធន គ្រូបង្រៀនក៏ជាអនុធនដែរ ពេទ្យក៏ជាអនុធន។ បានន័យថា ជីវភាពមួយរួចខ្លួនមិនខាត-- ខ្វះខាតទេ ហើយអាចសល់បន្តិច តែក៏មិនទៅធ្វើជានាយទុនអីទៀតៗកើតដែរ។ ហើយពួកនេះពួកអនុធនច្រើនប្រើកម្លាំងខួរក្បាល អ្នកអនុធនគឺអ៊ីចឹង។ ដូចខ្ញុំអី ពីអង្គាល់ធ្វើគ្រូហ្នឹង គេហៅ "អនុធន" ហើយ។

**ស៖** ហើយពាក្យបន្ទាប់មកទៀត គឺពាក្យថា "នាយទុន" តើពាក្យថា "នាយទុន" នៅក្នុងលក្ខន្តិកៈនេះ មានន័យថាដូចម្ដេចដែរ?

**ឆ៖** នាយទុនៗ គឺអ្នកមានលុយសល់ ហើយរកស៊ីដោយយកមូលធនរបស់ខ្លួនទៅយកចំណេញច្រើនជាងការបញ្ចេញកម្លាំង។ កសិករ យើងគិតមើល គាត់ស្នូង ហ្នឹងបញ្ចេញកម្លាំងកាយ។ អនុធន

បញ្ចេញកម្លាំងខួរក្បាល។ ឯចំណែកនាយទុន គាត់មានលុយយកទៅ។ ដូច្នេះមានលុយសល់យកទៅរកស៊ី។ រកស៊ីជាដួញដូរ លក់ដូរ ឬក៏បើកហាងជំនួញធំៗ ហ្នឹងហៅថា “នាយទុន”។

[១៥:០៦:៥៣]

**ស៖** សូមអរគុណ ច្បាស់ណាស់។ ឥឡូវខ្ញុំសួរថា តើពាក្យថា “សក្តិភូមិ” នេះ នៅក្នុងលក្ខន្តិកៈនេះ ពាក្យ “សក្តិភូមិ” មានន័យថាដូចម្តេចដែរ?

**ឆ៖** “សក្តិភូមិ” មកពីពាក្យពីរម៉ាត់។ ពាក្យ “សក្តិ” ហើយនិងពាក្យ “ភូមិ”។ “សក្តិ” ប្រែជាមានបុណ្យសក្តិ យកបុណ្យសក្តិទៅរកលុយ យកបុណ្យសក្តិទៅរកបក្សពួក យកបុណ្យសក្តិទៅជិះជាន់គេ។ ឯចំណែក “ភូមិ” ប្រែថាដី អ្នកដែលមានដីធំ មិនធ្វើខ្លួនឯងទេ ប្រវាស់ឲ្យកសិករធ្វើ។ ហ្នឹងសក្តិភូមិម្ចាស់ដីៗ គេហៅថា “សក្តិភូមិម្ចាស់ដី”។

**ស៖** តើមានមធ្យោបាយរបៀបណាមួយ ដែលភ្ជាប់ពាក្យនេះទៅនឹងរាជវង្សានុវង្សដែរឬទេ?

[១៥:០៨:១៦]

**ឆ៖** នៅក្នុងឯកសារវិភាគវណ្ណៈរបស់ ប៉ុល ពត ណ៎ា មាន។ សក្តិភូមិរាជវង្សានុវង្សមាន៨០០គ្រួសារ អ៎ ហ្នឹងហើយ ៨០០ នាក់។ រាប់តាំងពីស្តេចសោយរាជ្យរហូតដល់កញ្ច្រែកកញ្ច្រាក់ គេហៅថាស្តេចក្តាមខ្យងនោះ មាននាទីជាម៉ម មាននាទីកែវអី ៨០០គ្រួសារ ៨០០នាក់ នេះបើតាមឯកសាររបស់ប៉ុល ពត។ អ្នកដែលយកបុណ្យសក្តិទៅជិះជាន់គេហ្នឹង ហៅថា “សក្តិភូមិ” ពិតជាភ្ជាប់ នៅក្នុងសង្គមខ្មែរពិតជាមានជាប់។

**ស៖** តើខ្ញុំសួរបានទេថា តើលោកយោងទៅឯកសារណាដែរ?

**ឆ៖** ឯកសារហ្នឹងចាស់ បែបគ្មាននៅក្នុងស្ដី *ប៊ីយ៉ូតែក* របស់យើងនេះ។ ឯកសារនេះចេញដូច ៦០ វិភាគវណ្ណៈក្នុងសង្គមខ្មែរ មានរាជវង្សានុវង្ស ៨០០គ្រួសារ។ សូមបន្ថែមបន្តិចទៀតទៅចុះ ប្រើប្រៀបធៀបទៅនឹងការវិភាគវណ្ណៈរបស់ ម៉ៅ សេទុង គាត់ធ្វើ។ ចិនអត់មានរាជវង្សានុវង្សទេ។

[១៥:០៩:៤៥]

**ស៖** តើលោកបានឃើញឯកសារហ្នឹងជាលើកដំបូងនៅពេលណាដែរ?

**ឆ៖** មិនមែនជាលើកដំបូងទេ តែម្តងគត់ គឺនៅមន្ទីរសម្ងាត់ក្បែរផ្សារអង្គស្នួល ហួសផ្សារអង្គស្នួលបន្តិចទៅ ដែលខ្ញុំជួប វន វ៉េត ទៅដេកមួយយប់ហ្នឹងខ្ញុំបានមើលឯកសារហ្នឹង។ ក្រៅផ្លូវការទេ អត់មានការចាត់តាំងទៅរៀនសូត្រទេ ដល់ឯកសារនេះវានៅ ខ្ញុំមើល ១៩៦៧។

**ស៖** តើលោកអាចជួយរំឭកដល់យើងខ្ញុំបានទេ ថាតើឆ្នាំនោះគឺជាឆ្នាំប៉ុន្មានដែរ?

**ឆ៖** ១៩៦៧ ចុងខែ៩ ឬក៏ដើមខែ១០។

**ស៖** សូមអរគុណច្រើន។ តើលោកអាចរៀបរាប់ពាក្យថា ចក្រពត្តិនៅក្នុងលក្ខន្តិកៈនេះ។ ពាក្យថា “ចក្រពត្តិ” មានន័យដូចម៉េចដែរ?

[១៥:១១:១៣]

**ឆ៖** “ចក្រពត្តិ” បើតាមភាសាបារាំងគេហៅ“*កាប់ពីតាល់លីស*” សំដៅតែអាមេរិកាំងមួយទេ។

**ស៖** ហើយពាក្យចុងក្រោយគឺ១បំបាត់ពួកប្រតិកិរិយាទាំងអស់ តើពួកប្រតិកិរិយាទាំងអស់ហ្នឹងសំដៅទៅលើអ្នកណាដែរនៅក្នុងលក្ខន្តិកៈនេះ?

**ឆ៖** “ប្រតិកិរិយា” បានន័យថា សំដៅអ្នកប្រឆាំងបដិវត្តន៍ អ្នកប្រឆាំងប្រជាជន។ ប្រឆាំងបដិវត្តន៍ជាសំខាន់។ លោកឃើញហើយនៅក្នុង ន៉ែ រដ្ឋធម្មនុញ្ញ “សាសនាប្រតិកិរិយា”។ ពាក្យមួយម៉ាត់ហ្នឹង ដែលប្រើច្បាស់មែនទែន គឺសាសនាប្រតិកិរិយា។ ដូច្នេះ សំដៅសាសនាណាដែលមានការទាក់ទងជាមួយនឹងអាមេរិក ជាពិសេសប្រូតេស្តង់ហ្នឹងតែម្តង។

[១៥:១៣:០៣]

**ស៖** តើពាក្យនេះ យកសំដៅទៅលើសាសនាដទៃទៀត តែទៅលើប្រូតេស្តង់នេះមួយទេ?

**ឆ៖** ន័យដើមរបស់វា គឺប្រូតេស្តង់ ក៏ប៉ុន្តែដោយកាតូលិក ស្ថិតនៅក្រោមអំណាចវ៉ាទីកង់ផ្តាច់មុខ ក៏សំដៅ វ៉ាទីកង់កាតូលិកដែរ។

**ស៖** សូមអរគុណច្រើន។ នៅក្នុងលក្ខន្តិកៈពាក្យថា “ដាច់ខាត” គឺត្រូវបានយកមកប្រើប្រាស់ជាញឹកញាប់នៅក្នុងគោលការណ៍នេះនិយាយថា “បក្សត្រស៊ូដាច់ខាត” គឺនៅក្នុងគោលការណ៍ទីប្រាំ និយាយថា “បក្សកុម្មុយនីស្តកម្ពុជាប្រកាន់ខ្ជាប់និងដាច់ខាត” នៅក្នុងបរិបទនៃលក្ខន្តិកៈនេះ ថាតើវាមានន័យយ៉ាងម៉េចដែរចំពោះពាក្យថា “ដាច់ខាត” នេះ?

**ឆ៖** អរគុណ។ នេះនិយាយចំកថាខណ្ឌ មួយកថាខណ្ឌហើយ។ ពាក្យ “ដាច់ខាត” ដែលប្រើនៅក្នុងកថាខណ្ឌនេះ បានន័យថា ធ្វើដោយជំនឿស៊ុប មិនរារែក មិនស្ទាក់ស្ទើរ។ ធ្វើហ្នឹងធ្វើដោយជំនឿជឿស៊ុបមិនរារែក មិនស្ទាក់ស្ទើរ។

**ស៖** សូមអរគុណច្រើន។ ឥឡូវនេះបើយើងគោលការណ៍ទីប្រាំ គឺនិយាយថាបក្សកុម្មុយនីស្តកម្ពុជាប្រកាន់ខ្ជាប់ និងដាច់ខាតនូវទស្សនៈនឹងមាគ៌ាមហាជន។ តើឃ្លាត្រង់នេះ មានន័យយ៉ាងម៉េច ដែល

និយាយថា បក្សប្រកាន់ខ្ជាប់ និងដាច់ខាត នូវទស្សនៈនឹងមាគ៌ាមហាជននេះ?

[១៥:១៥:៣៣]

**ឆ៖** ទស្សនៈមហាជនដែលសរសេរនៅក្នុងកថាខណ្ឌនេះ។ ខ្ញុំនៅតែជឿថា វាមានកល្ខណៈជាទ្រឹស្តី ដាក់ឲ្យគ្រាន់តែល្អមើល តាំងពីដើមមក ខ្ញុំជឿអ៊ីចឹង។ មហាជនឯណាទៅចង់បានអង្ករមួយកំប៉ុងកន្លះមួយថ្ងៃ។ មហាជនឯណាដែលគេចាប់បងប្អូនទៅហើយ មិនៗឈឺ។ ដូច្នេះ ត្រូវមានកំហឹងដាច់ខាតចំពោះខ្មាំងហ្នឹង វាៗសង្កត់មកលើគេណ៎ា។ ដូច្នេះពាក្យ "ទស្សនៈមហាជន" "មាគ៌ាមហាជន" មានលក្ខណៈជាទ្រឹស្តី ដាក់ឲ្យគ្រាន់តែល្អមើល។ នេះ ខ្ញុំយល់។

**ស៖** បើសិនណាជាខ្ញុំ លោកមិនច្រឡំទេ គឺសក្ខីកម្មដែលលោកផ្តល់នេះ គឺជាទស្សនៈ និងមាគ៌ាដែលចេញមកពីបក្សកុម្មុយនីស្តកម្ពុជា មាគ៌ាមហាជននេះ គឺគ្រាន់ជាការភ្ជាប់ឲ្យល្អមើល តាមដែលលោកនិយាយអ៊ីចឹង តើលោកយល់ស្របថា អ៊ីចឹង ឬយ៉ាងម៉េច?

**ឆ៖** នេះ ជាគោលគំនិតរបស់ខ្ញុំ ដែលខ្ញុំយកមកបកស្រាយនៅពេលនេះ មុខតុលាការ។

**ស៖** សូមអរគុណ។ ប្រសិនណា យើងចុះទៅក្រោមបន្តិចនិយាយថា បក្ខជនម្នាក់ៗ ត្រូវទុកចិត្ត និងផ្អែកលើកម្លាំងមហាជន ហើយត្រូវទាក់ទងជិតស្និទ្ធជាមួយមហាជន។ តើវាមានន័យយ៉ាងម្តេចដែលថាបក្ខជនម្នាក់ៗត្រូវផ្អែកលើកម្លាំងមហាជន ត្រូវទាក់ទងយ៉ាងជិតស្និទ្ធជាមួយមហាជន។ តើមានន័យដូចម្តេច?

[១៥:១៨:១៤]

**ឆ៖** ក្នុងការអនុវត្តជាក់ស្តែង មេមួយៗ បើមិនដឹងសុខទុក្ខកូនចៅទេ មិនបានទេ។ នេះក្នុងការអនុវត្តជាក់ស្តែង។ ដូច្នេះ ដើម្បីសម្រេចផែនការរបស់បក្សបាន មេនីមួយៗ ត្រូវយកចិត្តយកថ្លើមកូនចៅបន្តិចដើម្បីសម្រេចផែនការបក្ស។ ក៏ប៉ុន្តែដល់សកម្មភាពខ្លះ ក៏គោងយកទ្រឹស្តីមកប្រើដែរ។ ឧទាហរណ៍ ប៉ះបងប៉ះប្អូន *(ឮមិនច្បាស់)* ត្រូវដាច់ខាត ត្រូវដាច់ខាតៗ។

**ស៖** ហើយឃ្លាបន្ទាប់សរសេរថា សមាជិកបក្សត្រូវនៅក្នុងចលនាបដិវត្តន៍របស់មហាជន ថា តើពាក្យថា "ត្រូវនៅក្នុងចលនាបដិវត្តន៍របស់មហាជន" ហ្នឹង មានន័យយ៉ាងដូចម្តេច?

[១៥:១៩:៤៥]

**ឆ៖** ខ្លឹមសារនេះ មានពន្យល់លម្អិត នៅក្នុងវគ្គសិក្សាដំបូង ដែលខ្ញុំមករៀននៅក្នុងភ្នំពេញ។ ចលនាមហាជន គឺម៉េច? ចលនាមហាជនគឺលោតផ្លោះ ទៅដល់បដិវត្តន៍សង្គម និងកសាងសង្គម

និយម។ ដូច្នេះ យើងត្រូវនៅក្នុងចលនានុំង។ កុំចេញទៅចលនា-- ពីចលនានុំងទៅនៅជាមួយក្រុមគ្រួសារ។ កុំចេញពីចលនានុំងទៅនៅជាមួយនឹងឯកជន។ ដូច្នេះ ត្រូវធ្វើពលិកម្មឯកជនចំពោះចលនាមហាជន។ ត្រូវធ្វើពលិកម្មក្រុមគ្រួសារខ្លួនឯងដើម្បីបដិវត្តន៍ ដើម្បីចលនាមហាជនដែលកំពុងមហាលោតផ្លោះ មហាអស្ចារ្យនេះ។

**ស៖** ឃ្លាចុងក្រោយនៅក្នុងគោលការណ៍ទីប្រាំនេះ គឺនិយាយនៅខាងក្រោមនេះថា "ទីចុងបំផុតនៃបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមក្នុងរយៈកាលយុទ្ធសាស្ត្រថ្មីនៃបដិវត្តន៍" តើមានយ៉ាងដូចម្តេចដែរ?

[១៥:២១:២៤]

**ឆ៖** ក្រោយ១៧ មេសា គេធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម។ គេបន្តទៅទៀតឲ្យដល់កុម្មុយនីស្តនិយមក្នុងពេលឆាប់ៗនេះ។ ហ្នឹងគឺន័យគេអ៊ីចឹង។ វាបញ្ជាក់នៅក្នុងកថាខណ្ឌទីបី ដើមកថាខណ្ឌទីបី។

**ស៖** សូមអរគុណ។ ប្រហែលជាយើងអាចចូលទៅដល់គោលការណ៍បន្តបន្ទាប់ទៀត គឺបាននិយាយថាបក្សកុម្មុយនីស្តកម្ពុជា គឺចាត់តាំងឡើងតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ។ តើពាក្យថា "គោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ" ហ្នឹងមានន័យដូចម្តេចដែរ?

**ឆ៖** "ប្រជាធិបតេយ្យប្រមូលផ្តុំ"ៗ មានន័យថាភាគតិចគោរពភាគច្រើន។ មតិហ្នឹងត្រូវក៏ដោយក៏ប៉ុន្តែបើអ្នកឯងភាគតិច ភាគច្រើនគេសម្រេចហើយ ត្រូវគោរព ធ្វើតាមគេសិនទៅ។ ប្រជាធិបតេយ្យប្រមូលផ្តុំម្យ៉ាងទៀតមានន័យថា ថ្នាក់ក្រោមគោរពថ្នាក់លើ។ យើងថ្នាក់ស្រុក បើខាងថ្នាក់តំបន់ គេថាអ្ហែ មិត្តកុំធ្វើអ៊ីចឹង យើងទាស់ចិត្តក៏ដោយត្រូវគោរពតាមថ្នាក់លើសម្រេច។ ទូទាំងប្រទេសគោរពមជ្ឈិមបក្ស។ អ្នកណាក៏ដោយ ក៏ត្រូវគោរពលេខា និងអនុលេខាបក្ស។ ព្រោះគេតំណាងឲ្យសមូហភាពវាធំទូលាយជាង។ សមូហភាពគេតំណាងឲ្យមួយប្រទេស លេខាភាគតំណាងឲ្យភូមិភាគនីមួយៗទេ។ ឯចំណែក អ្នកឯងសហករណ៍នៅតំណាងឲ្យសមូហភាពត្រឹមតែគ្នាប៉ុន្មានរយ ប៉ុន្មានពាន់នាក់ប៉ុននុំង។ នេះខ្ញុំសូមនិយាយប៉ុណ្ណោះ អធិប្បាយប៉ុណ្ណោះ តាមការយល់ឃើញ ហើយតាមការអនុវត្ត។

[១៥:២៤:៣០]

**ស៖** ខ្ញុំចង់លើកឡើងសង្ខេបទេ ចំពោះការអនុវត្តជាក់ស្តែងនេះ។ ប៉ុន្តែទីមួយ លោកនិយាយថាគោលការណ៍ទីមួយ គឺគ្របដណ្តប់ទៅលើ ដែលថាមតិភាគតិចត្រូវតែយល់ស្រប ឬធ្វើតាមមតិភាគ

ច្រើន។ ទាក់ទងទៅនឹងការធ្វើសេចក្ដីសម្រេចណាមួយ ឧទាហរណ៍ថា របស់គណៈកម្មាធិការណាមួយនៅក្នុងពេលនោះ។ ថាតើគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំនៅក្នុងគណៈកម្មាធិការមួយនោះអនុវត្តនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្តដែរឬទេ?

[១៥:២៥:២២]

**ឆ៖** ដំបូងខ្ញុំសូមបញ្ជាក់ ស្អីជាភារកិច្ច ស្អីជាបញ្ហា។ បញ្ហាដាក់មក ជូនអីអាចលេខា និងអនុលេខាជជែកគ្នាសិន។ ដល់ក្រោយមកជជែកគ្នាហើយ អនុលេខាច្រើនតែគោរពតាមមតិលេខា នេះបានតែបទបញ្ជាមួយចំពោះមុខទេ។ ឯចំណែកមាគ៌ាជាទូទៅ ឲ្យតែខ្លាំងត្រូវតែកម្ទេច គ្មានអ្នកណាហ៊ានកែប្រែមាគ៌ានេះទេ។ ដូច្នេះប្រជាធិបតេយ្យលើអាបញ្ហាខ្លាំងត្រូវតែកម្ទេចប្រជាធិបតេយ្យអត់បានទេ ត្រូវតែធ្វើ។ សម្រេចបីតោនមួយហិកតាឲ្យបាន ត្រូវតែធ្វើ។ ដូច្នេះសហករណ៍នីមួយៗ តើត្រូវធ្វើអីមុន? ត្រូវធ្វើអីក្រោយ? ចាត់តាំងគ្នាប៉ុន្មាននាក់? អាហ្នឹងគេប្រជាធិបតេយ្យប្រមូលផ្តុំនៅក្នុងសហករណ៍គេ។ ហ្នឹងគឺខ្ញុំសូមបញ្ចប់ប៉ុណ្ណឹង។

[១៥:២៦:២៦]

**ស៖** សូមអរគុណ។ ប៉ុន្តែគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំនេះ ថាតើត្រូវបានយកមកអនុវត្តនៅក្នុងកម្រិតគណៈកម្មាធិការណាមួយ? តើមានយកគោលការណ៍នេះមកអនុវត្តដែរឬក៏អត់?

**ឆ៖** ក្នុងការអនុវត្តដូចខ្ញុំរាយការណ៍ជូនអម្បាញ់មិញអ៊ីចឹង ថ្នាក់ក្រោមគោរពថ្នាក់លើ បញ្ហាថ្នាក់ត្រូវតែធ្វើឲ្យបានសម្រេច។ ដូច្នេះថ្នាក់ក្រោមជជែកគ្នាទៅ ពុះពារយ៉ាងម៉េច ធ្វើឲ្យបានសម្រេចតាមនុ៎ង។ ដូច្នេះ ការដែលជជែកគ្នានៅខាងក្រោម ដើម្បីឲ្យសម្រេចតាមភារកិច្ចដែលខាងលើកំណត់មក។ ភាគច្រើនៗតែអនុលេខាស្ដាប់លេខា។

**ស៖** អ៊ីចឹងខ្ញុំយល់ថា តាមអ្វីដែលលោកលើកឡើង គឺថ្នាក់ក្រោមត្រូវធ្វើតាមសេចក្ដីសម្រេចរបស់ថ្នាក់លើ។ ប៉ុន្តែទាក់ទងទៅនឹងការធ្វើសេចក្ដី បើយើងមើលមាត្រា៦ នៃ-- មាត្រា៦(២) នៃលក្ខន្តិកៈបានលើកឡើងថា "សេចក្ដីសម្រេចផ្សេងៗរបស់បក្សត្រូវធ្វើឡើងរួមគ្នា"។

តើខ្ញុំសូមបង្ហាញមាត្រានេះនៅលើអេក្រង់បានទេ? គឺមាត្រា៦(២)។

**ឆ៖** ទំព័រ សូមបញ្ជាក់ទំព័រ។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ សូមខ្ញុំសូមដាក់ទំព័រនេះជំនួសទំព័រមុន ហ្នឹងយើងអាចមើលឃើញ

មាត្រាហ្នឹងហើយ។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** អាចទំព័រ៣០ នៅលើឯកសារលោកហ្នឹង អាចនៅត្រង់ទំព័រ៣០។

[១៥:២៩:៥៣]

**ឆ៖** មាត្រា៦ កថាខណ្ឌទី២ នៃមាត្រា៦ សរសេរថា "គ្រប់សេក្ដីសម្រេចផ្សេងៗរបស់បក្ស ត្រូវធ្វើឡើងដោយសមូហភាពគឺបានប្រជុំគ្នាៗ ដល់ហើយសម្រេចសរុប។ អ្នកណាអ្នកសម្រេចសរុប លេខា។ លេខាខ្លះចេះពន្យល់ទៅ លេខាខ្លះមិនចេះពន្យល់ អាហ្នឹងវាជារឿងមួយ។ តែយកមកសរុប ជាមួយគ្នា ពិភាក្សាគ្នានៅក្នុងសមូហភាព ក្នុងអង្គប្រជុំ ដល់សម្រេចភាគច្រើនៗតែលេខាជាអ្នកសម្រេច យកតាមមតិរបស់លេខា។ នេះខ្ញុំសូមបញ្ជាក់ម្ដងទៀត ប៉ុននុ៎ង។

**ស៖** ដូច្នេះ ពាក្យថាត្រូវតែធ្វើឡើងដោយសមូហភាពនេះ តើវាមានន័យដូចម្ដេចដែរ?

**ឆ៖** ខ្ញុំសូមលើកបញ្ហានេះ ក្នុងជាក់ស្ដែង កាលណាទទួលផែនការពីខាងលើមក តែងតែលេខា ទេ ទៅទទួលផែនការពីខាងលើ។ លេខាហៅគណៈកម្មាធិការមកប្រជុំ ឥឡូវខាងលើដាក់ផែនការមក អ៊ីចឹង តើយើងត្រូវធ្វើយ៉ាងម៉េច? អានេះហៅថាប្រជុំសមូហភាព។ ម្នាក់ថាធ្វើអ៊ីចេះ ម្នាក់ថាធ្វើអ៊ីចុះ។ ដល់ចុងបញ្ចប់ លេខាគេថាទេ ធ្វើអ៊ីចេះដូចសមរម្យជាង អាចឈ្នះ អាចសម្រេចផលជាង រហ័សជាង។ អនុលេខាថាមក។ ដូច្នេះ ចុងបញ្ចប់ លេខាជាអ្នកសម្រេច ថាធ្វើអ៊ីចេះវារហ័សបានសម្រេចផែនការ របស់យើងជាង។ នេះគឺការប្រជុំពិភាក្សាគ្នាអ៊ីចឹង។

[១៥:៣២:០៧]

**ស៖** ប្រសិនជាខ្ញុំស្ដាប់លោកមិនច្រឡំទេ នៅពេលធ្វើសេចក្ដីសម្រេច ដោយគណៈកម្មាធិការ មួយ គឺថាបញ្ហាដែលត្រូវសម្រេចគឺត្រូវតែដាក់នៅលើតុ ដែលពិភាក្សាដោយសមូហភាព តើត្រឹមត្រូវទេ?

**ឆ៖** ត្រឹមត្រូវហើយ គឺសមូហភាពក្នុងគណៈកម្មាធិការរបស់ខ្លួន។

**ស៖** សូមអរគុណ។ បើយើងមើលចុះមកក្រោមទៀត នៅក្នុងគោលការណ៍ទីប្រាំមួយ ដែល លើកឡើងថា បក្សត្រូវតែមានម្ចាស់ការប្រុងប្រយ័ត្នខ្ពស់។ តើពាក្យថា "ត្រូវតែមានម្ចាស់ការបដិវត្តន៍ ខ្ពស់" នៅក្នុងលក្ខន្តិកៈនេះ "បក្សត្រូវប្រុងប្រយ័ត្នបដិវត្តន៍ដ៏ខ្ពង់ខ្ពស់"ហ្នឹង មានន័យថាម៉េចដែរ?

**ឆ៖** បក្សត្រូវតែប្រុងប្រយ័ត្នបដិវត្តន៍ឲ្យខ្ពស់ដល់កម្រិតចំពោះគ្រប់សកម្មភាព និងគ្រប់កលល្បិច របស់ខ្មាំង ជាផ្ទាល់ ជាប្រយោល ជាចំហ ជាសម្ងាត់ ដែលប្រាថ្នាបំផ្លិចបំផ្លាញបក្សតាមគ្រប់វិធី។

នេះវាច្បាស់លាស់ហើយ គឺត្រូវប្រុងប្រយ័ត្ន កុំឲ្យគេមកបំបែកយើងបាន កុំឲ្យគេមកបំភ័យយើងបាន កុំឲ្យគេមកអូសទាញកម្លាំងយើងបាន។ ព្រោះខ្មាំងវាចេះតែមានឧបាយកលហើយ អូសទាញតាមបែបនេះ អូសទាញតាមបែបនោះ អូសទាញតាមការឲ្យលុយកាក់ អូសទាញតាមការហៅឲ្យហូបចុក។ ដូច្នេះយើងត្រូវទប់គ្នាយើងកុំឲ្យទៅ។ នេះក្នុងន័យអនុវត្តវាមានន័យអ៊ីចឹង។ ប្រយ័ត្នគ្រប់ពេលវេលា កុំចេញដើរទៅណាសេរី គ្មានការចាត់តាំង។ ដូច្នេះ បក្ខជនគ្រប់រូប ពេលនោះគ្មាននរណាហ៊ានដើរទៅណាពាសវាលពាសកាលទេ។

[១៥:៣៥:០០]

**ស៖** សូមអរគុណ។ ប្រសិនជាយើងចូលទៅលើគោលការណ៍ទីប្រាំពីរ លើកឡើងថា បក្សកុម្មុយនីស្តកម្ពុជាអនុវត្តគោលការណ៍ទិតៀន ស្វ័យទិតៀននៅក្នុងការងារប្រចាំថ្ងៃដើម្បីតស៊ូកសាងបក្សផ្ទៃក្នុង ក្នុងការកម្ចាត់ និងកែប្រែគុណវិបត្តិ និងការភ័ន្តច្រឡំផ្សេងៗដែលមាននៅក្នុងបក្ស និងជំរុញពង្រីកគុណសម្បត្តិ ដែលមាននៅក្នុងបក្សឲ្យរីកចម្រើននិងជឿនលឿនមិនឈប់ឈរ។

សំណួរដំបូងរបស់ខ្ញុំ តើវាមានន័យថាម៉េច ពាក្យថា“ទិតៀន និង ស្វ័យទិតៀន”? ជាមធ្យោបាយប្រចាំថ្ងៃនេះ តើមានន័យយ៉ាងដូចម្តេច?

**ឆ៖** ការប្រជុំជីវភាពបក្ស អាហ្នឹងគេហៅថា “ប្រជុំជីវភាពបក្ស”។ អ្នកឯងជាបក្ខជន ដាច់ប្រជុំជីវភាពបីខែ មានន័យថា អស់លក្ខណៈជាបក្ខជនហើយ។ នេះមួយ។ ទីពី ការប្រជុំជីវភាពនេះខ្ញុំបានជម្រាបព្រឹកមិញហើយ ថាជាមធ្យោបាយកសាងខ្លួន និងកសាងសាខារបស់ខ្លួន ដោយយកលទ្ធិម៉ាក្ស-លេនីន-- ដោយយកមាគ៌ាបក្សមកអនុវត្តជាក់ស្តែងជាប្រចាំ។ នៅក្នុងមួយខែជួបគ្នាម្តង យើងទិតៀនគ្នា អនុលេខាគេទិតៀនថា បងឯងនេះ អត់គិតមើល អាត្រង់នេះទេ។ យើងថា អឺ!ខ្ញុំទទួល ខ្ញុំកែ។ គេទិតៀន មកយើង គេហៅថាទិតៀន។ ទិតៀន បារាំងហៅថា “*គ្រីទិក*” ហើយស្វ័យទិតៀន បារាំងហៅថា “*អូតូគ្រីទិក*”។ ឧទាហរណ៍ លេខាម្នាក់នឹកឃើញថាខុសហើយ ដល់ពេលប្រជុំជីវភាព ថាមិត្តអើយ! ខ្ញុំសុំលាតត្រដាងដោយស្មោះត្រង់ ពេលនេះខ្ញុំខុស លួចចេញដើរដោយមិនបានប្រាប់មិត្តយើង។ នេះហៅថា “ស្វ័យទិតៀន” បារាំងហៅថា “អូតូគ្រីទិក”។

ដូច្នេះ ការកសាងខ្លួនក្នុងជីវភាព គឺគ្មានអីទេ ទិតៀន និងស្វ័យទិតៀន ប៉ុននុ៎ង ដើម្បីតម្រែតម្រង់ការអនុវត្ត ការគិតរបស់បក្ខជនមួយៗឲ្យត្រឹមត្រូវទៅតាមវិន័យបក្ស និងមាគ៌ាបក្ស។

[១៥:៣៨:០២]

**ស៖** ហេតុម៉េចបានហៅថាជា “ការប្រជុំជីវភាព” តើដូចម្ដេចបានគេប្រើពាក្យហ្នឹង?

**ឆ៖** បក្ខជនគ្រប់រូបមានជីវិត មានតម្លៃជាបក្ខជននៅលើការប្រជុំនេះឯង បើដាច់ប្រជុំហើយ ដាច់ឆ្ងាយពីបក្សហើយ។ បានជាគេហៅប្រជុំជីវភាព។

**ស៖** ដូច្នេះប្រសិនបើគេមិនចូលរួម ហើយបំបែកខ្លួនចេញ តើមានអ្វីកើតឡើង? បានន័យថាតើសមាជិកបក្សហ្នឹង ឬបក្ខជនហ្នឹង មិនចូលរួមនៅក្នុងកិច្ចប្រជុំជីវភាពហ្នឹងតើមានអ្វីកើតឡើងចំពោះពួកគាត់?

**ឆ៖** អាចនៅក្នុងលក្ខន្តិកៈនៅត្រង់កន្លែងណាមួយខាន មិនខានទេ។ ដកខ្លួនចេញជាស្វ័យប្រវត្តិពីបក្ស អស់តម្លៃជាបក្ខជន។ អានេះបើអនុត្តតឹងរ៉ឹង តឹងតែងច្បាស់លាស់មែនទែន គឺអឺចឹង។

**ស៖** នៅក្នុងគោលការណ៍ទីប្រាំពីរ បានចែងថា ការទិតៀន និងស្វ័យទិតៀនជាមធ្យោបាយប្រចាំថ្ងៃ។ ដូច្នេះតើ-- ហើយៗលោកបាននិយាយយោងទៅលើកិច្ចប្រជុំជីវភាពដែលធ្វើជារៀងរាល់ខែ។ តើមានមធ្យោបាយប្រចាំថ្ងៃបែបណាដែលយើងនិយាយអំពីការទិតៀន និងស្វ័យទិតៀន ដូចដែលមានចែងនៅក្នុងលក្ខន្តិកៈហ្នឹង ឬមួយក៏គេធ្វើជាប្រចាំខែវិញ។ ដូចដែលលោកមានប្រសាសន៍រួចហើយ។

[១៥:៤០:០៨]

**ឆ៖** ជារបៀបរបប គេធ្វើប្រចាំខែ ក៏ប៉ុន្តែប្រចាំថ្ងៃក៏យើងអាចធ្វើបានដែរ។ ស្វាត់ៗមកកេះប្រាប់គ្នា ហ្នឹងក៏បានៗ។

**ស៖** ខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែ។ ដូច្នេះលោកចង់និយាយថា ពួកគេអាចធ្វើជារៀងរាល់ថ្ងៃ ឬមួយក៏លោកនិយាយអីផ្សេងពីនេះ?

**ឆ៖** ជាគោលការណ៍មួយខែត្រូវធ្វើម្ដង។ ក៏ប៉ុន្តែក្នុងករណីចាំបាច់ខ្លះ គេធ្វើស្វាត់តែពីរនាក់ដោយខ្សឹបប្រាប់គ្នាក៏បាន។ អើៗ ស្វាត់តែពីរនាក់ហ្នឹង ចាំបាច់។

**ស៖** ដូច្នេះយើងយល់ថា ជាការអនុវត្តជាក់ស្ដែងអ្វី តើកិច្ចប្រជុំជីវភាពនេះមានទំហំបែបណា? វាមានទំហំខុសៗគ្នា ឬមួយក៏មានទំហំប៉ុនៗគ្នា? បានន័យថា មានចំនួនមនុស្សចូលរួមដូចៗគ្នា។ ដូច្នេះតើលោកអាចពណ៌នាបានទេថា តើមានរយៈពេលប៉ុន្មាន? មានចំនួនប៉ុន្មានដែរ?

[១៥:៤១:៤០]

**ឆ៖** ប្រជុំជីវភាពនេះ គេហៅថាប្រជុំជីវភាពសាខា។ បក្ខជនមួយសាខាមានបីនាក់ ប្រជុំបីនាក់។ បើមិនគ្រប់មួយសាខាទេ រត់ទៅប្រជុំនឹងគេ។ ដូចខ្ញុំបានជូនឧទាហរណ៍ព្រឹកមិញហើយ។ អង្គាល់

ខ្ញុំនៅម-១៣ ខ្ញុំមានតែបក្សជនពីរនាក់ទេ ដាច់ខែឡើងខ្ញុំទៅប្រជុំជាមួយនឹងគេ ជាលេខាសាខា។ ប៉ុន្តែក៏ដល់មកនៅភ្នំពេញ ខ្ញុំមានគណៈកម្មាធិការរបស់ខ្ញុំ ខ្ញុំប្រជុំក្នុងគណៈកម្មាធិការរបស់ខ្ញុំជាទៀងទាត់។ នេះគឺច្បាស់លាស់។ ក៏ប៉ុន្តែករណីខ្លះជាចាំបាច់ ដែលយើងមិនអាចលើកក្នុងអង្គប្រជុំបាន ក៏យើងអាចខ្សឹបប្រាប់គ្នាជាសម្ងាត់ដែរ។ ខ្ញុំលើកបញ្ហាជាក់ស្តែងមួយ។ ខ្ញុំឃើញ ណាត គាត់ចេះតែដើរចាប់មនុស្ស ជាពិសេសដែលដឹងដល់ខ្ញុំ គឺរឿងគាត់ចាប់ ទៀប កូប។ មើលនៅក្នុងឯកសារបញ្ជីកម្មេច។ ខ្ញុំភ័យ ព្រោះខ្ញុំអនុប្រធាន ដល់គាត់ចាប់សេរី ខាងលើមិនបញ្ហា គ្រោះថ្នាក់ទាំងឯងទៅទៀតណ៎ា។ ស្ងាត់ៗខ្ញុំជួបគាត់ថា បងអ្នំា សម្រេចចាប់មនុស្សដោយខ្លួនឯងអ៊ីចឹងគ្រោះថ្នាក់ណាស់ណ៎ា។ នេះនិយាយនៅក្នុងសាខាម៉េចបាន? ដូច្នេះយើងខ្សឹះប្រាប់គ្នាស្ងាត់។ ណាត គាត់ភ័យខ្លាចខ្ញុំយករឿងហ្នឹងទៅរាយការណ៍ដល់ខាងលើ គាត់រាយការណ៍ស្មាក់មុន។ ត្រូវមាត់ខាងលើ។ នេះរឿងរ៉ាវអស់នេះ ខ្ញុំនិយាយហូរហែរួចមកហើយ មុខសហាចៅក្រមស៊ើបអង្កេត។

[១៥:៤៣:២២]

**ស៖** លោកនិយាយថា កិច្ចប្រជុំបែបនេះ គឺធ្វើឡើងដោយមានគ្នាបីនាក់ គឺនៅតាមសាខា តើបក្ខជនគ្រប់រូបត្រូវតែធ្វើការស្វ័យទិតៀននៅក្នុងកិច្ចប្រជុំជីវភាពហ្នឹង? តើធ្វើចំពោះគ្រប់គ្នា ឬមួយក៏តែសម្រាប់ប្រធានផ្នែក ឬក៏ប្រធានតំបន់ទេ?

**ឆ៖** ក្នុងពេលប្រជុំជីវភាពមួយៗណ៎ា ធ្វើទាំងអស់គ្នាៗ។

**ស៖** នៅក្នុងកិច្ចប្រជុំហ្នឹង គឺមានគ្នាបីនាក់ តើកិច្ចប្រជុំហ្នឹងចំណាយពេលប្រហែលប៉ុន្មានម៉ោង ឬប៉ុន្មានថ្ងៃដែរ? តើមួយថ្ងៃ ឬមួយម៉ោង? តើលោកអាចពន្យល់បានទេ ថាតើចំណាយពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំច្រើនតែប្រជុំមួយថ្ងៃ។ តាំងពីនៅម-១៣ ខ្ញុំប្រជុំមួយថ្ងៃ។

[១៥:៤៤:៤៩]

**ស៖** លោកបានពន្យល់ថា ស្ថានភាព គឺថាលោកបានឃើញបុគ្គលម្នាក់ឈ្មោះ ណាត ចាប់អ្នកដទៃ ចាប់បុគ្គលដទៃ។ ប៉ុន្តែគាត់ជម្រាបទៅមេ មុនពេលដែលលោកបានជម្រាបទៅមេកើយរបស់លោក។ តើលោកចង់និយាយថា កិច្ចប្រជុំហ្នឹងជំរុញឲ្យមនុស្សហ្នឹងបង្ហាញ ឬក៏និយាយនូវកំហុសរបស់ខ្លួន ឬមួយក៏និយាយអំពីកំហុសរបស់បក្សមុនពេលដែលបុគ្គលដទៃរិះគន់ទៅលើគាត់? តើៗការនិយាយថា ស្វ័យទិតៀនហ្នឹងមានន័យបែបហ្នឹងដែរឬទេ? តើគោលការណ៍ទីប្រាំពីរ ជំរុញឲ្យមនុស្សបង្ហាញនូវកំហុសខ្លួនឯង មុនពេលដែលកំហុសហ្នឹងត្រូវបានគេរកឃើញ? តើលោកមានន័យបែបនេះដែរឬទេ?

[១៥:៤៥:៥១]

**ឆ៖** បញ្ហានេះ វាចូលទៅជាក់ស្ដែងទៅវិញហើយ។ ខ្ញុំសូមនិយាយទៅចុះ ក្នុងឋានៈខ្ញុំជាអនុលេខាស-២១ ខ្ញុំបានទទួលដំណឹងមកថា លេខាធ្វើខុស ចាប់មនុស្សដោយអត្តនោម័តិ។ បើខ្ញុំមិនទប់ទេណា បែកការណ៍ទៅថ្ងៃក្រោយ វាត្រូវគ្រោះថ្នាក់ខ្ញុំដែរ។ ដូច្នេះខ្ញុំត្រូវតែសាកល្បងទប់ ព្រោះខ្ញុំនិង ណាត មានមនោសញ្ចេតនាជ្រាលជ្រៅមកយូរហើយ ជួបគ្នា ប្រកបការងារជាមួយគ្នាចាប់តាំងពីឆ្នាំ១៩៦៦មក។ ដូច្នេះ ខ្ញុំរិះរកពេលស្ងាត់និយាយ យ៉ាងខ្លី ថាបងអ្ហា! ចាប់មនុស្សដោយចិត្តឯងអ៊ីចឹង គ្រោះថ្នាក់ណាស់ណា។ គាត់ក៏ច្រឡោតដាក់ខ្ញុំ បើគេរកធ្វើឃាតយើងហើយ មិនចាប់ម្ដេចបាន មិត្តថារឿងហ្នឹងតូចអ្ហ? ខ្ញុំក៏ស្ងាត់ទៅ មិនមាត់មិនកអីទេ។ ធម្មតាទេ ខ្ញុំជាអនុលេខាម្នាក់ដែលមេហៅទៅប្រជុំជាប់រហូតជាមួយនឹងលេខា។

[១៥:៤៧:១៤]

ដូច្នេះប្រហែលជាគាត់ភ័យ ខ្លាចខ្ញុំរាយការណ៍ជូនមេ គាត់ទៅនិយាយជាមួយនឹងមេមុន។ នៅពេលប្រជុំលើកក្រោយ ជួបមេ គាត់ទៅនិយាយជាមួយមេ។ គាត់ថា អ្ហេ ម៉្យោនោះពួកបង មានពួកវាចង់រកធ្វើឃាតខ្ញុំ ខ្ញុំបើកឡាន ភ្លើងឡានផ្ដេកៗទៅ ហើយអានេះមិនស្រួលខ្ញុំចាប់។ មេដោះវ៉ែនតាជូតភ្នែកដល់ទៅពាក់វ៉ែនតាវិញ នេះជាទម្លាប់គាត់។ មុននឹងថាឲ្យអ្នកណា ឬក៏សម្រេចរឿងអី គាត់ដោះវ៉ែនតាជូតភ្នែក ហ្នឹង សុន សេន។ ដាក់វ៉ែនតាវិញ គាត់ថា មិត្តចាប់មនុស្សដោយអាងលើសមត្ថភាពផ្ទាល់ខ្លួនមហាបុគ្គលៗ។ គាត់និយាយតែមួយម៉ាត់ប៉ុណ្ណឹង ណាត គាត់ស្ងាត់។ ខ្ញុំៗអត់ប៊ាននិយាយអីទេ។ ដូច្នេះរឿងហ្នឹងជាក់ស្ដែងវាទៅអ៊ីចឹង។ ក៏ប៉ុន្តែដែលខ្ញុំនិយាយនេះ ចង់និយាយថាប្រចាំថ្ងៃ។ ការទិតៀនប្រចាំថ្ងៃគឺខ្ញុំទិតៀនទៅ ណាត ក្នុងពេលណាដែលសមរម្យ ក្រៅជីវភាពបក្ស ខ្ញុំធ្វើបាន។ នេះជាលក្ខណៈមួយនៃការទិតៀនរបស់លេខាទៅលើអនុលេខាក៏មាន អនុលេខាមកលើលេខាក៏មានដែរ ឬក្នុងសមាជិកបក្សណាមួយក្នុងនុ៎ង ក៏អាចទិតៀនគ្នាបានដែរ ដើម្បីចៀសវាងគ្រោះថ្នាក់ទាំងអស់គ្នា។ ហ្នឹង គឺខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

[១៥:៤៨:៥៣]

**ស៖** ខ្ញុំសូមសួរខ្លីមួយ តើមានអ្វីកើតឡើងចំពោះ ណាត?

**ឆ៖** ខ្ញុំជួយមតិ ណាត ហ្នឹងប្រហែលជាក្នុងខែ១២ ឬក៏ខែមួយ ខែបីបក្សដក ណាត ចេញពីស-២១ លែងឲ្យធ្វើលេខា ស-២១ ដាក់ខ្ញុំឡើងវិញ។

E1/52.1

[១៥:៤៩:៤០]

**ស៖** តើនៅចុងក្រោយ ណាត កើតអីដែរ? មានបញ្ហាអ្វីកើតឡើងចំពោះ ណាត នៅចុងក្រោយ?

**ឆ៖** នៅចុងក្រោយ ណាត លែងនៅក្នុងយោធាហើយ លែងនៅជាជំនួយការសេនាធិការហើយ ណាត ផ្លាក់ខ្លួនទៅនៅក្រសួងការបរទេស។ ដល់ចុងក្រោយ មានចម្លើយប៉ះ ណាត ខាងលើគេចាប់ ណាត មកចូល ស-២១។ ហើយដល់ចុងក្រោយនេះទៀត គឺនៅក្នុងឯកសារលេខខែ៤ នៅក្នុងឯកសារ ថ្ងៃ២១ ខែ៤ ឆ្នាំ១៩៧៦ ប៉ុល ពត បញ្ជាក់ច្បាស់ គឺលែងជឿទុកចិត្ត ណាត នៅក្នុងសេចក្ដីសម្រេចចិត្ត ថ្ងៃ២១ ខែ៤ ហ្នឹង នេះការវិវត្តន៍លោកសួរខ្ញុំ។ ខ្ញុំសូមឆ្លើយប៉ុណ្ណឹងតាមការនេះ។

**ស៖** សូមអរគុណ។ តើ ណាត ស្លាប់នៅ ស-២១ ឬក៏ត្រូវគេសម្លាប់នៅ ស-២១?

**ឆ៖** ណាត ធ្វើទារុណកម្មសួរចម្លើយហើយកម្ទេច។

**ស៖** លោកបាននិយាយថា ជារៀងរាល់ថ្ងៃលោកព្យាយាមទិតៀន ណាត ហើយលោកបានលើកឡើងផងដែរថា កិច្ចប្រជុំជីវភាពហ្នឹងធ្វើជារៀងរាល់ខែ ហើយក៏យើងឃើញមាននៅក្នុងលក្ខន្តិកៈដែលចែងថា ការទិតៀន ស្វ័យទិតៀនហ្នឹងធ្វើប្រចាំថ្ងៃ ថាតើលក្ខន្តិកៈហ្នឹងបង្កើតជាវប្បធម៌មួយដែលតម្រូវឲ្យមានការរិះគន់ស្វ័យទិតៀនជារៀងរាល់ថ្ងៃដែរឬយ៉ាងណា? បានន័យថា ទោះបីថាមានកិច្ចប្រជុំផ្លូវការក៏ដោយ។ បានន័យថា ជា១បង្កើតនូវទម្លាប់ ឬក៏ជាវប្បធម៌មួយនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា?

[១៥:៥២:០៣]

**ឆ៖** ខ្ញុំជឿថាការបកប្រែធ្វើឲ្យខ្ញុំលំបាកឆ្លើយបន្តិច ប៉ុន្តែឥឡូវខ្ញុំសូមឆ្លើយតាមការយល់។ ប្រចាំខែជាគោលការណ៍ដែលត្រូវតែអនុវត្ត ក៏ប៉ុន្តែដែលហៅថាមធ្យោបាយប្រចាំថ្ងៃ ម្នាក់មើលម្នាក់ ឃើញគ្នារៀងខ្លួនទៅវិញទៅមក ខ្លួនឯងម្នាក់ៗមើលខ្លួនឯងជារៀងរាល់ថ្ងៃ ដើម្បីឃើញខ្លួនឯងខុសត្រង់ណា? នេះជាមធ្យោបាយប្រចាំថ្ងៃ គេហៅថាមធ្យោបាយប្រចាំថ្ងៃ។ ក៏ប៉ុន្តែករណីខ្លះ ដូចរឿងខ្ញុំ ហើយនិង ណាត ទៅនិយាយក្នុងសាខាម៉េចបាន។ និយាយអត់បានទេ ដូច្នេះត្រូវរកពេលនិយាយស្ងាត់។ សរុបមកវិញ ទីមួយ ប្រជុំជីវភាពត្រូវធ្វើប្រចាំខែ ដាច់ខាត។ ម្នាក់ៗត្រូវធ្វើស្វ័យទិតៀនខ្លួនឯង គេហៅថា ដាក់ខ្លួន ធ្វើស្វ័យទិតៀនខ្លួនឯង។ ដាក់ខ្លួនឲ្យគេទិតៀន ហើយបានចុងបញ្ចប់មេគេសរុប។ លេខាហ្នឹងគេសរុបថា មិត្តគួរកែត្រង់នេះ អីត្រង់នេះ ហ្នឹងប្រចាំខែ។

[១៥:៥៣:១៨]

ហើយប្រចាំថ្ងៃម្នាក់ៗត្រូវមើលលេខារបស់យើងធ្វើខុសស្អីខ្លះ? អនុលេខារបស់យើងធ្វើខុសស្អី

ខ្លះ? គិតទុក កត់ទុក រកចងចាំទុក ហើយពិចារណាគ្នាខុសត្រង់នេះ មូលហេតុមកពីស្អី? ទិតៀនយ៉ាងម៉េច? អាហ្នឹងគេហៅថា មធ្យោបាយប្រចាំថ្ងៃ។ ដល់ពេលទៅជួបគ្នាមួយខែ គេលេងអាហ្នឹង ក៏ប៉ុន្តែក្នុងករណីពិសេសខ្លះ ដូចខ្ញុំបានរាយការណ៍ជម្រាបអ៊ីចឹង។ យើងមិនអាចនិយាយក្នុងទិតៀនបានទេហ្នឹង! ស្វ័យទិតៀន ប្រជុំជីវភាពបានទេ បញ្ហានេះធំ។ នេះខ្ញុំសូមនិយាយល្អិត។

**ស៖** សូមអរគុណ។ ដូច្នេះ តើតួនាទី និងភារកិច្ច ឬក៏មានអ្វីដែរឬទេ? នៅពេលដែលយើងរកឃើញថា អ្នកណាម្នាក់មានកំហុស។ បានន័យថា យើងរកឃើញថាបក្ខជនណាមួយមានកំហុស ថាតើមានកាតព្វកិច្ច និងតួនាទីក្នុងការរាយការណ៍កំហុសទៅអ្នកដទៃដែរ ឬយ៉ាងណា ឬមួយក៏យើងមិនមានតួនាទីភារកិច្ចត្រូវរាយការណ៍នោះទេ?

[១៥:៥៤:៣៨]

**ឆ៖** មានភារកិច្ចត្រូវរាយកាណ៍ៗ។ ជាប្រចាំគឺលេខាវារាយការណ៍ ក៏ប៉ុន្តែក្នុងករណីពិសេសខ្លះ អនុលេខាវាមានផ្លូវរបស់វារាយការណ៍ទៅដែរ។ ព្រឹកមិញព្រះរាជអាជ្ញាលោកសួរខ្ញុំ ពីម្សិលមិនដឹងពេលហ្នឹង ខ្ញុំនៅផ្លូវរថទេះភ្លើងជាមួយមេ។ ខ្ញុំថាអត់ទេ។ ផ្លូវរថទេះភ្លើង ជាកន្លែងនីរសារចំហ អ្នកណាចង់ផ្ញើសំបុត្រទៅមេ យកទៅឲ្យពួកផ្លូវរថទេះភ្លើងហ្នឹង។ ផ្លូវរថទេះភ្លើងវាយកទៅជូនមេ។ គ្មានអ្នកណាចូលដល់កន្លែងមេបានទេ។ ដូច្នេះ អនុលេខាបើចង់រាយការណ៍អី ទៅពីលេខា ទៅលើតាមៗអាផ្លូវរថទេះភ្លើងហ្នឹង។ នេះជាច្រកមួយ សម្រាប់អនុលេខាវារាយការណ៍ នៅក្នុងករណីដែលវាអត់ប៉ាននិយាយជាមួយលេខា។ ប៉ុន្តែនៅក្នុងករណីណា វាប៉ាននិយាយ វានិយាយ។

**ស៖** ដូច្នេះនៅពេលដែលលេខា ឬក៏អនុលេខាបានដឹងអំពីកំហុសរបស់បក្ខជន តើគេរាយការណ៍ទៅអ្នកណាដែរ? បានន័យថា លេខាហ្នឹងគាត់រាយការណ៍ទៅអ្នកណាដែរ?

**ឆ៖** កំហុសវាទម្ងន់របស់វា។ កំហុសធម្មតា ជាទិតៀន ជាស្វ័យទិតៀន គេទុកចាំប្រជុំជីវភាព។ កំហុសណាដែលលើសពីធម្មតាទៅទៀត គេរាយការណ៍។ ហ្នឹង វាមានទម្ងន់របស់វាអ៊ីចឹង។

**ស៖** ដូច្នេះ ប្រសិនបើមានកំហុសធ្ងន់ធ្ងរ តើលេខារាយការណ៍ទៅអ្នកណាដែរ?

[១៥:៥៧:០៩]

**ឆ៖** កំហុសធ្ងន់ធ្ងរ មិនមែនលេខាធ្វើទេ តែគេធ្វើ។ លេខារាយការណ៍ទៅមេ។ ខ្ញុំសូមលើកឧទាហរណ៍ជាក់ស្តែង។ រឿងយកអ្នកទោសម្នាក់ឈ្មោះ សឺន សារី ហៅ ប្រេវ យកទៅកម្ទេច មុននឹងសួរចម្លើយចប់ ខ្ញុំអត់មាត់ អត់កទេ ព្រោះរឿងយកអ្នកទោសទៅកម្ទេច វាភារកិច្ចដែលមេប្រគល់ឲ្យ

គេ។ ហើយដល់ថ្ងៃក្រោយ មេសួរ ទេ មិត្តឌុច អាមិញដូចបាត់ចម្លើយអាប្រេវអ្វី។ ខ្ញុំថា មិត្តហ៊ា គាត់យកទៅបាត់ហើយបង សួរអត់ទាន់ចប់ផង។ យី! មិត្តហ៊ា ម៉េចអ៊ីចុង។ ដល់ក្រោយមក បានមេហៅមិត្តហ៊ា មកប្រាប់ ថ្ងៃក្រោយ ត្រូវតែប្រាប់មិត្ត ឌុច សុំយោបល់មិត្ត ឌុច អានេះចប់ហើយ យកទៅបាន មិនបាន។

អានេះនៅ អានេះចប់ហើយ អីៗ បានរៀបរយកន្លែង ឲ្យទៅជាលក្ខណៈមួយឡើងវិញ។ នេះ អ៊ីចឹង ស្រេចមេ គេរាយការណ៍ ឬគេមិនទាន់រាយការណ៍។ ប៉ុន្តែរឿងបន្ទាន់ខ្លះ រាយការណ៍ភ្លាម ដូចខ្លាំង -- ពួកអ្នកទោសឆក់កាំងភ្លើងបាន។ ខ្ញុំចុចទៅមេភ្លាម ទូរស័ព្ទទៅមេភ្លាម។ មិត្តហ៊ា ស្ទុះមកដល់ខ្ញុំ ខ្ញុំចុចទូរស័ព្ទទៅមេភ្លាម។ ហ្នឹង គឺបន្ទាន់ហើយ។ ដូច្នេះ រឿងរាយការណ៍ និងមិនរាយការណ៍ វាអ៊ីចឹង។

[១៥:៥៨:៥៨]

**ស៖** ដូច្នេះ ចំពោះកំហុសធ្ងន់ធ្ងរ តើការផ្តន្ទាទោសយ៉ាងម៉េចដែរ? តើការផ្តន្ទាទោសដែលធ្ងន់ធ្ងរបំផុត គឺមានលក្ខណៈបែបណាដែរ?

**ឆ៖** រឿងនេះ ខ្ញុំសូមនិយាយវែងបន្តិចទៅចុះ។ ខ្ញុំរៀនលក្ខន្តិកៈបក្សដំបូងជាមួយ ឆាយ គឹមហ៊ា។ ខ្ញុំថា បើកំហុសធ្ងន់ធ្ងរ ម៉េចក៏ត្រូវមកដកពីសិទ្ធិពីបក្ស? ដកសិទ្ធិបក្ស? បាន ឆាយ គឹមហ៊ា គាត់ពន្យល់ថាក្នុងបក្ស គឺយើងមិនអាចធ្វើអីក្រៅបានពីដកសិទ្ធិ ឯចំណែកកំហុសជាព្រហ្មទណ្ឌ ជាស្អីផ្សេងទៀតតាមច្បាប់សង្គមចាស់ អាហ្នឹង ស្រេចលើរដ្ឋបាលគេចាត់ចែង។ បក្សដកសិទ្ធិសិន។ លោកព្រះរាជអាជ្ញាដឹងហើយ កុយ ធួន គាត់សមាជិកមជ្ឈិម។ គាត់ទៅសម្លាប់ប្ដីគេ ក្នុងករណីដែលគេ គាត់ទៅខូចជាមួយប្រពន្ធគេ។

ប៉ុល ពត ដឹង ដំបូងដកសិទ្ធិ កុយ ធួន ពីបក្ស។ ដល់ដកសិទ្ធិ កុយ ធួន ពីបក្ស វាអស់ទាំងតំណែងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ យក កុយ ធួន មកដាក់គុក ឃុំឃាំង។ អាហ្នឹង គាត់ជានាយករដ្ឋមន្ត្រី គាត់បញ្ជាឲ្យគេដាក់ឃុំឃាំង។ ដូច្នេះ គាត់ជាលេខាបក្សផង ជានាយករដ្ឋមន្ត្រីផង គាត់សម្រេចភ្លាម ព្រួស។ សរុបមក កំហុសធ្ងន់ធ្ងរបក្សមានសិទ្ធិដកសិទ្ធិបក្សទេ។ នេះនិយាយអំពីន័យរបស់បក្ស។ ព្រះរាជអាជ្ញាគង់ឃើញហើយ នៅពេលណាដែលយើងនិយាយអំពីវិន័យ និងការអនុវត្តវិន័យ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២៦ ខែមីនា ឆ្នាំ

២០១២ គឺដើមសប្តាហ៍ក្រោយ។ ហើយបញ្ជាក់ទៀតគឺថាស្អែកនេះ អង្គជំនុំជម្រះមិនធ្វើសវនាការទេ ដូចអ្វីដែលអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនពីម្សិលមិញហើយ។ ដោយកិច្ចការជាច្រើននៅចំពោះមុខ ដែលអង្គជំនុំជម្រះត្រូវប្រជុំពិភាក្សាដើម្បីសម្រេចជាបន្តបន្ទាប់ ក្នុងន័យដើម្បីរួមចំណែកក្នុងការជំរុញ លើកកម្ពស់គុណភាពគ្រប់គ្រង ដឹកនាំសម្របសម្រួលកិច្ចដំណើរការសវនាការឲ្យប្រព្រឹត្តទៅបានរលូន ឲ្យឆាប់រហ័ស និងមានប្រសិទ្ធភាព។

[១៦:០១:៣៨]

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃចន្ទ ទី២៦ ខែមីនា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដូចគ្នានេះដែរ អនុរក្សមន្ទីរឃុំឃាំងនាំសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ទៅកាន់មន្ទីរឃុំឃាំងវិញចុះ ហើយឲ្យនាំមកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃចន្ទ ទី២៦ មីនា ឲ្យបានមុនម៉ោងប្រាំបួនព្រឹក មុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២នាទី)*